សំឡេងគាត់និយាយបន្ថែមជាមួយឥរិយាបថដ៏តឹងតែង៖

«ពួកគេនិយាយគ្នាយូរណាស់! មីងត្រូវឆុងតែអស់បួនប្រាំប៉ាន់ ទើបពួកគេចេញទៅវិញ! ពួកគេទៅដោយមិនសប្បាយចិត្តប៉ុន្មានទេ ចំណែកពូឯងយប់ឡើងគាត់ចាប់ផ្ដើមសម្រាន្តមិនលក់! មីងដាច់ចិត្តសួរ! គាត់ប្រាប់ថា អ្នកធំអស់នោះមានរឿងក្ដីដោះមិនចេញ មកហៅគាត់ចូលរួម ប៉ុន្តែគាត់ប្រកែក!»

ចិត្រាឈឺក្បាលហើយ តែគេខំពង្រឹងខ្លួនឯងឱ្យនៅភ្លឺស្វាងដើម្បី ឆ្ពោះទៅរកការសន្និដ្ឋានត្រឹមត្រូវមួយ។

«សំណុំរឿងអីទៅ គាត់មានប្រាប់ដែរ?»

អ្នកមីងនិស្ស័យគ្រវីក្បាល។

«អ្នកមីងជួយរកនឹកបន្តិចទៅ?»

អ្នកស្រីនៅស្ងៀមបិទភ្នែកសញ្ជឹងគិតបានបន្តិចទើបនិយាយបន្ថែមហាក់ដូចជាទើបនឹងនឹកឃើញ៖

«មីងនឹកឃើញហើយ! រំលងមកបានពីរបីថ្ងៃ ធ្លាប់ឮគាត់និយាយថា ប៉ូលិសឥឡូវនេះគេទំនើបជាងកាលសម័យគាត់ឆ្ងាយណាស់! គេចេះប្រើបណ្ដាញស៊ើបតាមinternetហើយថាពួកក្រៅច្បាប់ចូលចិត្តរៀនជំនាញនេះមកស៊ូជាមួយប៉ូលិស!»

តាមមើលពូខ្លួនបានជួបនិងរឿងស្មុគស្មាញណាមួយមិនខាន បានជាគាត់មិននិយាយបន្តឱ្យភរិយាស្មុគជាមួយ។ មនុស្សដែលគេគោរពពេញប្រទេសដូចគាត់គ្មានអ្វីចម្លែកទេដែលថាមានបញ្ហាស្មុគមេៗប៉ូលិសអាចនឹងនឹកឃើញមកសួរយោបល់គាត់ ប៉ុន្តែហេតុអ្វីមីងអះអាងថាពួកគេនោះចេញទៅវិញដោយមិនសប្បាយចិត្ត? មេប៉ូលិសណាខ្លះទៅមិនសប្បាយចិត្តនឹងពូខ្លួន?

«និយាយអ៊ីចឹងពូរបស់ឯង! ឧត្ដមសេនីយ៍ សេត  សេត សេត វិទូ ត្រូវហើយ សេត វិទូ! មានជ្រាបតួនាទីថ្មីរបស់ក្មួយឬនៅ?»

គេនឹកឃើញសាជាថ្មីដល់ស្នងការមហាដំឡើងឫកនោះ...ក្នុងចំណោមឧត្ដមសេនីយ៍ចាស់ក្មេងដែលខ្លួនធ្លាប់បានជួប ក្រៅពីគេម្នាក់ហ្នឹង គ្មានអ្នកណាដែលបង្ហាញចរិតឌឺដង ផ្ដេផ្ដាសាដល់លោកមា ដូចស្នងការRoyឡើយ។

គេងើបមុខសួរម្ដាយមីងថ្លៃភ្លែត៖

«ក្នុងចំណោមអ្នកធំដែលមកជួបពូកាលហ្នឹង មានអាម្នាក់ស្នងការRoyក្មេងជាងគេនោះអត់?»

គាត់គ្រវីក្បាលយឺតៗ។ ស្នងការRoyជាប៉ូលិសដ៏មានឈ្មោះល្បី អាស្រ័យដោយប្រវត្តិសិក្សាអប់រំ កិត្តិសព្ទគ្រួសារ និងភាពក្មេងវ័យរបស់គេ មីងនិស្ស័យស្គាល់ច្បាស់ក៏គ្មានអ្វីចម្លែកទេ។

គាត់និយាយមួយៗពេលក្មួយប្រុស កំពុងធ្វើមុខហាក់ទ័លគំនិត៖

«ឧត្តមសេនីយ៍មាន ឧកសេណាកា ឱត សាម៉ុន ហើយពីរនាក់ទៀតមីងមិនស្គាល់ទេ! សុទ្ធតែផ្កាយបីទាំងអស់!»

ចិត្រាបើកភ្នែកមូលក្លំ។

ឱត សាម៉ុនហេតុអីចុងក្រោយនេះមានព័ត៌មានពីសកម្មភាពមួយចំនួនដែលខ្លួនមិនបានដឹងទាល់តែសោះ?

គេឧទានសួរវិញ ៖

«ឧត្តមសេនីយ៍ ឧក សេណាកា អ្នកជំនាញការអង្កេតលើបទល្មើសបច្ចេកវិទ្យាមកពីអាល្លឺម៉ង់! គាត់ស្គាល់ពូខ្ញុំដែរ! ឮសូរតាហ្នឹងខ្លាំងណាស់! »

«មីងមិនដឹងទេចិត្រា! តាមស្មាន គាត់ទើបតែស្គាល់ពួកគេនៅក្នុងថ្ងៃដែលគេមករកជួបនោះព្រោះមីងឃើញពួកគេនិយាយគ្នាក្នុងលក្ខណៈផ្លូវការ!»

គេដកដង្ហើមធំ ក្រោកឈរដកយកទូរសព្ទចេញមកថតផ្ចិតគ្រប់យ៉ាងលើផ្ទាំងក្រដាសទុក....

## វគ្គ កិច្ចប្រជុំពេលទាបភ្លឺ

...នេះគឺជាបន្ទប់ប្រជុំពិសេស។

បន្ទប់នេះមានរាងបញ្ចកោណ ដែលមានសំណុំទ្វារកញ្ចក់ចំនួន៥ផ្នែក បំពាក់ស៊ុមប្រភេទ Angle Framed Mirrors និងឆ្លងកាត់ប្រអប់សោសុវត្ថិភាពប្រើកូដ។

នេះពុំមែនជាប្រភេទបន្ទប់នៃគ្រឹះស្ថានហិរញ្ញវត្ថុកំពូលសម្រាប់ការពារលុយកាក់មហាសាល ឬមួយរតនវត្ថុមានតម្លៃអ្វីទាំងអស់  តែវាមានតួនាទីការពារ ១០០លើ១០០មិនឱ្យបណ្ដាកិច្ចសន្ទនាថ្នាក់ជាតិអាចជ្រែកចេញមកក្រៅបានទោះបីអ្នកលបលួចជ្រៀតចូលមានមហាជំនាញបច្ចេកវិទ្យាលុកលុយបណ្ដាញលើបរិយាកាសកម្រិតណាក្ដី។

«ឯណាRoy?»

សំឡេងសួរខ្សោយៗ ស្រាលៗ តែអាចធ្វើឱ្យឱិត សាម៉ុនធូន់កណ្ដុកក្នុងចិត្តជាងកាលដែលចិត្តកំពុងនឹកឆ្ងល់ជាពន្លឹកថា ហេតុអីត្រូវកោះប្រជុំមកទាំងយប់ថ្នាក់នេះ?

«ទាក់ទងមិនបានទេ រដ្ឋលេខាធិការ!»

រដ្ឋលេខាធិការ សុម៉ា ស៊ីធឿន មានវ័យហាប្លាយ មាឌតូចបន្តិចសំឡេងស្រាលៗ តែលោកជាមន្ត្រីដ៏មានកិត្យានុភាពជាទីគោរពកោតក្រែងពីឧត្តមសេនីយ៍ផងទាំងឡាយ។

«ចេញទៅវិញចុះ!»

អ្នកដែលត្រូវគេបណ្ដេញចេញនោះគឺឧត្តមសេនីយ៍ ប្រាក់សូនីត ជំនួយការជំនិតរបស់លោករដ្ឋលេខាធិការ សុម៉ាស៊ីធឿន។ ឱិត សាម៉ុន រវេភ្នែកសម្លឹងជុំវិញខ្លួន។ ឌុក សេណាកា នៅស្ងៀមជាមួយLaptopដែលដេកស្ងៀមពីមុខ ចំណែកជា មេត្តារិទ្ធ ទំនងជារត់មកទាំងភ្នែកនៅបិទបានជាគាត់ហាក់មិនទាន់ស្វាងទឹកមុខទទួលយកកិច្ចប្រជុំពេលទៀបភ្លឺនេះនៅឡើយ។

តាមថាRoyក៏ត្រូវមានមុខក្នុងការប្រជុំទាន់ហាន់នេះ តែគេស្រាប់តែបាត់ស្រមោលទៅ ធ្វើឱ្យ ឱិត សាម៉ុន នឹកអនិច្ចាដល់អនាគតកូនប្រសា ហើយនឹកឃើញឡើងវិញដល់សម្ដីគេកាលពីល្ងាច

«ខ្ញុំនឹងត្រូវចេញពីតួនាទីក្នុងពេលបីថ្ងៃទៀត បើបិទសំណុំរឿងនេះមិនចេញ»។

ទ្វារបើកក្រោមសម្ពាធបរិយាកាសស្ងាត់ស្ងួនរង់ចាំទទួលបទបញ្ជា ស្នូរទ្វាររុញចូលមកក្នុង មិនមែនជំនួយការនោះវិលមកវិញទេ គាត់គ្រាន់តែបើកទ្វារប៉ុណ្ណោះ ព្រោះអ្នកផ្សេងម្នាក់ទៀតចូលមកដល់។

ជាមនុស្សស្រីសម្បុរជ្រះ សក់រួញដោយអន្លើ។

គាត់មានវ័យប្រមាណ៤០ឆ្នាំ អាចថាក្មេងជាងគេក្នុងចំណោមអ្នកនៅទីនេះ។ ជាមួយសំលៀកបំពាក់ស៊ីវិលថ្លៃថ្នូរ ស្ត្រីនេះមានអោបឯកសារមួយសំណុំធំ ហើយមានទឹកមុខមាំទាំម៉ឺងម៉ាត់។

«អញ្ជើញអង្គុយ! »

លោករដ្ឋលេខាធិការហៅគាត់ឱ្យមកអង្គុយក្បែរ។

បន្ទាប់មកគាត់ណែនាំបន្ថែម៖

«នេះគឺលោកស្រី មឿន សូម៉ាណែត គាត់ជាទីប្រឹក្សាផ្នែកចិត្តសាស្ត្រ! គាត់បានមកចូលរួម

ធ្វើការមួយចំនួនឱ្យខ្ញុំ ហើយថ្ងៃនេះគាត់បានព័ត៌មានខ្លះមកបង្ហាញអ្នករាល់គ្នាជុំវិញករណីកូនស្រីអភិជនដែលបាត់ខ្លួនទៅទាំង៥នាក់! បើកអង្គប្រជុំ!»

«រដ្ឋលេខាក៏ដេកមិនលក់ មកដោះស្រាយសំណុំរឿងនេះតាមរបៀបរបស់គាត់ដែរ ! ប្រហែលជារឿងក្តីនេះត្រូវឡើងកម្តៅដល់ចំណុចទុំជោរហើយ!»

ឱិត សាម៉ុនរិះគិតទាំងអោនមុខទទួលយកការអាម៉ាស់។

«ប៉ូលិសកំពុងត្រូវបានអ្នកកាសែតសរសេរត្មះមិនសំចៃដៃ! ពួកលោកក៏ដឹង! »

គាត់និយាយតិចៗ ប៉ុន្តែអាចធ្វើឱ្យឧត្តមសេនីយ៍ម្នាក់ៗត្រៀមលក្ខណៈរួចរាល់ក្នុងការរបូតមួក។

អំណាចពិតប្រាកដមួយនៅក្នុងប្រទេសនីតិរដ្ឋ គឺគ្រប់គ្នាត្រូវស្ថិតនៅក្រោម ច្បាប់ហើយអ្នកដែលគោរពនីតិរដ្ឋពិតប្រាកដ ពុំមែនស្រលាញ់វាតែពេលណាដែលវាផ្តល់ផលប្រយោជន៍ដល់ខ្លួននោះទេ គឺត្រូវតែគោរពវាជានិច្ច ទោះបីវាកំពុងតែផ្តល់ហានិភ័យមកឱ្យខ្លួនក្តី។

ប៉ូលិសម្នាក់ៗដឹងច្បាស់ណាស់ថា ការបំពេញភារកិច្ចមិនបានល្អគឺជាសូចនាករនៃលទ្ធភាពដ៏មានកម្រិតរបស់ខ្លួន។ ទោះបីឧក្រិដ្ឋជនពូកែកម្រិតណា ប៉ូលិសមិនអាច យកលេសនេះមកលាងកំហុសហើយរក្សាតួនាទីរបស់ខ្លួនបាននោះទេ។

«ខ្ញុំទទួលកំហុសគ្រប់យ៉ាងទាន!»

ឌិត សាម៉ុននិយាយតិចៗ តែក៏ល្មមឱ្យ ជា មេត្តារិទ្ធ ស្វាងចេញពីការងោកងុយ។

ភាគទី៤៤

«លោកចាំទទួលកំហុសក្រោយពេលចាប់មេខ្លោងបានសិនក៏មិនទាន់យឺតប៉ុន្មាន!»

រដ្ឋលេខាធិការនិយាយធម្មតា តែគ្រប់គ្នាលែងរមូលពោះចង់បានកាហ្វេព្រឹកព្រលឹមអ្វីហើយ។

បុរសមានអំណាចជាងគេនៅទីនេះចាប់ផ្តើមរាដៃឱ្យសញ្ញាស្ត្រីចំណាស់ជាទីប្រឹក្សា។ អ្នកស្រីមឿន សូម៉ាណែត ចាប់ផ្តើមនិយាយ៖

«តាមការបញ្ជាពីឯកឧត្តមរដ្ឋលេខាធិការ ខ្ញុំបានចុះទៅជួបនារីរងគ្រោះទាំងប្រាំ! នេះគឺជាកំណត់ហេតុដែលបានរកឃើញ! ពួកគេត្រូវបានចាប់ខ្លួនដោយអង្គរក្សដែលចូលដៃជាមួយអ្នកបើកបរផ្ទាល់!»

ឌិត សាម៉ុនងាកមើលមុខគ្នាជាមួយមិត្តរួមការងារ។ រឿងសំខាន់យ៉ាងនេះស្រីៗទាំងនោះមិនព្រមនិយាយ ហើយបិទមាត់ជិតឈឹងរហូតដល់ពេលវិលដល់ផ្ទះហើយក៏មិនព្រមជួបប៉ូលិសតើដោយសារមូលហេតុអ្វី?

អ្នកជំនាញផ្នែកចិត្តវិទ្យាមានជំនាញខ្ពស់ក្នុងការ មើលបញ្ហានៅក្នុងភាពលម្អិតនានា ហើយក៏

មានសមត្ថភាពខ្ពស់ក្នុងការធ្វើសេចក្តីវិភាគលើ ទម្រង់ចរន្តផ្សេងៗនៅក្នុងសកម្មភាពរបស់មនុស្សម្នាក់ៗដែលគេចង់សិក្សា ។

ពួកគេអាចធ្វើការ កត់សម្គាល់លឿននិងច្បាស់លើរាល់ចំណុច ស្រដៀងគ្នាឬក៏ ភាពខុសគ្នាខ្លាំង ព្រមទាំងឈ្លេចយកព័ត៌មានលម្អិតនៃស្ថានភាពនានាបានភ្លាមៗ និង ជាជំនាញដ៏មានតម្លៃសម្រាប់នីតិប្រតិបត្តិ។ ប៉ូលិសគ្រប់គ្នាត្រូវចេះចិត្តសាស្ត្រ គ្រាន់តែថាក្នុងកម្រិតមិនដូចគ្នា តែលោកឱត សាម៉ុនកំពុងនឹកមិនយល់ថា ហេតុអីស្ត្រីនេះអាចធ្វើឱ្យពួកនាងព្រមនិយាយ។

សំឡេង ជាមេត្តារិទ្ធ លាន់ឡើងកាត់ផ្តាច់ការត្រិះរិះរបស់ឱត សាម៉ុន៖

«ការស្រាវជ្រាវដោយយកអង្គរក្ស និងអ្នកបើកឡានជាភារកិច្ចរបស់ខាងខ្ញុំ! រហូតដល់ពេលនេះក្រុមគ្រួសារពួកគេមិនបានបញ្ឈប់ការទាមទារឱ្យយើងស្វែងរកដំណឹងប្តីរបស់ពួកគេទេ! បានន័យថាម៉េច? បើពួកនោះខ្លួនឯងជាឧក្រិដ្ឋជន ហើយពួកគេទៅណាបាត់មិនព្រមទាក់ទងមកផ្ទះសោះ?»

មឿន សូមាណែត ហាក់តោះតើយនឹងសំណួរនេះ អ្នកស្រីឆ្លើយតបវិញធ្វើវាហី៖

«ពុំមែនជាភារកិច្ចរបស់ខ្ញុំក្នុងការឆ្លើយរឿងនេះទេទាន! »

ជាមេត្តារិទ្ធងក់ក្បាល ៖

«បាទ អញ្ជើញបង្ហាញរបាយការណ៍លោកស្រីទៀតចុះ!»

«ការវិភាគជាទូទៅ! មនុស្សស្រីទាំង៥ត្រូវបានចាប់ឃុំក្នុងទីមួយងងឹត! ប៉ុន្តែមានអាហារដាក់ឱ្យគ្រប់គ្រាន់ហើយចម្លើយពួកគេពេលចេញមកវិញ គឺមិនស្រវាំង មិនទន់ខ្សោយផ្លូវកាយ! គ្រប់យ៉ាងគឺធម្មតា! ពួកគេមានការលាក់លៀមខ្លះក្នុងការផ្តល់ចម្លើយ រហូតដល់មិនអាចគេចវេះបាន ទើបព្រមនិយាយចេញមក! ស្ថានភាពទូទៅនៅក្នុងពាក្យចម្លើយរបស់ម្នាក់ៗ មិនបានបង្ហាញថា ពួកគេមានគំនុំជាមួយអ្នកដែលដៃដល់ទាំងនោះខ្លាំងក្លាឡើយ ប៉ុន្តែគេហាក់មានការភ័យព្រួយអ្វីផ្សេងដែលខ្ពស់ជាងនេះ!»

«ជាអ្វីទៅ?»

ជាមេត្តារិទ្ធិបន្តសួរ។

«ខ្ញុំក៏មិនដឹងដូចគ្នា!»

អ្នកចិត្តសាស្ត្រឆ្លើយធ្វើវាហើយធ្វើឱ្យគ្រប់គ្នាងើបមុខមកសម្លឹងរដ្ឋលេខាធិការ។ លោកសូម៉ាស៊ីធឿននៅស្ងៀមមិនមាត់គឺគាត់កំពុងឈ្ងោកត្រិះរិះ។

«បើអ្នកចិត្តសាស្ត្រមិនអាចសួរកើតផង ឱ្យប៉ូលិសទៅសួរចម្លើយរបៀបណាវិញ? គ្រួសារពួកគេអស់នោះ ក៏មិនងាយនឹងនិយាយជាមួយដែរ!»

អ្នកស្រីឆ្លើយតបវិញ៖

«អ៊ីចឹងហើយបានជាខ្ញុំទៅជាលើកទីពីរ! ហើយទៅដោយមិនឱ្យពួកគេដឹងខ្លួនមុន! ខ្ញុំបានថតរូបជាច្រើននៅទីកើតហេតុ ដែលពួកគេធ្លាប់ជាប់នៅ! ២នាក់ក្នុងចំណោមមនុស្សទាំង៥ជឿថាអ្នកចាប់ពួកគេមានបំណងផ្សេងក្រៅពីលុយកាក់ ឬបំពារបំពានរាងកាយ! ពីរនាក់នោះជឿថានេះជាការបំភ័យឪពុកពួកនាង លើផ្នែកជំនួញ!»

រដ្ឋលេខាធិការងាកទៅរកលោកឧកសេណាកាភ្លាម៖

«យើងអាចស្វែងរកទិន្នន័យថា អ្នកណាខ្លះជា គូបដិបក្ខជាមួយគ្រួសារពួកនាងដែរអត់?»

ឧកសេណាកាចាប់ផ្តើមបើកកុំព្យូទ័រធ្វើការរបស់គាត់។

«ខ្ញុំត្រូវការពេលម្ភៃនាទីយ៉ាងហោច! ហើយខ្ញុំត្រូវការPasswordទាន!»

បន្ទប់នេះមានSecurityគ្រប់គ្រងលើបណ្តាញinternet ដូច្នេះហើយរដ្ឋលេខាធិការបានហុចUSBមួយទៅឱ្យឧត្តមសេនីយ៍ដែលជំនាញកុំព្យូទ័ររូបនេះដើម្បីបើកផ្លូវបំពេញភារកិច្ចរបស់ខ្លួន។

ឆ្លៀតពេលនោះ ឪត សាម៉ុនរាយការណ៍៖

«ក្នុងចំណោមអ្នក រងគ្រោះទាំងប្រាំ មានបីនាក់ ដែលមានឪពុកម្តាយជាធុរកិច្ចជន ម្នាក់ទៀតឪពុកជាចៅក្រម ហើយម្នាក់ចុងក្រោយគ្មានឪពុកម្តាយទេ គេមកពីអង់គ្លេសជាអ្នកជំនាញផ្នែកfashionក៏ជាអ្នកដែលរៀបចំកម្មវិធីសមោសរនោះឡើង!»

រដ្ឋលេខាធិការយកបាតដៃមកទ្រចង្កាខ្លួនឯង។ សំឡេងអ្នកចិត្តសាស្ត្រនិយាយឡើង៖

«យើងបានសួរពួកគេពីសមោសរនោះ! គ្មានអ្នកណាម្នាក់ក្នុងចំណោមពួកគេយល់ថា ជនឈ្មោះមហាវីន ឬ Sponsor ឈ្មោះLorenzo នៅពីក្រោយការចាប់ខ្លួននេះទាំងអស់! ពួកគេហៅវាថាជារឿងជួនគ្នាឬអាចថា អ្នកដៃដល់ឆ្លៀតពេលកម្មវិធីមួយនោះមកបំភ័ន្តក្រុមប៉ូលិស!»

ដល់ពេលលោករដ្ឋលេខាធិការគ្រវីក្បាល៖

«វាមិនអាចជួនគ្នាដល់ម្លឹង! គេមិនអាចចង់ធ្វើបាបមនុស្ស៥នាក់ហើយស្រាប់តែមានកម្មវិធីមួយដែល៥នាក់នោះ អាចទៅជួបដោយគេមិនមានទាក់ទងអ្វីនឹងកម្មវិធីនោះសោះទេ! គេគួរតែបានរួមចំណែកបង្កើតឱ្យមានសមោសរនោះឡើង!»

ជាមេត្តាវិទ្ធនិយាយទាំងមុខមាំ៖

«អាណាម្នាក់នោះ វាលេងសើចជាមួយប៉ូលិស!»

ឱត សាម៉ុនក៏បន្ទរបន្ថែម៖

«កូនស្រីខ្ញុំក៏ត្រូវគេចង់បន្លំចាប់ ហើយអ្នកដៃដល់ជាស៊ីវិលដែលប្រើខោអាវប៉ូលិស! ពួកគេនិយាយស្តីដូចប៉ូលិស ធ្វើសកម្មភាពដូចប៉ូលិសបានឥតខ្ចោះ! ជនសង្ស័យដែលប្រើពួកគេឈ្មោះដេវីត កំពុងក្នុងដៃយើង ម្នាក់នោះសារភាពថា គេទទួលលុយពីតួឯកសប្បុរសដែលជា Sponsor ធំនោះ ឱ្យចាប់កូនស្រីខ្ញុំនិងធ្វើសកម្មភាពចាប់ស្រីៗទាំងប្រាំនាក់នោះផង! ជំនួយការផ្ទាល់របស់lorenzo ក៏បានសារភាពដែរថា ចៅហ្វាយក្មេងរបស់ខ្លួនជឿលើភូតព្រាហ្មសហេតុ! គេជឿហោម្នាក់ឈ្មោះពាងដែលថាអាចនឹងមានអំណាចកែប្រែថាមពល បើអាចរកបានមនុស្សស្រីឆ្នាំនាគ ៣៥នាក់ដែលកើតនៅឆ្នាំ២០០០មករួមមេត្រីជាមួយគ្នា! »

រដ្ឋលេខាធិការនិយាយទាំទាំងទឹកមុខខឹង៖

«ឆ្កួតពេញបន្ទុក! ដោយសារអ៊ីចឹងហើយបានជាស្រីៗរងគ្រោះអស់នោះមិនព្រមចង់និយាយអ្វីទាំងអស់ព្រោះកិត្តិយសគ្រួសារគេហើយថែមទាំងមិនចោទប្តឹងម្នាក់នោះ!»

ឱត សាម៉ុនបដិសេធការសន្និដ្ឋាននេះភ្លាមដោយអធិប្បាយ៖

«ជំនួយការនោះអះអាងថា មុនពេលបាត់ខ្លួនទៅ Lorenzo នៅមិនទាន់បានប៉ះពាល់ក្មេងស្រីៗអស់នោះនៅឡើយ!»

«ម៉េចអ៊ីចឹង?»

ឱុក សេណាកាភ្លាត់មាត់មក ប៉ុន្តែគាត់មិនមែនកំពុងប្រកែកឬដាក់សំណួរទៅទល់នឹងសម្តីរបស់ឱិត សាម៉ុនទេ ប៉ុន្តែគឺគាត់កំពុងឈ្លោះនឹងកុំព្យូទ័រខ្លួនឯង។

រដ្ឋលេខាធិការ ស៊ីធឿន អានមើលនាឡិកាមុនពេលងាកទៅពិនិត្យ ឱុក សេណាកា ដោយយកចិត្តទុកដាក់។ ឧត្តមសេនីយ៍មកពីនាយកដ្ឋានបច្ចេកវិទ្យា ឱុក សេណាកា រុញ laptop បែរមកឱ្យមេដឹកនាំពិនិត្យភ្លាម។

រដ្ឋលេខាធិការពិនិត្យហើយ ក៏យកចង្អុលដៃ ចុចចុះឡើង ក្រវែមក្រវាម មុនពេលព្រមងក់ក្បាលផ្ងក់ៗ ទំនងអាចកាត់យល់ការសំខាន់អ្វីមួយ ដែលធ្វើឱ្យឧត្តមសេនីយ៍ពីររូបទៀតកាន់តែអន្ទះសាចិត្ត។

យល់ចិត្តច្រាសច្រាល់របស់បណ្តាឧត្តមសេនីយ៍ដែលនៅជុំវិញតុនេះ ឱុក សេណាកា និយាយមួយៗប្រាប់៖

«លើកលែងតែអ្នករងគ្រោះចុងក្រោយឈ្មោះ Rose! ប្អូននាក់ទៀតផ្សេងទៀត ឪពុកម្តាយគេមានសត្រូវរួមតែមួយ!»

«អ្នកណា?»

ឱុក សេណាកា ងាកមករកមេកោយ។ បានរដ្ឋលេខាធិការអនុញ្ញាត គេចាប់ផ្តើមនិយាយ៖

«គ្រួសារលោកថៅក្រុមមុនីតារា និងនាយកOceanACលោកពិនមឿង ព្រមទាំងគ្រួសារក្មេងស្រីឆ្នាំរោងពីរនាក់ទៀត ធ្លាប់មានបញ្ហាជាមួយក្រុមហ៊ុនសេវាកម្មផ្នែកច្បាប់មួយជាកម្មសិទ្ធិរបស់អតីតប៉ូលិសម្នាក់ឈ្មោះសេតវិទូ និងភរិយារបស់គេសូត្រនិស្ស័យ!»

ឱិត សាម៉ុនចំហមាត់....

**វគ្គ កូននាគគួរឱ្យស្រលាញ់**

រាត្រីនៅតំបន់ភ្នំពោរពេញទៅដោយសន្សើមត្រជាក់។ នេះគឺជាយប់ទីពីរដែលអភិជនត្រូវសម្រាកក្នុងផ្ទះអនាគត។

គេចូលមកដល់ទីសម្រាកក៏ឃើញនាងរៀបចំដាក់ចំបើងក្រាសឃ្មឹកហើយក្រាលភួយពីលើនៅឯគ្រែឈើដ៏តូចប្រែខ្លួនសឹងមិនចង់បានមួយនោះ។

ធុញណាស់និងបរិយាកាសនេះ ប៉ុន្តែងាកមកឃើញរង្វង់មុខតូចច្រឡឹងរបស់នាងដែលខំរៀបចំកន្លែងឱ្យខ្លួនបែកញើសសស្រោក់ទាំងអាកាសធាតុត្រជាក់ បុរសនេះមិនអាចធ្វើចិត្តថ្មបាន។

គេសួរទាំងឈរផ្ទឹង៖

«ក្រាលចំបើងធ្វើអី?»

នាងសម្លក់ហើយនិយាយផ្ទូង៖

«ស្មានថាក្រាលឱ្យគោស៊ី?»

គេឃើញនាងសម្លក់ក៏ញញឹមតប។

ស្នាមញញឹមបុរសនេះរឹតតែចិញ្ចាចក្រោមស្រមោលព្រះចន្ទានាយប់១៤កើត។ នាងពិតជាអៀនតែក៏កក់ក្ដៅនិងរូបសម្រស់របស់ទេវបុត្រ។ ប្រសិនបើគេមានវត្តមាននៅផ្ទះអនាគតកាន់តែយូរ នាងមុខតែនឹងអរគុណព្រះជាក់ជាមិនខាន។

គេនិយាយពេលឃើញនាងលាក់លៀមក្ដីអៀនប្រៀន៖

«ស្មានថា អ្នកណារៀបការ ហើយចាប់ក្មេងៗឱ្យរៀបចំគ្រែផ្សំដំណេកឱ្យ!»

«ខ្ញុំកើតឆ្នាំ២០០០ មិនមែនក្មេងទេ! បងឯងរាប់សារដើមទៅ!»

ប្រុសស្អាតរុះរោយស្នាមញញឹមសន្សឹមៗ។ ពាក្យឆ្នាំ២០០០បានធ្វើឱ្យក្ដីឈឺចាប់ក្នុងបេះដូងរើឡើងមកវិញ ហើយគេនឹកឃើញដល់កូននាគីស្រស់ៗរបស់ត្រកូលអភិជនផងទាំងពួងដែល

ខ្លួនបានជំពាក់ភ្នែក។ ពួកគេពេលនេះមិនដឹងជាយ៉ាងណាហើយទេ គម្រោងការទាំងអស់ក៏កំពុងតែខ្លាចជាផេះដែរ។

«អូយឈប់ហៅបងក៏បាន! ដុះពុកមាត់តិចតួចមិនមែនមានន័យថាធំជាងខ្ញុំប៉ុន្មានទេ! ប្រាប់ឈ្មោះមក ហៅឈ្មោះហ្មងបានស្មើគ្នា!»

នាងនិយាយរញ៉ាំរញ៉ូវបន្តបន្ទាប់គ្នា តែទេវបុត្រដឹងថា កូននាគកម្សត់នេះ និយាយឱ្យតែបាននិយាយ បន្លប់ភាពរំភើបដែលបេះដូងនាងកំពុងលោតចច្រប់ធ្លាក់លង់ក្នុងអន្លង់មន្តស្នេហ៍ប្រុសស្អាតនៅនឹងមុខនេះទៅហើយ។

Lorenzoនៅជិតនារីនេះ ភ្លេចអស់ទុក្ខកង្វល់។ គេញញឹមដើរទៅពីក្រោយនាងហើយលូកដៃម្ខាងដែលមិនឈឺ ទៅចាប់ស្មា។ បុប្ផាព្រឹក្សព្រៃ នៅទ្រឹងបន្តិចដែរពេលត្រូវគេប៉ះបន្ទាប់មកក៏រេខ្លួនទម្លាក់ដៃគេចេញ។

ពេលសន្សាងាកមកសម្លក់ ភ្នែកស្រីទាំងសង ហាក់ធំប្រផែងទំហំ ពងមាន់។ ជាមួយអំពូលម៉ាងសុងក្រហមរស្មីមាស នាងពិតជាស្អាតដូចសត្វក្ងោកលាក់កន្ទុយមិនទាន់បញ្ចេញ។ រោមភ្នែកងរខ្វង់ ហើយប្រស្រីភ្នែកធំៗដូចគេបង្កប់ត្បូងនិលនៅខាងក្នុង។ ភាពស្មោះបរិសុទ្ធនៅក្នុងពន្លឺភ្នែកនាង និងបបូរមាត់រីកត្រសុំដូចបុប្ផារីកគ្រប់រដូវ ធ្វើឱ្យបុរសមើលភ្លឹក។ តណ្ហានៃការចង់បានផ្កាមកអោបប្រលោម កម្រើករំពើកក្នុងទ្រូងមនុស្សប្រុសឡូយឆាយដែលធ្លាប់ឆ្លងកាត់រាត្រីជាមួយមនុស្សស្រីរាប់មិនអស់។

ក្មេងស្រីមិនទាន់ជ្រុះពន្លៃពីក្បាលដូចនាង បេះដូងគ្មានកករល្អក់ដូចនាង តើរសស្នេហ៍ផ្អែមដូចទឹកឃ្មុំដែលរកបានពីអាម៉ាហ្សូន ព្រៃដ៏កម្រនោះដែរឬអត់ទេ?

«ប៉ះពាល់ខ្លួនគេពេញមួយតួ! ពេលនេះកាន់ស្មាតិចតួច ធ្វើឯងរលាស់ចេញ!»

សំឡេងគេនេះប្តូរមកជាលែងទ្រគោះ ខ្ពស់កប់ពពកដូចពីម្សិល ហើយវាមានសព្ទពីរោះ ពិសាបន្ទន់ចិត្ត។

សន្សាវភ្នែកចេញពីពន្លឺចក្ខុគេ ព្រោះនាងមិនចង់ឱ្យគេឃើញមូលហេតុដែលធ្វើឱ្យដង្ហើមនាងដកញាប់។ ភាសាបេះដូងមិនអាចលាក់តាមសរសៃភ្នែកបានឡើយ។ ស្រីតូចសម្លឹងមកស្មាហើយទ្រូងនិងទម្លាក់ពីចង្កេះមកដល់ចុងជើងគេ។

ធម្មតានាងពូកែនិយាយបំផុត តែពេលនេះដូចជាកំពុងស្ងាត់ឈឹង។

កម្មករនេសាទម្នាក់នេះ មន្តស្នេហ៍រោលរាលពេកហើយ នាងគិតម្នាក់ឯងស្របពេលដែលស្រមោលគេក៏រំកិលចូលមកក្បែរ ធ្វើឱ្យនាងដកថយ។ នាងកាន់តែដកថយ គេកាន់ចង់បន្ថែមទៅមុខ។

«ខ្ញុំហៅបងឯងថាពូវែងចុះ!»

គេទ្រឹងលែងចូលទៀតព្រោះអាណិតនាងដែលនៅតែខំបន្លប់ចិត្តស្រលាញ់។ នាងទាបស្រោប់ហើយកំពុងអៀន ឈ្ងោកមុខក្រោមទ្រូងបុរសនេះ។

គេដឹងថាកម្ពស់ខ្លួនឯងទេ ដែលធ្វើឱ្យកូននាគច្រឡឹង មកដាក់ឈ្មោះ «វែង» នេះឱ្យគេ។ ប្រុសស្អាតប្រើសំឡេងស្រទន់សួរ៖

«អស់ពីបង មកហៅពូឱ្យចាស់គ្នាអស់!»

នាងឆ្លើយផ្ទួងទាំងសើចខឹក៖

«អ៊ីចឹងហៅអាវែង?»

នាងសើចខឹកៗងើយសម្លឹងនាយដែលមិនខ្វីសើច។

បុរសនេះក្តាប់មាត់ប្រឆាំងនិងរាងកាយដែលចង់រឹតត្បិតឃុំឃាំងកូននាគច្រឡឹមឱ្យជាប់រហូតដល់នាងស្រែកអង្វរចាំលែង តែគេទប់ចិត្តបាន ព្រោះទងផ្កាមិនសមណាឱ្យបុរសណាម្នាក់មកធ្វើបាបប្រឡាក់ប្រឡូសទឹកចិត្តដ៏ល្អបរិសុទ្ធរបស់នាងទាល់តែសោះ។

គេប្តូរពីរចង់ក្រសោប មកប្រើដៃដដែលក្តាប់ស្មានាង។

«ហៅម្តងទៀតមើល៍!»

បុរសនិយាយទាំងខាំមាត់។ នាងរលាស់ចេញ គេមិនលែង នាងកាន់តែរើគេកាន់តែកាន់ជាប់ម៉ឹង។នាងធ្វើមុខជូរស្រែកដាក់៖

«គេមានកម្លាំងគេហើយហ្អែន! ដឹងអ៊ីចឹងយប់មិញទុកឱ្យដេកក្ដៅមិនខ្វីស្ងំទឹកឱ្យទេ! អត់ងងុយឡើងមួយយប់ទល់ភ្លឺ!»

ម្រាមនាយរបូតខ្សាក ព្រោះតែការទោរទន់ដូចបាយម៉ាននៃចិត្តដែលជាអភិជនរឹងរូសក្រអឺតក្រអោង។ កាលពីមុន មនុស្សស្រីកើតឆ្នាំ២០០០ក៏ដោយ បើមិនមែនអ្នកនាងធំអ្នកនាងតូចកុំសង្ឃឹមLorenzoនឹងយកខួរទៅគិត។ ពេលនេះគេធ្លាក់ខ្លួនលង់អាណិតកូននាគតូចល្អិតយ៉ាងជ្រៅ មិនដែលមានមកពីមុនជាមួយស្រីឯណាដូច្នេះឡើយ។

«ហើយអត់គេងមែន?»

គេសួរតិចៗដោយខ្សែភ្នែកស្រទន់ ។

នាងងាកមុខចេញហើយនិយាយ៖

«រកធ្មេច អ្នកខ្លះស្រែកក្ដៅ មមើមមាយ! ធ្មេចម៉េចនឹងលក់!»

នាងចាកចេញទុកឱ្យនាយឈរម្នាក់ឯងក្នុងខ្ទម។ មនុស្សមិនដែលស្គាល់គ្នា ម្ដេចក៏នាងមកយកចិត្តទុកដាក់រឿងអាយុជីវិតនាយធ្វើអ្វី? បុរសថយទៅអង្គុយគិតលើគ្រែក៏ឃើញនាងលើកល្អីមួយចូលមក នាំទាំងក្លិនឆៃថាវមកជាមួយ។

គេជ្រួញចិញ្ចើមនិយាយ៖

«យកស្អីចូលមកហ្នឹង ធំក្លិនអាក្រក់!»

នាងសម្លក់នាយដូចមុនហើយទើបនិយាយ៖

«កន្លែងនេះរោងបាយ បើមិនយកឆៃប៉ូវមកទុក ឱ្យទុកនៅឯណា? ថ្នាក់រៀនអត់ទ្វារទេ បើកណ្ដុរមកស៊ីអស់ ស្អែកក្មេងៗបានអីហូបបបរ?»

«ក្មេងៗណា?»

«កូនសិស្សរបស់សាលាអនាគត!»

គេលបសម្លឹងនាងពីក្រោយ។ គេយល់ហើយថាទីនេះជាសាលាសម្រាប់ពួកក្មេងក្រីក្រ ហើយក៏យល់បណ្ដើរៗដែរថា ហេតុអ្វីបានជានាងចង់ជួបLorenzo។

«បងឯងគេងទៅ! ស្អែកហ្នឹងក្មេងៗមកតាំងងងឹតឡូឡាពេញហ្នឹង! តិចថាគេងមិនគ្រប់ លាប់គ្រុនវិញ!»

គេសម្លឹងជុំវិញខ្លួនសាជាថ្មី។ អាការៈកនិងសរសៃគ្រេចហាក់ដូចធូរស្រាលស្មើទិព្វមន្ត ឱសថអីក៏សក្តិសិទ្ធិម្ល៉េះ? ដោយសារតែយ៉ាងនេះ ទើបពួកអ្នកស្រុកអាចរស់នៅទីដាច់ស្រយាលអស់ទាំងនេះបាន?

គេរវេ្ភកពិនិត្យចានឆ្នាំងដែលបីពេលមកហើយ គេស្គាល់តែអំបិលនិងបបរក្ដៅ នាងគ្មានអាហារ ឬជំងឺគេមិនអាចឆីអ្វីផ្សេងបាន?

គេសួរស្រាលៗ៖

«គ្មានត្រីសាច់ទេ មានតែឆៃថាវក្រៀមអស់នេះ?»

នាងនៅស្ងៀមទ្រឹងដៃឈប់រៀបចំរបស់របរមុនពេលងាកមកយឺតៗ។ សេចក្តីអាណិតអាសូរកើតមានក្នុងកែវភ្នែកនារីនេះ។ នាងដើរចូលមកក្បែរហើយទាញកៅអីអង្គុយទល់មុខនាយដូចកាលពីព្រឹក។

«បងឯងឃ្លានហ្មែន?»

គេនៅស្ងៀមលង់ក្រោមចិត្តមេត្តារបស់នាង។ ប្រុសស្អាតមិនឆ្លើយរវល់តែសម្លឹងកែវភ្នែកនាងទាំងសងខាងធ្វើឱ្យស្រីតូចសន្សា លាន់មាត់មកទៀត៖

«បងឯងហ៊ាននៅតែឯងអត់? ខ្ញុំជិះទៅភូមិទិញសាច់ និងត្រីមក!»

គេមិនឆ្លើយបែរជាប្រើដៃដែលមិនឈឺទាញប្រអប់ដៃនាងឱ្យក្រោកមកជាមួយ។

«មិនឃ្លានអីទាំងអស់! ចង់អង្គុយមើលលោកខែនិយាយគ្នាលេងមួយកូននាគ!»

នាងបណ្ដោយឱ្យប្រុសស្អាតបណ្ដើរមកក្រៅ ព្រោះអាល័យតែភ្លឹកនិងពាក្យ «កូននាគ»ដែលគេទើបនឹងហៅ។

ភាគទី៤៥

បុរសឈររំភើយស្រូបយកខ្យល់អាកាសហាក់រីករាយនិងវិស្សមកាលមួយមិនបានព្រាងទុកនេះស្រាប់តែឮនាងសួរផ្ទួង៖

«ម៉េចបងឯងដឹងថាគេកើតឆ្នាំនាគ!»

ប្រុសស្អាតងាកមកវិញទាំងបើកភ្នែកធំៗ ហើយឆ្លើយតបវិញហាក់ហួសចិត្ត៖

«អុញ! អ្នកណាប្រាប់ថាខ្លួនឯងកើតឆ្នាំ២000?»

នាងបួញមាត់រអ៊ូ៖

«គិតលេខរហ័សម៉េះ? ចេះរាប់ឆ្នាំខែទៀត? កម្មករសមុទ្រសោះហ្នឹង!?»

បុរសក្រឡេកមកនាងជាមួយខ្សែភ្នែកស្រទន់ជាងពន្លឺព្រះចន្ទដែលចាំងពីលើក្បាលពួកគេទាំងគូនេះទៅទៀត។ កម្មករសមុទ្រអាចធ្វើឱ្យស្រីចិត្តបរិសុទ្ធមានមេត្តាករុណាលើគេកម្រិតនេះ យើងគួរសំងំធ្វើជាកម្មករនេសាទតទៅ ឬមួយសារភាពពីអង្គLorenzoក្នុងខ្លួនយើងប្រាប់ដល់នាងជាការស្មោះត្រង់ទៅវិញទៅមក?

នាងថយទៅអង្គុយលើគ្រែឫស្សីធំមួយ ជាកន្លែងទុកសម្រាប់ឱ្យពួកក្មេងៗហូបអាហារនៅសំយាបខាងក្រៅថ្នាក់។ បុរសថយទៅអង្គុយក្បែរ ហើយរេភ្នែកសម្លឹងចូលទៅខាងក្នុងថ្នាក់ដែលងងឹតស្រពេចស្រពិលពឹងលើភាគរយខ្លះដែលបានពន្លឺដោយសារស្មៃព្រះចន្ទ្រារះ ជះចាំងមកដល់។

«នេះហ្អីថ្នាក់រៀន?»

គេសួរ ទាំងគិតជាស្រេចដល់ការសាងសាលាមួយសម្រាប់ផ្ទះអនាគតរបស់កូននាគ។

ស្រីតូចមិនឆ្លើយអ្វី បុរសនេះក៏ថាបន្តទៀត៖

«ហើយរាល់យប់មកគេងនៅហ្នឹង? គេងហិតក្លិនពួកឆៃថាវក្រៀមអស់ហ្នឹង!»

«ឆៃប៉ូវអត់ស្គាល់ឆៃប៉ូវទេអី?»

គេងៀងមើលនាងហើយលូកដៃទៅកាន់ដៃសាជាថ្មី។ នាងដកចេញយឺតៗហើយនិយាយតប៖

«បើគ្មានអ្នករបួស គ្មានអ្នកណាគេមកគេងនៅហ្នឹងទេ!»

បុរសញញឹម។

សេចក្ដីអំណររីករាយកើតមានមកកម្ដៅបេះដូងបានមួយគ្រា។ គេនិយាយលលេងបន្តទៀត៖

«ចុះបើអ្នករបួសនៅហ្នឹងរហូត?»

«ហើយមិនទៅដើរសមុទ្រវិញទេ?»

មនុស្សប្រុសមិនដែលដឹងទេថា ពាក្យលលេងរបស់ខ្លួនតែងតែធ្វើឱ្យមនុស្សស្រីទុកចិត្ត ហើយគេនិយាយស្រួលៗនៅពេលចិត្តរំភើបរាយមាយ តែគេភ្លេចវិញក៏ងាយដូចគ្នា ធ្វើឱ្យស្រីៗលើផែនដីនេះកើតទុក្ខឈឺចាប់ ព្រោះតែនៅចងចាំពាក្យពេជ្រផ្អែមល្ហែមមួយគ្រានៃពួកកន្លង់។

លើកនេះទៀតសោតLorenzoមិនដឹងថា តើខ្លួនឯងកំពុងធ្វើចិត្តកូននាគ រំភើបអាចនឹងគេងមិនលក់ព្រោះនឹកសម្ដីគេនោះទេ?

គេរឹតតែនិយាយលោនាង៖

«ម៉េចបានស្គាល់ឈ្មោះLorenzo!»

«បងធម៌ខ្ញុំប្រាប់! ហើយនែ៎ បងឯងត្រូវឆាប់ជា បើមិនបានជួបម្នាក់នោះទេ ខ្ញុំត្រូវឡើងទៅភ្នំពេញជួបគេ!»

គេសួរវិញទាំងអស់សំណើច៖

«ហើយទៅរកគេនៅឯណាភ្នំពេញធំយ៉ាងនេះ!»

នាងរអ៊ូ៖

«ទោះពិបាកក៏ត្រូវស៊ូដែរ! ខែប្រាំងជិតចូលមកដល់ហើយ! យើងត្រូវការអណ្តូងទឹក យើងត្រូវការទឹកមកប្រើ!»

Lorenឈោងកមុខគិត ។ សំឡេងនាងលាន់មកបន្ថែម៖

«ព្រឹកមិញមេឃជិតភ្លៀងកុំអីបានដើរទៅដល់កន្លែងសក្តិសិទ្ធិដើម្បីបន់ស្រន់ហើយ!»

«ក្រៅពីគេគ្មានអ្នកផ្សេងអាចជីកអណ្តូងឱ្យបានទេ?»

«មិនមែនងាយទេ! បើសុំពួកបរទេសយើងត្រូវពូកែសរសេរពាក្យសុំ! ហើយភាសាអង់គ្លេសសរបស់ខ្ញុំមិនចំណាប់ទេ! សុំខ្មែរដូចគ្នាងាយជាង!»

នាងស្រាប់តែសើចហើយងាកមកនិយាយរឿងផ្សេង៖

«បងឯងនៅតែលើសមុទ្រធ្វើកម្មករគេ អត់ចេះអង់គ្លេសទេមែនអត់? ស្អែកខ្ញុំបង្រៀនក្មេងៗ បងឯងចង់រៀនអត់?»

គេនៅស្ងៀមហើយញញឹមសម្លឹងកូននាគគួរឱ្យស្រលាញ់ នាងនិយាយបន្ទោសតិចៗទៅកាន់កែវភ្នែកផ្អែមល្ហែមរបស់គេ៖

«ស្អែកណ៎ា!!!រៀនអត់?»

«រៀនធ្វើអី?»

«រៀន!.....គឺ ចេះតែរៀនទៅ! អូមែន ចាំខ្ញុំបង្កើតFacebookឱ្យបងឯងមួយទុកឆាតលេងជាមួយគ្នា!»

គេនៅស្ងៀមព្រោះនឹកឃើញដល់រឿងនៅភ្នំពេញ។ ទឹកមុខប្រុសស្អាតប្រែមកជាស្រពោនបោះបង់ចោលមនោសញ្ចេតនាអណ្តែតអណ្តូងក្នុងកែវភ្នែកហើយនៅស្ងៀមឈឹង។

កូននាគតូចរបស់គេចាប់ផ្ដើមវាចាសួរ៖

«បងឯងដឹងពាក្យឆាតហ្នឹងមានន័យម៉េចអត់?»

Lorenzoដៀងភ្នែកមកវិញ ហើយនិយាយមួយៗដាក់នាង៖

«ជួយបងរឿងមួយបានអត់? បងចង់និយាយទូរសព្ទ!»

នាងឃើញគេក្រៀមក្រំ ស្រីតូចដឹងថារឿងដែលគេកំពុងស្នើសុំពិតជាចាំបាច់ណាស់ហើយ។ នាងមិនដឹងធ្វើយ៉ាងណានឹងរកឱ្យ ហើយក៏មិនដឹងថាបដិសេធការស្នើសុំដោយរបៀបណាទៀតដែរ ព្រោះព្រឹកមិញបានប្រាប់រួចហើយថាទីនេះមិនមានសេវា។

សំឡេងបុរសអាណិកជនវាចាមកបន្ថែមផ្ទួនលើចិត្តអន្ទះសារបស់នាង៖

«ទោះបីត្រូវចេញទៅផ្សារទៅខេត្ត ទៅទីប្រជុំជនណាក៏ដោយ បងចង់ទៅអាឡូវនេះ! បងទៅកើត!»

នាងក្រោកឈរហើយសម្លឹងគេ ធ្វើឱ្យនាយលូកដៃមកបង្វិលរាងកាយតូចចរណៃមកចំពីមុខដោយនិយាយពន្យល់៖

«រឿងចាំបាច់! បងត្រូវការខល! មិនអាចរង់ចាំស្អែកបានទេ!»

ស្រីតូចដកដង្ហើមធំពោលប្រាប់វិញ៖

«ទោះយើងប្រឹងជិះទៅដល់ផ្សារ គេបិទទ្វារគេងលក់អស់មិនខាន! ទូរសព្ទខ្ញុំអត់មានលុយគ្រប់វ៉េចេញទេ! មិនអ៊ីចឹង ពេលភ្លឺស្រាងៗខ្ញុំនាំបងឯងទៅ!»

«បងចង់ទៅពេលនេះ! គង់តែអាចរកឃើញអ្នកណាហើយយើងសុំទូរសព្ទគេប្រើបាន! ចុះអ្នកផ្ទះខ្លួនឯង គេមានទូរសព្ទអត់ ! ចង់និយាយថាប៉ាម៉ាក់អីហ្នឹងណ៎ា!»

នាងលែងមាត់ តែងាកទៅរកមើលម៉ូតូ។

បុរសដឹងថា គេអាចចេញទៅទីប្រជុំជនបាន ហើយចំណែកពេលថ្មើរណេះគ្មានអ្នកណាចូលមកម្ដុំនេះរកមើលពួកគេទេ។

ទីបំផុតនាងបានប្ដូរអាវចាស់ដែលដាច់ដៃម្ខាងរបស់គេនោះចេញ ហើយឱ្យអាវយឺតធំរលង់មានរូបគណបក្សនយោបាយគេពាក់។

«សំណាងហើយបងឯង! កាលពីគេចុះឃោសនាបោះឆ្នោតឃុំ ខ្ញុំបានអាវនេះពីរបីយកមកទុក ក្រែងមានអ្នកណាខ្វះអាវពាក់ខែវងា!»

«គិតវែងឆ្ងាយដូចមនុស្សចាស់!»

អ្នកមានដូចគេនេះ មិនដែលដឹងទេថាអ្នកក្រខ្វះមុខ ខ្វះក្រោយគិតបែបណាសន្សំសំចៃកម្រិតណាហើយរស់ដោយរបៀបណា?

ហើយនេះក៏ជារឿងដ៏គួរឱ្យភ្ញាក់ផ្អើលមួយទៀតដែរ ព្រោះគេមិនដែលគិតទុកមកទេថា មានថ្ងៃមកជិះ ម៉ូតូចាស់លាន់ម៉ាស៊ីនធំប្រេងកម្រិតនេះ ហើយជាមួយនារីម្នាក់នេះ ក្នុងចម្ងាយផ្លូវរាប់គីឡូនាពេលវេលាថ្មើរណេះ?

គេសួរខ្លួនឯង តើឯងជិះម៉ូតូចុងក្រោយបង្អស់កាលពីឆ្នាំណាទៅ? ត្រូវហើយនឹកមិនឃើញទេ! មិនដែលជិះទេ តាមថា! អូមែនហើយជិះចុងក្រោយកាលពីយប់មិញហ្នឹងឯង គឺជិះពីក្រោយនាងបានបន្តិច ក៏រលត់ស្មារតីសន្លប់ឈឹងបាត់ព្រោះតែការឡើងកម្ដៅ។

«អ្ហ៎ !»

គេហៅនាងឮៗ ព្រោះនាងពាក់មួក គេក៏ពាក់មួកម៉ូតូដ៏ធំហើយធ្ងន់។

«មានការអី?»

គេដោះមួកមកកាន់ហើយនិយាយៈ

«ប៉ុនម៉េះ? យប់មិញឱបមនុស្សសន្លប់មួយបាន? ផ្លូវមហារលាក់?»

«បងឯងត្រូវដឹងគុណខ្ញុំហើយអ៊ីចឹង!»

នាងនិយាយកំប្លែងតែចិត្តនាយចាប់អាណោចអនេក។

ចេញពីផ្ទះអនាគតមកគេមិនដែលគិតថានឹងមានថ្ងៃព្រមវិលទៅផ្ទះអនាគតវិញជាដាច់ខាត គេនឹងទាក់ទងជំនួយការព្រមទាំងរកវិធីចេញទៅរកទីសុវត្ថិភាពជាមួយពួកគេវិញ។

«រីករាយណាស់ដែលបានស្គាល់កូននាគតូច!»

គេគិតស្ងាត់ៗក្នុងចិត្ត ទាំងញញឹមលាយក្ដីអាឡោះ។ ស្រាប់តែ នាងនិយាយទៀតៈ

«ខ្ញុំមិនទារគុណអីទាំងអស់ ព្រោះបងឯងក៏អ្នកអត់ខ្ញុំដឹងហើយ មិនបាច់អង្គុយពិបាកចិត្តទេ!»

ដោយសារនាងខំនិយាយប្រណាំងកម្លាំងខ្យល់ទើបសំឡេងនាងខ្លាំងៗហើយស្រួយស្រីប។

សរសៃសក់នាងប៉ោងមកតាមខ្យល់ប៉ះនាសានាយក្រអូបក្លិនក្រូចប្រហើរៗមិនដែលមានអារម្មណ៍ធម្មជាតិបែបនេះពីមុនមកឡើយ។

«បានអីមកលាបសក់ក្រអូបម្ល៉េះកូននាគ?»

«ព្រឹកមិញទៅព្រៃបងឯងមិនឃើញខ្ញុំបេះស្លឹកក្រូចសើចទេ?»

«អាចធ្វើជាសាប៊ូ?»

«បាន! អ្នកណាថាមិនបាន?»

«ហើយចុះមានច្រើនអត់ដើមក្រូចអស់ហ្នឹង!»

«ច្រើនណាស់បងឯងមិនសម្គាល់មើល?»

«អ៊ីចឹងមិនបើករោងចក្រធ្វើសាប៊ូមួយហ្មងទៅ! ឱ្យអ្នកព្រៃភ្នំទាំងអស់បានការងារធ្វើផង នឹងអាលឈប់ញ៉ាំអាឆែថាវ ធុំក្លិនអាក្រក់អស់ទាំងហ្នឹង?»

«ប្រាប់ហើយថាឆែប៉ូវ!»

«ដូចតែគ្នាហ្នឹងហៅអាម៉េចក៏វាដូចតែគ្នា!»

«ឆែថាវញ៉ាំឆៅមិនបានទេ! តែឆែប៉ូវញ៉ាំបាន!»

«ឈប់និយាយទៅតិចបងដូរឈ្មោះខ្លួនឯងមកជាកញ្ញាឆែថាវអាឡូវហ្នឹងហើយ!»

នាងបិទមាត់។ គេដឹងហើយថា នាងចូលចិត្តឈ្មោះ«កូននាគ»តែមិនចង់បាននាមកញ្ញាឆៃថាវទេ។ គេនិយាយបន្តប់ទៅរឿងដដែលៈ

«ឮបងនិយាយអត់? បើករោងចក្រធ្វើសាប៊ូមួយហ្មងទៅ! ឱ្យអ្នកព្រៃភ្នំទាំងអស់បានការងារធ្វើផង!»

«ហ្នឹងហើយ! បងឯងនិយាយធ្វើមើលតែខ្លួនឯងជាអ្នករកស៊ី!»

គេដល់ពេលស្ងាត់មាត់ទៀតហើយ។ ឱ្យតែត្រូវនាងរំលឹកដល់សមាសភាពរបស់គេម្តងៗ ភាពប្រឆាំងគ្នារវាងLorenzoនិងកម្មករនេសាទ ចេះតែបង្ខំគេឱ្យក្រៀមក្រំ។ កើតមកជាកម្មករនេសាទក៏មិនមែនថាមិនល្អទាំងស្រុងដែរ ហោចណាស់មានស្រីម្នាក់ថៃទាំយើងអត់ដេកពួនពេញមួយយប់។ ចំណែកLorenzoបានត្រឹមតែសម្រាប់ឱ្យគេសុំអណ្តូងទឹកប៉ុណ្ណឹងឬអ្វី?

នេះហើយជាមូលហេតុដែលគេមិនដែលរកបានម្ចាស់ចិត្តណាម្នាក់ឱ្យពិតប្រាកដតាំងពីអាមេរិករហូតដល់ស្រុកខ្មែរ។ ស្រីៗផ្តើលចង់ជួបទេវបុត្រLorenzo ព្រោះតែភាពសប្បុរសនិងធនធានមហាសាលរបស់គេ?

«ចាំរួចរាល់ហើយ បងឯងត្រូវរៀនលេងឆាត! ហើយឆាតមកខ្ញុំ! ខ្ញុំខានទៅសមុទ្រជិត៥ឆ្នាំហើយ ខេត្តកោះកុងនៅជិតបង្កើយខ្ញុំមិនដែលបានឃើញសមុទ្រសោះ នឹកណាស់!»

ឮហើយ គេពិតជាចង់អោបចង្កេះកូននាគតូចរត់ប្រដេញគ្នាលើឆ្នេរ ឬក៏យប់អធ្រាត្រឡើងកាលណាបណ្តើរគ្នាទៅរកមើលពពុះសមុទ្រដូចគូស្នេហ៍ក្នុងរឿងនិទានអាស៊ីល្បីៗដែលគេធ្លាប់អាននិងបឋមវ័យ។

សេចក្តីស្រមៃ ផ្អែមល្ហែមក៏គង់អាចរំភើបចិត្តធ្វើឱ្យបេះដូងកើតក្តីកក់ក្តៅភ្លាមៗបានមែន នេះជាសុភមង្គល ដ៏ធំក្នុងជីវិតមនុស្សរាល់គ្នា។ ប៉ុន្តែវិលមកវិញ វាបានត្រឹមតែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ ព្រោះគ្រប់យ៉ាងវាមិនអាចកើតឡើងបានទេ។

មិនយូរប៉ុន្មានយើងនឹងបែកគ្នា កូននាគអើយ! យើងនឹងវិលទៅតាមទីតាំងប្រភពដើមរៀងៗគ្នា ។នាងនឹងភ្លេចបងកម្មករម្នាក់នេះ ដូចដែលយើង ក៏មានកាតព្វកិច្ច និងវិបត្តិជាច្រើនទៀតដែលត្រូវផ្ចង់ចិត្តដោះស្រាយ។

«បងឯងនៅស្ងៀម? គេងលក់?»

ដៃនាយឈោងមកក្រសោបចង្កេះនាងភ្លាម ធ្វើឱ្យតូចស្រីផ្អើលសឹងរបូតម៉ូតូដួលធ្លាក់ផ្លូវរទេះទាំងអស់គ្នា។

បរិយាកាសរឹតតែស្ងាត់។ គេដឹងថានាងចង់ឱ្យគេដកដៃចេញ តែចិត្តគេនៅតែពន្យារតាមបញ្ជាបេះដូង។ រ យៈពេលាម្ភៃម៉ោងមកនេះ គេភ្លាត់មកឆ្ងាយ ជួបអ្នកណាក៏អត់ នៅជិតដិតនឹងស្រីតូចតែម្នាក់។

ពេលវេលាដដែល អ្នកត្រៀមនឹងចាកចេញទៅ ហេតុអីចិត្តនៅបង្កប់ក្ដីស្រណោះស្មើនឹងមនុស្សមាននិស្ស័យជាមួយគ្នារយជាតិមកហើយ?

គេនិយាយតិចៗដោយផ្ទឹបមុខទៅលើសក់នាងហើយខ្សឹបដាក់ត្រចៀកនាង៖

«ថ្ងៃក្រោយ! ឈប់ទៅនៅឆ្ងាយរបៀបនេះទៅ! ផ្ទះអនាគតនោះ វាឆ្ងាយ វាជ្រៅពេកហើយ! ខ្លួនធំហើយត្រូវនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្ដាយ!»

«ខ្ញុំអត់មានពុកម៉ែទេ!»

នាងទំនងជាស្ថិតក្នុងអារម្មណ៍ជិតស្និទ្ធនឹងកក់ក្ដៅដូចគ្នាបានជាមិនខឹងពេលត្រូវគេអោបពីក្រោយហើយចាប់ផ្ដើមសារភាពស្ថានភាពគ្រួសារ។ ដៃនាយស្រយុត។

អារម្មណ៍ជាក្មេងកំព្រាដែលត្រូវឪពុកម្ដាយបោះបង់ចោលនៅកណ្ដាលប្រទេសមហាអំណាចព្រោះញៀនល្បែងគ្មានលទ្ធភាពចិញ្ចឹម ជាអារម្មណ៍ដែលយល់ថាគ្មានអ្នកណាដូចខ្លួនទេនៅលើលោកនេះស្រាប់តែពេលនេះមកជួបមនុស្សម្នាក់ដែលនិយាយពីរឿងកំព្រីកំព្រាចេញមកបានដោយអារម្មណ៍ធម្មតាគ្មានខ្វល់ខ្វាយអ្វី?

តទៅនាងរស់ដោយរបៀបនេះរហូតឬអ្វីកូននាគព្រាត់មេឃ?

តាមថានាយត្រូវរបូតដៃចេញ តែបែរជាម្ដងណេះ អោបនាងណែនជាងមុន។

«ខ្ញុំជាក្មេងមណ្ឌល! ខ្ញុំធំឡើងក៏ចេញមកហើយត្រៀមរៀបចំមណ្ឌលខ្លួនឯង! ខ្ញុំមានតាចិញ្ចឹមតែគាត់ខូចបាត់ហើយ! ដីព្រៃនោះជាមរតកគាត់ផ្ទេរឱ្យខ្ញុំ ខ្ញុំទុកកសាងជាសាលារៀនសម្រាប់ក្មេងៗកូនអ្នករស់នៅក្នុងព្រៃ! ពួកវាមិនអាចទៅរៀននៅសាលាឆ្ងាយៗបានទេ!»

នេះឬសេចក្តីប្រាថ្នារបស់នាង?

«ប្រវត្តិគ្រួសារខ្លួនឯងនៅឯណា! ចាំបងជួយរកឱ្យ!»

«មិនដឹង! អ្នកស្រុកថាខ្ញុំប្រហែលជាកូនអ្នកភ្នំពេញដែលគេយកមកផ្តុងចោល! ចាស់ៗតំណាល យប់មួយមានឡានមួយបោលលឿនណាស់ គេឈប់បន្តិចហើយក៏ចេញទៅ! មិនបានប៉ុន្មានអ្នកស្រុកឮសូរទារកយំ ក្មេងនោះគឺខ្ញុំហ្នឹងហើយ! ចាស់ៗថាខ្ញុំមកដល់ទីនេះ ខ្ញុំឈឺសល់តែស្បែក ប្រហែលមកពីខ្ញុំឈឺ បានជាគ្រួសារនោះគេមិនចង់ចំណាយពេលមកមើលខ្ញុំ! ចាស់ស្រុកម្តុំនេះយកខ្ញុំទៅលើភ្នំឱ្យគ្រូបុរាណមើលថៃទាំ ខ្ញុំក៏បានរស់នៅទីនោះបន្តជីវិត សុំទឹកដោះម្នាក់នេះផង ម្នាក់នោះផង គ្រាន់នឹងបៅ! អាយុបាន៨ឆ្នាំល្មមឱ្យខ្ញុំចាំឱសថបុរាណទាំងអស់បានខ្ទេច! ពេលនេះខ្ញុំមានអីមិនល្អ! ចាំបាច់អីត្រូវការគ្រួសារមួយដែលគេមិនត្រូវការខ្ញុំ!»

បុរសកាន់តែអោបនាងណែន ព្រោះសេចក្តីអាណិតស្រលាញ់។

**វគ្គ ស្នូចត្រីនាគ**

ពន្លឺព្រះអាទិត្យព្រឹមៗនាវេលាម៉ោង៦ព្រឹកចោលរស្មីស្រទន់ស្រអាប់ ពីលើផ្ទឹមដែលមានសណ្ឋានរាបស្មើលំអដំបូលផ្ទះបាយចាស់ដ៏ធំទូលាយមួយ។ នេះជាប្រភេទផ្ទះបាយដែលគេសង់នៅក្រោយវិឡាធំ ឃ្លាតគ្នាប្រមាណជា៥ម៉ែត្រប៉ុណ្ណោះ។

ដោយសារទ្វារផ្ទះខាងមុខមិនអាចចូលបានដូច្នេះប៉ូលិសចូលនិវត្តន៍បានបន្តដំណើររហូតមកដល់ទីនេះ ក្រែងឃើញអ្នកណាម្នាក់នឹងអាចសួរដំណឹងបាន។

«មានអ្នកណានៅទេ?»

វិទូពោលសួរពីក្រៅ ចំណែកភណ្ឌាដែលដើរពីក្រោយ គេនៅតែរក្សាការប្រុងប្រយ័ត្នហើយត្រួតពិនិត្យជុំវិញបរិវេណនេះ។

គេដកដង្ហើមយូរពេលឃើញអ្នកណាម្នាក់បង្ហាញខ្លួននៅក្បែរបង្អួចក្រាស់ៗក្នុងវិទ្យាទល់មុខនឹងផ្ទះបាយមួយនេះ។

«វិទូ! នៅខាងក្នុងវិទ្យាវិញ!»

សម្ដីមិត្តធ្វើឱ្យអតីតឧត្តមសេនីយ៍ងាកក្រោយសម្លឹងទៅក្នុងផ្ទះដែលនៅខាងមុខទ្វារជាប់សោ តែនៅខាងក្រោយនេះអាចចូលបានដោយទ្វារម្ខាងបើកចំហចាំ។

ចលនានៃល្អងធូលីនិងកម្ទេចស្លឹកឈើលំអងផ្កាក្រៀម អណ្ដែតតាមកាំពន្លឺថ្ងៃ ធ្វើឱ្យវិទូគិតពីស្ថានភាពអ្នកដែររស់នៅក្នុងនេះ ។

ផ្ទះដែលគ្មានផាសុកភាពនេះបានរំឭកប្រាប់ថា វាទំនងជាគ្មានអ្នកនៅយូរមកហើយ។

«ចេញមកសុខា!»

គេស្រែកហៅតិចៗ។ ភណ្ឌងាកមកក៏ដឹងថា មិត្តខ្លួនមានការប្រុងប្រយ័ត្ន មិនព្រមចូលទៅកន្លែងបែបនេះងាយៗឡើយ។ ចិត្តគេក៏គិតរបៀបនេះដូចគ្នា។

«ត្រូវហើយ ចេញមកនិយាយគ្នាខាងក្រៅមក!»

ស្ងាត់ច្រៀបគ្មានសូម្បីតែសំឡេងឆ្កែឆ្មាមួយ។

«ខ្ញុំឃើញមនុស្សនៅក្នុងមិញ!»

ភ័ណ្ឌដើរមកក្បែរហើយនិយាយខ្សឹបៗប្រាប់មិត្តសម្លាញ់ ធ្វើឱ្យវិទូខំផ្ទៀងត្រចៀកស្ដាប់រកសំរិបជើងនិងដង្ហើមមនុស្សក៏ដូចជារំពៃរកមើលដោយកែវភ្នែកមុតថ្លារបស់គេ។

គេប្ដូរថយពីទ្វារផ្ទះ មកសម្លឹងតាមបង្អួចដែលគ្របដណ្ដប់ទៅដោយ ស្រទាប់ធូលីស្ដើង។ វាជាបង្អួចកញ្ចក់។ ដូច្នេះភ័ណ្ឌដកយកក្រដាសជូតមាត់ពីហោប៉ៅមកភ្លាមព្រមទាំងជូតឱ្យថ្លាឡើងវិញ។

«ចេញមកសុខា! ខ្ញុំណាខ្ញុំមកតែពីរនាក់ទេ! អត់មានអ្នកណាមកតាមទាំងអស់ មិនបាច់ភ័យទេ!»

ភាគទី៤៦

អតីតប៉ូលិស ក្រឡេកទៅមើលធុងសំរាមដ៏ធំមួយនៅជ្រុងម្ខាងជាមួយនឹងកាកសំណល់ស្រស់ៗ ថ្មីហូរហៀរជាទីខ្ពើមរអើម។

«ផ្ទះនេះមាននមនុស្សនៅ ហើយច្រើនគ្នាទៀត!»

គេគិត ហើយងាកមករកទ្វារចូលសាជាថ្មីទាំងនិយាយ៖

«ចេញមក!»

សូរសំឡេងព្រូសប្រះលាន់មកពីខាងក្នុងបន្ទាប់មកសូរគ្រាំងដូចអ្វីមួយត្រូវរលំយ៉ាងដំណំ។ វិទូងាកមករកភណ្ឌ។ ទាំងពីរនាក់ឈានថែមមួយជំហានទៀតតម្រង់មករកច្រកចូលទាំងចិត្តសន្ទុតភ្លាមៗថា ធ្វើអ្វីមួយបាននឹងកំពុងកើតឡើង។

ពីទីនេះទៅក្នុងផ្ទះ ទាំងពីរកាយ អាចសម្លឹងផ្តោតទៅឃើញកម្រាលព្រំកខ្វក់គ្មានការសំអាត និងគ្រឿងសង្ហារិមខ្លះ បែកបាក់ដួលរលំដូចជាទើបនឹងមានអ្នកណាច្រានអម្បាញ់មិញ។

«ល្បិចស្អីមួយមិនខាន»

ភណ្ឌខ្សឹបៗតែវិទូនៅតែអន្ទះសានិយាយ៖

«គេមានភស្តុតាងអាចជួយក្មួយខ្ញុំ!»

«អ៊ីចឹងគេប្រហែលជួបគ្រោះថ្នាក់មុនយើងមកដល់!»

វិទូយល់ស្របលើការគិតនេះ។ ពួកគេមើលមុខគ្នាមុនពេលនិយាយព្រមគ្នា៖

«ចូលទៅមើល!»

កម្រាលព្រំលាតសន្ធឹងតាំងពីមាត់ទ្វារក្រោយនេះចូលទៅខាងក្នុងឆ្ពោះទៅបង្ហាញបន្ទប់ទទួលភ្ញៀវធំទូលាយ និងគ្រឿងសង្ហារិមនៅសេសសល់ដោយអន្លើ។

កំប៉ុងទឹកក្រូចនិងប៊ីយែរ ទុកចោលរប៉ាត់តាមធ្មើរបង្អួចនិងលើទូតាំង។

«សុខា?»

វិទូព្យាយាមហៅ ឮតែសំឡេងខ្លួនឯងលាន់មកវិញ។

ទាំងពីរកាយ បែងចែកទិសដៅរវេវន្អែកផ្ទង់អារម្មណ៍ពិនិត្យយ៉ាងល្អិតល្អន់ដោយផ្ដោតចាប់ពីទីខាងក្រោមរហូតដល់ជាន់ខាងលើ។ ទោះជាយ៉ាងណា អំពូលភ្លើងចំកណ្ដាលពិតានធំដែលមានរាងខូងដូចពិតានប្រាសាទជះរស្មីភ្លឺចិញ្ចាច។ អ្នកណាម្នាក់កំពុងស្នាក់នៅផ្ទះនេះហើយបានបើកភ្លើង។

ភណ្ឌាលូកដៃទៅស្ទាបកែវកាហ្វេStarbucksដែលនៅក្ដៅឧណ្ហៗក្នុងស្រោមនៅឡើយ។ បន្ទាប់មកពួកគេរកឃើញ កែវកាហ្វេជាច្រើនទៀតនៅកន្លែងផ្សេងៗគ្នា ខ្លះនៅសល់ទឹកកក ខ្លះនៅសល់កម្ដៅ។ ចុះម្ចាស់កាហ្វេនាំគ្នាបាត់ទៅណា? គេទាំងពីរដឹងថាអ្វីមួយមិនប្រក្រតីបានកើតឡើងមុនពេលពួកគេមកដល់បន្តិច។

«យើងរកសុខាឱ្យឃើញ!»

វិទូនិយាយទាំងអន្ទះសារហើយឈានតម្រង់ខឿនជណ្ដើរឆ្ពោះទៅកាន់ជាន់ទីមួយ តែជើងគេឈប់ង៉ក់គាំងចលនា។

«ភណ្ឌា!»

វិទូហៅមួយម៉ាត់គត់ធ្វើឱ្យសម្លាញ់រត់មកដល់។ ពួកគេនៅទ្រឹងជាមួយគ្នាសម្លឹងខ្សែលោហិតក្រហមខាប់ ហូរជាខ្សែបង្អួសចុះមកពីលើជណ្ដើរឈើបេងពណ៌លឿងទុំរលោងស្រិល។

«សុខា!» គេហៅសាជាថ្មីទាំងតក់ស្លុតហើយស្ទុះបម្រុងឡើងទៅ ប៉ុន្តែភណ្ឌាទាញស្មាគេឃាត់វិញ។

អតីតប៉ូលិសនេះ ប្រើកែវភ្នែកជំនួសសម្ដី ក្នុងការហាមប្រាមវិទូ មិនឱ្យឡើងទៅ។

ពេលភ្លើងងាកមកសម្លឹងមុខគេទាំងរន្ធត់ ភណ្ឌានិយាយបន្ថែម៖

«យើងហៅប៉ូលិស!»

គេឈ្ងោករកទូរសព្ទ វិទូទាញដៃគេឃាត់ហើយនិយាយខ្សឹបៗយ៉ាងអន្ទះសា៖

«សុខា មានភស្តុតាងថា ពីអ្នកដែលជួលពួកគេឱ្យចាប់ស្រីៗទាំងអស់នោះ! ខ្ញុំដឹងថា អ្នកធ្វើរឿងនោះអាចជាពួកប៉ូលិស! យើងត្រូវរកឱ្យឃើញវត្ថុតាងអស់នោះ មុនប៉ូលិសមកដល់!»

ភណ្ឌាគ្រវីក្បាលយ៉ាងញាប់ហើយទាញវិទូឃាត់វិញ៖

«អាណាម្នាក់បានមកដល់មុនយើងហើយសំឡេះពួកនេះ! បើមានភស្តុតាងមែន វាយកទៅបាត់ហើយ! យើងត្រូវហៅប៉ូលិស!»

វិទូនៅទ្រឹង សម្លឹងមិត្ត។ កែវភ្នែកគេបង្ហាញនូវសម្ពាធដ៏ធំដែលត្រូវបង្ខំឱ្យគេសម្រេចចិត្តជាបន្ទាន់។

គេរលាស់ដៃភណ្ឌាចេញហើយនិយាយ៖

«ប្រាកដជានៅសល់អ្វីម្យ៉ាង!»

សំឡេងព្រូសប្រុះលាន់មកពីខាង ធ្វើឱ្យអ្នកនៅក្រោមទាំងពីរនាក់បើកភ្នែកក្រឡោតងើយទៅសម្លឹងរកប្រភពនៃសំឡេង។ រហ័សដូចផ្លេកបន្ទោរវិទូរត់រំលងខ្សែលោហិត ឆ្ពោះទៅជាន់ខាងលើ ធ្វើឱ្យភណ្ឌាស្រលាំងកាំង មុនពេលដើរមួយៗឡើងទៅតាម។

បន្ទប់ខាងលើ នៅធំក្លិនឆ្អៀមដោយផ្សែងរំសេវ ហើយងងឹតគ្មានភ្លើងបើកទេ។

ក្នុងភាពអន្ធះសាជើងគេជាន់អ្វីមួយហើយភ្លាត់ជំហរដួលស្រុបទៅប្រឈមនឹងអ្វី ដែលប្រាកដណាស់ប៉ូលិសចូលនិវត្តន៍ម្នាក់នេះ ដឹងច្បាស់ណាស់ថា «មនុស្សដេកស្ងៀម» ។

វិទូស្រែកអស់មួយទំហឹងស្មើនឹងក្តីរន្ធត់របស់គាត់។

«សុខា?»

គេអង្រួនរាងកាយស្គូកស្គឹង ចំណែកភណ្ឌាព្យាយាមស្វែងរកក្រែងឃើញសាកសពផ្សេងទៀត។

សាកសពនៅក្តៅ ហើយដៃនៅក្តាប់ជាប់ចូលគ្នា។ អក្សរប្រឡាក់ឈាមពីរបីសរសេរនៅលើកម្រាលព្រំស្រអាប់ ធ្វើឱ្យគេចំត្រដរវែកមើល។

«ដេវីដ?»

ភណ្ឌាងាកមកហើយចាប់ផ្តើមចតទាំងមាត់និយាយឆ្ងល់៖

«បងសុខាសរសេរឈ្មោះអ្នកដែលសម្លាប់គាត់?»

ទឹកភ្នែកប៉ូលិសចូលនិវត្តន៍ស្រក់ជូនដំណើរអតីតអ្នកធ្លាប់កៀកស្មាជាមួយគ្នា។

បុរសនេះជាមនុស្សមានជំនឿទុកចិត្តលើខ្លួនឯងខ្ពស់ តែគាត់បានចាកចេញពីវិស័យនេះយូរហើយ គាត់មិនដែលសូម្បីតែនឹកស្មានថា នៅកណ្តាលក្រុងធំ មានការសម្លាប់ស្រស់ៗ ដល់ម្លឹងហើយនៅចំពោះមុខកែវភ្នែកខ្លួនទៀត។

ភណ្ឌាឃើញវិទូទន់ជើងចុះអង្គុយផ្ទាល់ព្រំ ក្បែរមនុស្សមានតួចស្គមដែលដេកក្នុងថ្លុកឈាម។

«សុខា! ដឹងខ្លួនឡើង! សុខា!»

ភណ្ឌាឈរឆ្ពឹងអត់ធ្មត់ ទ្រាំសម្លឹងភាពសោកសៅមិនចេញសំឡេងយំរបស់អតីតឧត្តមសេនីយ៍ព្រហ្មទណ្ឌដ៏មានស្នាដៃ។ បានមួយខណៈគេដាច់ចិត្តនិយាយតិចៗ៖

«គេស្លាប់ហើយ!»

វិទូភ្ញាក់ខ្លួនពីវិយោគ។ គេងើបមុខសម្លឹងជុំវិញខ្លួន ភណ្ឌាក៏ស្ទុះទៅជួយរុករកដូចគ្នា។ ពួកគេជាប៉ូលិសជំនាញ គេដឹងច្បាស់ថា មនុស្សដែលគេបានឃើញមួយកន្ទុយភ្នែក កាលពីពេលចូលមកដល់ផ្ទះនេះដំបូង គឺឃាតករដែលទើបនឹងបណ្តោះខ្លួនចេញ។

«សុខាប្រាប់ថា អ្នកដែលចាញ់បោកមនុស្សឈ្មោះដេវីដ មានហោចណាស់ក៏ពី១២ទៅ១៥នាក់ដែរ»

វិទូងាកខ្សឹបប្រាប់ភណ្ឌាធ្វើឱ្យប៉ូលិសម្នាក់នេះកាន់តែវិលវល់ឈរស្តុបកណ្តាលចំណោមថ្លុកឈាម។

អ្នកទាំងពីរដឹងដូចគ្នាថា ថេរវេលាដ៏ប្រថុចញ៉ុចនេះ ជនដៃដល់មិនអាចសំអាតដានអស់ទេ។

វាប្រាកដជាមានសេសសល់អ្វីមិនខាន។ ឧត្តមសេនីយ៍ចូលនិវត្តន៍លូកដៃបិទភ្នែកឱ្យមិត្តឈ្មោះសុខាហើយក្រោកឈរទាំងបេះដូងឈឺផៀប។

គេប្រុងឈានទៅមុខ ឆ្ពោះទៅកាន់វត្ថុអ្វីមួយ ប៉ុន្តែស្នូរឡាននៅខាងក្រៅផ្ទះធ្វើឱ្យជំហានគេគាំង។

ប៉ូលិសក្នុងឯកសណ្ឋានទាំងក្រុមរត់ចូលមកដល់ ជាមួយអាវុធគ្រប់ដៃ ដូចជាបានត្រៀមលក្ខណៈរួចរាល់សម្រាប់ប្រយុទ្ធ។

វិទូនិងភណ្ឌាឈរស្ងៀមទាំងគ្មានអាវុធក្នុងដៃ ហើយសម្លឹងពួកគេពីជាន់ខាងលើមក.....

ភណ្ឌានឹកឃើញរឿងសំខាន់មួយគេសួរវិញ៖

«បើថាមានច្រើនគ្នាអ្នកផ្សេងទៀតនៅឯណា? វរហើយ! គេសម្លាប់ម្នាក់ហើយចង់ទម្លាក់បន្ទុកមកលើយើង?»

មនុស្សដែលមានការប្រុងប្រយ័ត្នខ្ពស់ ដូចពួកគេនៅតែមិនបានយកចិត្តទុកដាក់ទេថា ស្ថានភាពកំពុងតែប្រែប្រួលឈានទៅរកភាពអវិជ្ជមាន។

មនុស្សស្វាហាប់ម្នាក់ញែកកាត់កណ្ដាលក្រុមប៉ូលិស ហើយដើរបណ្ដើរងើយមកមើលជាន់ខាងលើបណ្ដើរ។

នោះគឺឧត្តមសេនីយ៍ឌិត សាម៉ុន ដែលអ្នកទាំងពីរខានជួបមុខច្រើនខែមកហើយ។

បុរសចំណាស់នៅភាំងពីមុខជណ្ដើរ ពេលឃើញខ្សែលោហិតដែលប្រែទៅជាកកបណ្ដើរៗ ហើយបន្ទាប់មកគាត់ងៀងភ្នែកមករកស្នាមដានជើងរបស់ប៉ូលិសទាំងពីរដែលនៅសេសសល់។

ឌិត សាម៉ុនមិនងើបមុខសម្លឹងជាន់ខាងលើទៀតទេ តែគាត់ស្រែកបញ្ជា៖

«ទាំងអស់គ្នា! បិទទីកើតហេតុ ឃាត់មនុស្សទាំងអស់នៅទីនេះមិនឱ្យរួចម្នាក់! ហៅពេទ្យកោសល្យវិច្ច័យមក!»

គ្មានអ្នកណាអាចប្រាប់បានទេថា ហេតុការណ៍ដ៏ឆាប់រហ័សនេះ វាកើតឡើងដោយរបៀបណា ហើយវាមានន័យយ៉ាងម៉េច?

ភណ្ឌាចុះពីជណ្ដើរមកយឺតៗហើយនិយាយទៅកាន់ឧត្តមសេនីយ៍៖

«បង! ពួកខ្ញុំមកដល់យឺត! ហេតុការណ៍កើតឡើងមុននេះប្រហែលជាម្ភៃនាទី! គឺមុនពេលពួកខ្ញុំចូលមកដល់! កាហ្វេពួកគេនៅក្ដៅនៅឡើយ!»

ឱិត សាម៉ុនសម្លឹងឯកសណ្ឋានស៊ីវិលលើខ្លួនម្នាក់នេះ ទោះគាត់មិនដឹងថាគេមកពីនាយកដ្ឋានណាប៉ុន្តែសម្ដីសំដៅគេ បញ្ជាក់ថាគេក៏ជាប៉ូលិស។

គាត់និយាយតបស្មើធេង៖

«ចាំទុកចម្លើយបងឯង ឆ្លើយប្រាប់អ្នកកត់ត្រាទៅ!»

គាត់ងាកក្រោយហើយស្រែកបញ្ជា៖

«ចាប់អ្នកទាំងពីរហើយឆែកខ្លួន!»

ភណ្ឌាបើកភ្នែកធំជាងមុន ព្រោះភ្ញាក់ផ្អើល។ ឱិត សាម៉ុនធ្វើមុខមាំ មិនសម្លឹងគេទៀត តែគាត់បង្ហួសដំណើរមកជាន់ខាងលើ។

«ឧត្តមសេនីយ៍! លើកនេះលោកធ្ងន់ខ្លួនហើយ!»

វិទូសម្លឹងបុរសនេះដោយកែវភ្នែកនឹងន។ ទម្លាប់របស់គេកាលនៅជានាយប៉ូលិសនិងក្លាយមកជាអ្នកជាប់សង្ស័យគឺនៅតែដដែលគ្មានអ្វីប្រែប្រួលផ្លាស់ប្ដូរ។ ពូរបស់ចិត្រានិយាយមួយៗកណ្ដាលការរត់ស្រចូលមករបស់ក្រុមប៉ូលិសជាច្រើនទៀត៖

«ខ្ញុំមិនបានធ្វើអីខុសទាំងអស់!»

វគ្គ ឆាកបង្ហើយធំៗ

ការផឹកស្រាមិនដែលជាជម្រើសសម្រាប់ពួកប៉ូលិសដែលមានសមត្ថភាពនិងមានស្មារតីទទួលខុសត្រូវនោះទេ ក្នុងកំឡុងពេលដោះស្រាយរឿងក្ដី។

យប់នេះ ស្នងការ Roy បង្ហាញខ្លួនម្នាក់ឯងក្នុងNight Club My Honey គឺជាការបង្ហាញខ្លួនដ៏កម្រមួយ។ បុរសនេះផឹកស្រាម្នាក់ឯង គ្មានអ្នកcheer ក៏ប៉ុន្តែផឹកមិនឈប់ដល់ថ្នាក់អ្នកចាក់ស្រាចង់ភ័យ។

«បងRoyមានរឿងអី? ខូចចិត្តហ្អែន?»

អ្នកចាក់ស្រាឈ្មោះពៅ លាន់មាត់សួរ ទាំងមុខស្លេកព្រោះថាស្ថានភាពគេអាចបញ្ជាក់ប្រាប់អ្នកស្និទ្ធស្នាលទាំងឡាយថា គេកំពុងស្ថិតក្នុងដំណាក់កាល«Sadដល់កម្រិតចុងក្រោយ»។

«ស្នងការRoyងាយឯណាឱ្យគេធ្វើបាបបាន?»

នាងមកដល់ហើយ។ ចុងកន្ទុយភ្នែករបស់ Roy បញ្ចេញនូវស្នាមញញឹមសម្ងាត់ពេលឮសំឡេងឌឺដងដៀមដាមរបស់ស្រីម្នាក់នេះ។

នារីសិចស៊ី Rose យប់នេះនាងស្លៀករ៉ឺបរាងពណ៌ស ដែលជារ៉ូប Nightclub មានតម្លៃខ្ពស់ Roy ធ្លាប់ឃើញតែស្រីៗអភិជននៅ London គេពាក់វាជិះរថយន្តតម្លៃលានផោន។ «ពីណាថាស្នងការRoyខូចចិត្ត!»

គេខំលាក់បាំងនិងក្លែងបន្លំភាពស្រវឹងជោក ហើយងាកមកលើកដៃមនុស្សជាច្រើនកំពុងសប្បាយក្អាកក្អាយនៅក្រោមភ្លឹងពណ៌ដ៏មហស្ចារ្យរួមជាមួយនឹងសូរសំឡេងលាន់រណ្ដំរងំនៃបទភ្លេងឡូក្នុងក្លឹបនេះ តែចម្លែកកន្លែងដែល Roy អង្គុយគ្មានអ្នកណាមកជិតទេ។

«អូខេ! លោកព្រមទទួលស្គាល់ថាខ្លួនឯងអត់មានអ្នករាប់? អ៊ីចឹងខ្ញុំធ្វើចិត្តល្អអង្គុយក្បែរលោកចុះ!»

គេជាបុរសម្នាក់ មានបេះដូងដូចមនុស្សប្រុសគ្រប់គ្នា។ មានស្រីស្អាតម្នាក់មកអង្គុយក្បែរពេលកំពុងផឹកម្នាក់ឯងជាសុភមង្គលលមហាសែនមួយ។

Roy ងាកមើលទៅនារីនេះជាមួយស្នាមញញឹមពីលើផ្ទៃមុខស្រវឹងដូចងងើកភ្លើង។ នាងញញឹមស្រស់បង្ហួតស្នាមក្រែមក្រហមខ្មៅក្រាស់ឃ្មឹក ប៉ុន្តែពុំមែនមកកាន់នាយទេ គឺមកកាន់អ្នកចាក់ស្រា។

«ចាក់ស្រាឱ្យបង!»

នាងមិនបាច់ប្រាប់ថាស្រាអ្វីទេ តែអ្នកនោះងាកទៅចាក់ភ្លាម បានន័យថាពួកគេស្គាល់គ្នាពីមុនមក។ ក៏ម្នាក់ដដែលនេះទេដឹង ដែលបានខលប្រាប់នាងអំពីវត្តមានខ្លួនដែលកំពុងផឹកស្រាយលិចថ្លើមធ្វើឱ្យនាងក្រោកពីដេក មកតាមដល់កន្លែងនេះ?

គិតដូច្នេះមែន ប៉ុន្តែមាត់ស្នងការសួរផ្សើង៖

«មកដោយចៃដន្យ?»

នាយស្នងការសួរស្រីស្អាតបញ្ជិតបញ្ជៀងនាងវិញ មិនរវល់នឹងអាការៈរបស់គេ គិតពីអង្គុយពត់ខ្លួនរីករាយបង្ហាញសម្រស់មាត់ឆ្លើយឡូយឆាយ៖

«មកអបអរសាទរឱ្យខ្លួនឯង!»

កែវភ្នែកអ្នកចាក់ស្រាហាក់មានបង្កប់ទំនុក«ភ័យ» ហើយដៃគេហុចស្រាមកឱ្យស្រីស្អាតភ្លាមងាកទៅធ្វើជាជូតនេះនោះភ្លាមហាក់ខ្លាចស្នងការមើលដឹងពីចរិត«ស៊ើបអង្កេត»របស់ខ្លួន។

«ខ្ញុំស្មានថានាងអបអរដែលឃើញខ្ញុំត្រូវគេដោះមួកគ្រវាត់ចោល!»

គេនិយាយហើយលើកកែវអកផ្តាច់។ ដៃគេគោះកែវទទៃផ្ងងទៅប្រមាថអ្នកចាក់ ធ្វើឱ្យម្នាក់នោះភ័យស្លេក។

«បង Royបងឯងហូបច្រើនហើយយប់នេះ!»

គេមិននិយាយជាមួយអ្នកចាក់ស្រា បែរជាងាកទៅរកស្រីស្អាតដែលកំពុងមានភាពរីករាយពេញមួយតួខ្លួន។

«លោកមិនរបូតតំណែងឯណា Roy ! ឱត សាម៉ុនចាប់បានអ្នកដែលធ្វើបាបមហាវីននិង Loren ហើយ អាម្នាក់នោះវាត្រូវគុកហៅហើយ!»

Roy ផ្ទុះសំណើចយ៉ាងខ្លាំងធ្វើឱ្យRoseថ្លោះទឹកមុខ។ ដៃនាងក្រសោបកែវសុរាលុបចោលចលនាម្រាមដែលកម្រើកញ័រតិចៗកុំឱ្យមានអ្នកឃើញ។

សំឡេងស្នងការលាន់មកក្រងួរៗ៖

«នាងខ្លួនឯងក៏ដឹងដែរ អតីតប៉ូលិសនោះមិនបានធ្វើអីអ្នកណាទេ! ហេតុអីនៅតែកុហកអ្នកផងហើយកុហកទាំងខ្លួនឯងទៀត?»

Rose អកស្រាអស់។

នាងមិននិយាយតែមុខនាងក្រញូវ។ នៅក្រហមពន្លឺភ្លើងប្តូរពណ៌ នាងប្រាកដជាស្រីស្អាតដាច់គេក្នុងចំណោមស្រីៗដែល Roy បានឃើញនៅភ្នំពេញ។

«ស្រវឹងហើយទៅគេងទៅ Roy!»

«បើទៅគេងពេលនេះមែន ទាល់តែមានគេទៅកំដរខ្ញុំ!»

«លោកជះលុយប៉ុន្មានសន្លឹកទៅ ក៏មិនខ្វះទេ!»

នាងថាទាំងស្ទូរស្រាចាក់ផ្លូកៗបន្ថែមក្នុងកែវដែលនាងហុចទៅ។ ស្នងការក្តៅត្រចៀកស្រែកដាក់អ្នកចាក់ស្រា៖

«អ្ហែងមិនចាក់អញផង!»

តោះនាយស្រវឹងផ្លូងតែនាយឃើញនាងមិចភ្នែកដាក់ក្មេងនោះ។ វាក៏បែរមកចាក់ស្រាឱ្យទៀត។

នាងអកដាច់ភឹងចំណែកនាយ និយាយស្អកស្អា៖

«ស្នេហាយកលុយទៅទិញម៉េចសប្បាយ?»

នាងនិយាយដោយមិនងាកមុខ៖

«រឿងរបស់លោក!»

«ស្រីគ្មានបេះដូង!»

គេដៀលតិចៗហើយដៀងភ្នែកទៅរកគល់ភ្លៅស្រឡូនរលោងរបស់នាងដែលគងលើគ្នារេចុះឡើងបង្កើតទំនុកក្តៅរោលរាលឱ្យភ្នែកមនុស្សប្រុស។

«ពួកប៉ូលិសប្រហែលកំពុងរវល់កសាងសំណុំរឿងទៅតុលាការហើយ ម៉េចលោកមកផឹកស្រាងូតនៅទីនេះទៅវិញ!»

«ព្រោះខ្ញុំមិនដែលចូលរួមជាមួយការងារអត់បានការទេ!!»

នាងហាក់កាន់តែប្រុងប្រយ័ត្ននឹងសម្តីគេ ហើយចាប់ផ្តើមរេភ្នែកគិត។

«ពួកប៉ូលិសអស់នោះកំពុងល្ងង់ ហើយយល់ថាខ្លួនឯងអស្ចារ្យ!»

គេហាក់ភាពរវើរវាយខ្លះ ហើយបាននិយាយរឿងក្នុងចិត្តចេញមកខ្លះ ទោះបីស្ថិតក្រោមឥទ្ធិពលសុរា។

នាងនិយាយតិចៗបណ្ដេញអ្នកចាក់ស្រា៖

«ឯងទៅឈរខាងណោះទៅ បងត្រូវការនិយាយគ្នា!»

Roy សម្លឹងក្រដាសប្រាក់២០ដុល្លារអាមេរិកដែលនាងផ្ទាត់ដោយម្រាមរាវដូចកិន្នរហុចទៅឱ្យក្មេងចាក់ស្រាម្នាក់នោះ។ លុយធីបរបស់នាង ចរិតរបស់នាង សម្លៀកបំពាក់និង Lifestyle របស់នាងមិនសមថានាងមកធ្វើការឱ្យLorenzoឬមហាវីនទេ នាងគួរតែជាថៅហ្វាយរបស់ពួកគេវិញ។

«ហេតុអ្វីលោកគិតថា សេតវិទូមិនមែននៅពីក្រោយល្ខោនដ៏ធំនេះ!»

គេមិនញញឹមលើបបូរមាត់ទេ តែគេញញឹមវាក្នុងចិត្ត។ នាងមានសំណួរដូចអ្នកមានជំនាញវិជ្ជាជីវៈ។គេចង់ប៉ះគ្នាជាមួយនាងណាស់ដូច្នេះបានជា Roy ក្រឡេកសម្លឹងនាងដល់ជម្រៅភ្នែកគឺស្នងការចង់ឱ្យនាងដឹងថា គេចង់ស៊ើបមើលគ្រប់កន្លែងនៅលើរាងកាយរបស់មនុស្សស្រីអាថ៌កំបាំងដូចនាង។

«នាងកំពុងយកការណ៍ឱ្យពីណា? ROSE?»

ស្រីសិចស៊ីដកភ្នែកចេញ។ បើផ្ទង់មើលឱ្យមែនទែន Roy នឹងឃើញថានាងភ័យ តែពេលនេះនាងប្រឹងធ្វើមាំឆ្លើយវិញមិនបង្អង់៖

«លោកគិតម៉េចតាមចិត្ត! តែដឹងរឿងមួយផង! កុំគិតអ្វីស្រមៃពេកស្នងការ! ពិសេសក្នុងពេលខ្លួនឯងកំពុងស្រវឹងដាប!»

«នាងធ្វើការឱ្យមហាវីនឬអាតាវាសប្បុរសបាត់ស្រមោលនោះ? ឬមួយ…..»

គេនិយាយមួយកំណាត់ទុកមួយកំណាត់ បញ្ចេញមួយអន្លើទុកមួយអន្លើ គេមានចេតនាធ្វើឱ្យស្រីស្អាតច្រាសច្រាល។ គេសប្បាយចិត្តដែលឃើញមេពិធីការបែបនេះទៅតាមការចង់បានរបស់គេ។

«មនុស្សដូចលោកគួរឱ្យធុញបំផុត Roy»

នាងនិយាយហាក់មិនសប្បាយចិត្តទេហើយក្រេបស្រាដាច់ៗ ភឹងៗមិនស្រវឹងមិនរង្គើ ប្រហែលមកពីនាងអាងថា ពេលនាងក្រហមមុខ នាងកាន់តែបញ្ចេញក្លិនរោលរាលរបស់នាង ហើយមើលទៅ «ផ្កាកុលាប»។

«ឬក៏នាងធ្វើការឱ្យឱិត សាម៉ុន?»

គេនិយាយបង្អើយស្រាលៗធ្វើឱ្យនាងងាកមករឹងហើយសម្លឹងតាមដានគេដោយពិនិត្យពិច័យ។

«លោកថ្លើមប៉ុនណា ហៅឱិក្មេកទាំងឈ្មោះទាំងត្រកូល?»

ស្មូរទូរសព្ទគេលោតសារមក។ គេអោនសម្លឹង។

នៅក្នុងចម្ងាយនេះ គេស្មានដឹងថា នាងអាចក្រឡេកមកហើយមើលឃើញអានសារនេះបាន ដូច្នេះគេធ្វើជាបែរខ្នងបាំងនាងខ្លះទុកខ្លះ។

Roy ដឹងថាពីក្រោយខ្នងខ្លួនមនុស្សស្រីម្នាក់នេះកំពុងអន្ទះសាចង់ដឹង ចង់ឮអ្វីមួយដែលគេទើបនឹងបានទទួលមកទាំងកណ្ដាលរាត្រីស្ងាត់។ នាយប៉ូលិសបែរក្រោយហើយនិយាយប្រាប់៖

«ដំណឹងល្អ!»

រោមភ្នែករបស់ Rose បះ ឡើងលើ។ នាងពិតជាកំពុងចង់ស្ដាប់ទោះជានាងធ្វើជាក្រេបសុរា។ Royនិយាយបង្អើយ៖

«អាថៅកែកាម៉ាប់ ល្បិច១០០របស់យើង រកលេខចេញពីដៃប៉ូលិសបានហើយ! គេចេញបាត់ហើយ!»

«មហាវីន?»

នាងនិយាយភ្លាត់ស្រាលៗទាំងបញ្ឈប់កែវកាហ្វេត្រឹមបបូរមាត់។

«មើលទៅដូចជាសប្បាយចិត្តណាស់?»

គេឱ្យទៀតធ្វើឱ្យនាងប្រញាប់ដាក់កែវចុះហើយងាកមករឹងៈ

«មេខ្ញុំចេញមកហើយ សមោសរក៏បានបើកវិញ! ខ្ញុំជាពិធីការមិនសប្បាយចិត្តកើតដែរ?»

«តែអាអ្នកឧបត្ថម្ភធំនៅបាត់ស្រមោលនៅឡើយ!»

«ពួកខ្ញុំអត់មាន Lorenzo ក៏រកស៊ីកើតដែរ មិនមែនរង់ចាំដង្ហើមពីគេតែម្នាក់នោះទេ Roy!»

Roy សើចក្អាកក្អាយៈ

«គេពូកែរកគ្នាបានណាស់! ចៅកែនិងកូនចៅ! ឬកមហាអស្ចារ្យប្រហែលគ្នា! ស្មៀតមិនចាញ់គ្នា»

«មុនថាអ្នកដទៃ មើលខ្លួនលោកសិនទៅស្នងការ! មនុស្សមាត់ស្អុយ សម្ដីអាក្រក់ មាក់ងាយអ្នកដទៃយកមេឃទ្រាប់អង្គុយ ប្រមូលគុណសម្បត្តិ ធ្វើចរិតអស្ចារ្យ ញ៉ែមិនរើសមុខ! ទាំងអស់នេះបើខ្ញុំឬមហាវីនលេខមួយ លោកប្រាកដជាគ្មានលេខដាក់ហើយ!»

នាងថាចប់ក៏ក្រោកទាញកាបូបតូចហើយចាកចេញ។

«នាងយកលេសចេញទៅពេលនេះ ប្រញាប់ទៅជួបមហាវីន!»

ស្នងការមិនក្រោកតាមទេ គេនិយាយស៊កសៀតដូច្នេះតិចៗពីក្រោយខ្នង ធ្វើឱ្យនាងទ្រាំមិនបានក៏ឈប់ដំណើរ ហើយងាកថាឱ្យវិញៈ

«លោកស្រវឹងបន្តតាមចិត្តទៅ គិតរវើរវាយតាមចិត្តទៅ!»

ស្នងការក្រោកយឺតៗហើយដើរមកក្បែរនាង ព្រោះនាងនៅសម្លក់ខ្មែរមិនទាន់ចាកចេញ។ គេនិយាយខ្សឹបៗសំដៅកែវភ្នែកមូលថ្លាខ្មៅយង់របស់នាងៈ

«អាម្នាក់នេះ មិនត្រឹមញ៉េមិនរើសមុខទេ វាថែមទាំងចូលចិត្តមើលរឿងអាសអាភាសទៀត!»

បបូរមាត់ Rose ខាំចូលគ្នា។ គេដឹងថានាងជាមនុស្សស្រីដែលគ្មានមនោសញ្ចេតនា គ្មានសេចក្ដីស្នេហានោះទេ។ ចិត្តនាយខូច តែមាត់កាន់តែផុយជាងទៅទៀត នាយនិយាយបន្ថែមសង្កត់ៗ៖

«វាសម្ដីប្រទ្បើសបើស ធ្វើឫកអស្ចារ្យ អ្នកខ្លះថាវាចូលចិត្តយកគុណសម្បត្តិ តែបើបំណាច់ជាយក វាមិនព្រមចូលស៊ងឱ្យគេប្រើក្បាលលេងទេ! អ្នកណាអង្អែលក្បាលវាលេងវាកាច់ម្រាមអ្នកហ្នឹង!!»

នាងងាកមុខចេញទាំងកំហឹងហើយប្រញាប់ចាកចេញ តែគេទាញដៃនាងមកជាប់ជាមួយពាក្យបន្ថែម៖

«ខ្ញុំជាមនុស្សមិនល្អក្នុងកែវភ្នែកនាងឬក្នុងកែវភ្នែកអាណាក៏ដោយ ខ្ញុំមិនខ្វល់! សំខាន់ខ្ញុំចាប់ចោរបាន! រឿងគម្រោងការចោលម្សៀត២០៣៥នៅមិនទាន់ចប់ទេ Rose! ផ្ដាំទៅអាណាម្នាក់ដែលវារៀបចំរឿងនេះឡើង! ផ្ដាំទៅថា ស្នងការ Roy ជាអ្នកបញ្ចប់វា!»

នាងរលាស់ដៃគេចេញ ហើយរអ៊ូ៖

«មនុស្សក្មេងក្អាងគ្មានបានការ!»

ស្នងការឈរវត្ថុបកណ្ដាលបារពេលរងពាក្យប្រមាថ «គ្មានបានការ»។

ភាគទី៤៧

វគ្គ មហាវីននិងRose

មហាវីធ្លាប់ស្លាប់ម្ដងហើយ ដូច្នេះគេគួរតែដឹងថាសុវត្ថិភាពសំខាន់យ៉ាងណា។

«ជិះផ្លូវធំៗទៅមិនបាច់ប្រើផ្លូវកាត់ទេ!»

នៅលើរថយន្ត Mercedes AMG E43 ស៊េរីថ្មីរបស់ខ្លួនថៅកែដែលមានមានរាងស្លីមក្រោយ

ចូលពេទ្យបានមួយរយៈ ហាក់រក្សាភាពស្ងាត់ស្ងៀមខុសមុនពេលដែលគេធ្លាប់មានរឿង។

ប្រមាណកន្លះម៉ោងមុន គេនៅក្នុងពេទ្យក្រោមការឆ្មក់យាមរបស់ប៉ូលិស តែពេលនេះគេបានសេរីពេញលេញមកវិញហើយ។

ម្ចាស់សមោសរដ៏ល្បីរន្ទឺគួរតែមានអ្វីសប្បាយចិត្តបង្ហាញចេញមកខ្លះ ប៉ុន្តែពេលនេះ គេកំពុងចាប់ផ្តើមមានអារម្មណ៍ថា មិនស្រួល។

«ជំនួយការរបស់លោក មិនមែនក្បត់លោកទេ តែគេជាមនុស្សស៊ីឈ្នួលឱ្យការងារក្រៅច្បាប់! តាមចម្លើយសារភាព ដំបូងគេថា Lorenzo ជាអ្នកជួលគេ តែប៉ូលិសជឿថា Lorenzo មិនមែនមេខ្លោងពិតប្រាកដទេ!»

សម្តីឱត សាម៉ុននៅតែដិតដាមក្នុងការគិតរបស់បុរសសអភិជន។

«ជំនួញអាចខកខានតែជីវិតមិនអាចប្រឈមមុខជាមួយការគំរាមញឹកញាប់ពេកនោះទេ!»

គេគិតហើយនិយាយមួយៗទៅកាន់អ្នកបើកបរ៖

«បងឯងឈប់ធ្វើប៉ូលិសហើយមកធ្វើការជាមួយខ្ញុំទៅ!»

អ្នកបើកបរនៅស្ងៀម។

«បងឮណា?»

គេតឿនសួរ។

បុរសនៅខាងមុខសើចតិចៗហើយនៅស្ងៀមទៀត។

មហាវីននិយាយសុភាពរាបសារ៖

«ខ្ញុំគោរពបង ខ្ញុំមិនមែនយកលុយមកនិយាយទេ! បងឃើញពូឱត សាម៉ុននិយាយមុននេះហើយ គាត់ឱ្យបងជូនខ្ញុំចេញមកឱ្យបងការពារខ្ញុំមួយខែពីរខែ ចុះម៉េចបងឯងមិននៅនឹងខ្ញុំតែម្តងទៅ»

បុរសអ្នកបើកបរជាប៉ូលិសជំនាញជាអ្នកដែលឱត សាម៉ុនចាត់ឱ្យតាមការពារមហាវីន។ គេប្រាកដជាមានស្នាដៃហើយគួរឱ្យទុកចិត្តបានជាងអ្នកដែលមហាវីនធ្លាប់យកលុយទៅប្រើ។

ពេលនេះ អ្វីដែលអភិជនក្មេងអន្ទះសាចង់បានគឺប្រព័ន្ធការពារសុវត្ថិភាពមួយដែលគេអាចគេងលក់ស្រួលដូចដើមវិញបាន។

«ម៉ូតូពីរនោះដូចតាមយើង?»

ថាហើយប៉ូលិសឈ្មោះធីណាសម្លឹងទៅផ្លូវខាងមុខ ពេលដែលបេះដូងអ្នកមានលោត។

គេមិននិយាយតែខំសម្លឹងកញ្ចក់សឹងធ្លុះ។

«ម៉េចក៏គេបើកម៉ូតូដូចប៉ូលិសបើកការពារ?»

«គេចចេញទៅ! ទើបតែចេញមកខ្ញុំមិនចង់មានរឿងទេបងធីណា»

មហាវីននិយាយក្នុងសភាពដូចឆ្មាដែលធ្លាប់ត្រូវទឹកក្តៅ ពេលនេះមកប៉ះទឹកត្រជាក់ក៏បះរោម។

អ្នកបើកឡាននៅស្ងៀមស្ងាត់វិញ តែគេបានរេចង្កូតបត់ប្តូរគោលដៅ។ ផ្លូវដែលនៅខាងមុខប្រញឹកព្រោះជាដងផ្លូវដែល ជានិច្ចកាលមានអ្នកទេសចរដើរព្រាតចង់ចូលផ្សាររាត្រីនិង Pup ជាច្រើនអមបណ្តោយទន្លេ។

ជាធម្មតាយើងតែងតែគិតថា  កន្លែងដែលមានមនុស្សច្រើនអាចទុកចិត្តជាង។

«យឺតៗមើល៍ ដើម្បីឱ្យដឹងថាតើវាតាមមកទៀតដែរអត់?

មហាវីននិយាយខ្សាវៗខ្សឹបៗភ្នែកគេក្រឡេកក្រឡាប់ចុះឡើង។ ប៉ូលិសចំណាស់បន្ថយល្បឿនបើកឡានផងរេភ្នែកសម្លឹងមុខក្រោយឆ្វេងស្តាំផង។

«បាត់ពួកវាទៅណាហើយ?»

នៅលើកញ្ចក់ មហាវីនពិបាកក្នុងការតាមដានអ្វីៗដែលកើតឡើងនៅជុំវិញយានរបស់ខ្លួនណាស់។ តែគេអរនៅពេលឮប៉ូលិសដែលតាមមកការពារ ប្រាប់ថាបាត់លែងឃើញម៉ូតូ។

«យើងអាចមើលខុស! ពួកគេមិនបានតានដានយើងទេ យើងប្រហែលភ័យពេក!»

មាហាវីននិយាយកម្លាតិចៗហើយក្រឡេកឆ្វាច់មកក៏មើលឃើញបុរសម្នាក់ឈប់ម៉ូតូនៅម្ខាងនៃផ្លូវដែលឡានគេកំពុងបោល។ ពួកគេបានបើកឡានហួសទៅតែចិត្តនាយអភិជននៅតែពិភាល់។

«ម្នាក់មិញហ្នឹង ខ្ញុំដូចប្រហែលមុខ!»

«ធ្វើធម្មតាទៅកុំតឹងតែងពេក!»

ឡានបត់វេរចូលច្រកផ្ទះបុរីរបស់គេ។

វាមិនមែនជាទី ដដែលផ្ទះទុកសម្រាប់សប្បាយជាមួយពួកស្រីៗកន្លែងដែលគេត្រូវប្រហារស្ទើរលែងបើកភ្នែករួចកាលពីថ្ងៃមុននោះនោះទេ។

ទីនេះមានប្រពន្ធការពារសុវត្ថិភាព ដោយមានសន្តិសុខនិងប្រតិបត្តិការតឹងតែងម្ភៃបួនម៉ោងលើ២៤ម៉ោង។ គេធូរចិត្តពេលទទួលអារម្មណ៍ថាមកដល់ផ្ទះ។

«យប់នេះខ្ញុំកុម្ម៉ង់បាយថ្លៃជាងគេនៅភ្នំពេញនេះមកឱ្យបងឯងហូបជាមួយខ្ញុំ!» ប៉ូលិសធីណាញញឹមជ្រួញតាមកញ្ចក់។

ទាំងពីរនាក់ចតឡានហើយចុះមកក្នុងបរិវេណសួន។ អ្នកយាមផ្ទះពីរបីនាក់រត់មកទទួលមហាវីនធ្វើឱ្យអភិជនកន្ទាត់រេភ្នែកសម្លឹងមុខពួកគេយកចិត្តទុកដាក់។

គេមានចរិតប្រុងប្រយ័ត្ន ជាមួយនឹងវិនិច្ឆ័យស្វាត់ៗដូចជាមហាវីនថ្មីម្នាក់ទៀត។ អ្វីមួយគួរឱ្យសង្ស័យទេម្នាក់ៗសប្បាយរីករាយពេលឃើញចៅហ្វាយវិលមកវិញ។

នៅខាងក្នុងផ្ទះ អ្នកមេផ្ទះជាស្ត្រីចំណាស់ម្នាក់និងដៃជើងស្រីៗវ័យកណ្តាលពីរនាក់ទៀតនៅរង់ចាំជាជួរ។

«ពីមុនមកខ្ញុំមិនទម្លាប់នៅជាមួយអ្នកណាច្រើនគ្នាអ៊ូអរទេ! ជីវិតខ្ញុំដូចពួកលោកខាងលិច

ចូលចិត្តស្ងាត់! អ៊ីចឹងហើយផ្ទះនេះខ្ញុំមិនសូវមកទេ! ឃើញអត់អ៊ំពូមាមីងខ្ញុំបញ្ជូនមនុស្សមកពេញផ្ទះពួកគេបារម្ភពីខ្ញុំនេះ ហើយបើកុំតែខ្ញុំហាម កុំអីញាតិខ្ញុំគេនាំគ្នាបើកឡានមកលេងអង្គុយពេញហ្នឹងចាំស្វាគមន៍ខ្ញុំ! »

លោកប៉ូលិសតបវិញទាំងងក់ក្បាល៖

«ល្អទេតើ! មានញាតិច្រើន!»

នៅឯជាន់ខាងលើ។ ពួកគេទាំងពីរមានអាហារពេលល្ងាចមួយពេលជាមួយគ្នាហើយសេព ស្រាស្រៀងៗតែមហាវីនប្រយ័ត្នណាស់ក្នុងសកម្មភាពនីមួយៗរបស់គេ។

ចុងក្រោយភាពហត់នឿយធ្វើឱ្យគេដេកលក់ក្លឹងក្នុងបន្ទប់ដូចរាជវាំងរបស់ខ្លួន។ ភ្លឺឡើងកាល ណាគេក្រោកដឹងខ្លួនភ្លែតហើយស្ទុះចោលគ្រែ។ ទ្រនិចនាឡិកាចង្អុលម៉ោង៧ព្រឹក វាព្រលឹម ណាស់សម្រាប់មហាវីន។

«អរុណសួស្តី»

ធីណា និយាយដោយសំឡេងខ្លាំងៗនិងស្នាមញញឹមដ៏ធំពីតុបាយមក។ មហាវីនងក់ក្បាល ហើយញញឹមតបជាមួយពាក្យដូចគ្នា ប៉ុន្តែគេលបគិតក្នុងចិត្ត៖

«ជីវិតរបស់អញ នៅជាមួយប៉ូលិសរហូតដល់ពេលណា?»

សំឡេងប៉ូលិសនេះនិយាយមកឮៗ៖

«ខ្ញុំហូបច្រើនណាស់ហើយចូលចិត្តហូបជាងអ្នកផ្សេង! បើថ្ងៃណាលោកយល់ថាបង្ហិនអង្ករ ច្រើនហើយចង់ឱ្យខ្ញុំត្រឡប់ទៅវិញ ប្រាប់មកខ្ញុំទៅភ្លាម!»

មហាវីនសម្លឹងទៅមេផ្ទះដែលលើកបាយឆាមួយចានធំទៀតចេញមក។

គេនិយាយទាំងឈានជើងមួយៗចុះជណ្តើររលាក់អស់ដងខ្លួន៖

«បងឯងពូកែហូប ហូបឱ្យខ្ញុំក្រមើល៍! ចាំខ្ញុំឱ្យបងឯងទៅវិញ!»

គេគ្មានថ្ងៃក្រទេ គេដឹងច្បាស់។ អ្វីដែលគេបារម្ភពេលនេះគឺថា តើគេអាចនៅចាយទ្រព្យបាន ដល់ពេលណា?

មហាវីនមកអង្គុយក្បែរតុអ្នកបម្រើសួរភ្លាម៖

«កាហ្វេដដែលទាន!»

«អត់ទេ! យកក្រូចពោធិ៍សាត់!»

ប៉ូលិសធីណាញញឹមសម្លឹងជននេះ ពេលគេប្តូរមកជាសុភាពរាបសារខុសពីមហាវីនដែលធ្លាប់ល្បី។

ស្នូរជើងកុបៗនៅមាត់ទ្វារធ្វើឱ្យមហាវីនងាកទៅហើយគេចាប់ផ្តើមថ្លោះទឹកមុខ។

«ខ្ញុំដឹងមហាវីនចេញមកតាំងតែពីយប់ម្សិលតែខ្ញុំមិនចង់រំខាន!»

ប៉ូលិសធីណាឃើញក៏ព្រួយបារម្ភក្នុងជម្រៅគ្រាប់ភ្នែកមហាវីនជាជាងស្នាមញញឹមរបស់គេ។ អ្នកដែលទើបនឹងបង្ហាញខ្លួនជាមនុស្សស្រី ដែលស្រស់ស្អាត សូម្បីតែប៉ូលិសចំណាស់ក៏ត្រូវញញឹមភ្លឹកស្វាគមន៍សម្រស់នាង។

«ម៉ោះ Rose! អាហារពេលព្រឹកជាមួយគ្នាម្តង!?»

នៅពីក្រោយ ឈុតអាវកីឡានាងនៅតែមានរូបរាងខ្ពស់ស្រាវ យ៉ាងស្អាត ដែលធ្វើឱ្យធីណានឹកឆ្ងល់អំពីភាពព្រួយបារម្ភក្នុងទឹកមុខប្រែប្រួលចុះឡើងរបស់មហាវីន។

នារីនេះអង្គុយចុះមកជាមួយកាយវិការស្រាលស្ទើក។ រាងកាយនាងមានភាពរហ័សរឹងប៉ឹងនិងសុខភាពល្អ។ នាងលូកដៃមកស្វាគមន៍ប៉ូលិសដែលស្ថិតនៅក្នុងឯកសណ្ឋានគេងនៅឡើយ។

«ញុាំអី Rose?»

«សុំតែពិសេសនោះមក»

មហាវីនញញឹមបើកភ្នែកធំៗ ព្រោះទើបនឹងនឹកឃើញអំពីតែបុរាណជាថ្នាំចិនដ៏មានតម្លៃដែលគេនឹងនាងបានទិញអំឡុងពេលដែលពួកគេធ្លាប់មានបេសកកម្ម ការងារទៅស្រុកចិនជាមួយគ្នា។

គេចង្អុលនាងមួយៗទាំងញញឹមបន្ទោសៈ

«ពូកែរករបស់ឆ្ងាញ់! ចាំមួយភ្លែតខ្ញុំឡើងទៅយកមកឱ្យ!»

ប៉ូលិសធីណាឈ្ងោកហូបអាហារបន្ទាប់ពីបានអញ្ជើញ ហើយតែនាងគ្រវីក្បាលបដិសេធ។

ទោះបីអោនក្តី គាត់នៅតែចាប់អារម្មណ៍ដឹងថានារីនេះកំពុងសម្លឹងមកគាត់ដោយកន្ទុយភ្នែក។

នាងគឺជាអ្នកជំនាញខាងវិនិច្ឆ័យនេះបើតាមការពិចារណាអំពីសកម្មភាពភ្នែករបស់នាងនិងរបៀបអង្គុយរបស់នាង។

«ខ្ញុំដូចធ្លាប់ឃើញពូ?»

Rose និយាយតិចៗទាំងលើកជើងគងលើគ្នាក្នុងឈុតកីឡារបស់នាង។ អាការៈនាងជានារីដែលមានទំនុកចិត្តចំពោះខ្លួនឯងមហាខ្ពស់។

«ខ្ញុំទើបតែផ្លាស់ពីខេត្តមកទេនាង!»

«ពូមកធ្វើការឱ្យឧត្តមសេនីយ៍ឱត សាម៉ុន?»

«ម៉េចក៏នាងដឹង?»

Rose នៅបន្លាយពេលជាមួយស្នាមញញឹមពេលគាត់ចោលភ្នែកមក។ នាងព្រមនិយាយពេលបុរសចំណាស់ហាក់នៅទន្ទឹងរង់ចាំចម្លើយ៖

«ថៅកែខ្ញុំទើបនឹងចេញមក ប៉ូលិសត្រូវតែដាក់កម្លាំងការពារគាត់មិនលែង! ចំណែកអ្នកដែលកាន់សំណុំរឿងរបស់មហាវីនគឺឧត្តមសេនីយ៍ឱត សាម៉ុន!»

ធីណាងក់ក្បាលហើយនិយាយស្រប៖

«ប៉ូលិសចង់បង្ហិនបាយថៅកែវីនប៉ុណ្ណោះ! គ្មានអ្នកណាគេមានពេលមកធ្វើអីគាត់ទេ ពួកមនុស្សអាក្រក់ជាប់ជុចអស់អស់ហើយហ្នឹង!»

Rose ហាក់បីដូចជាកាន់តែមានឱកាសក្នុងការសួរ៖

«ចំណែកពូ? ទស្សនៈផ្ទាល់ខ្លួនរបស់ពូ! ពូយល់ថាសេតវិទូពិតជាបានជួលប៉ូលិសចូលនិវត្តន៍ទាំងអស់ដែលគាត់ស្គាល់ហ្នឹង ឱ្យទៅបន្លំខ្លួនក្នុងគ្រួសារពួកអ្នកមានរង់ចាំឱកាសមកដល់នឹងចាប់កូនស្រីរបស់ពួកគេ ហើយពេលសភាពការណ៍ទុំជោរក៏ចាត់ការចោលទាំងអស់បំបិទមាត់?»

គិតចុះឡើងធីណាឈប់បរិភោគ។ គាត់យកកន្សែងមកជូតមាត់ហើយក្រេបទឹក ក្អឹកទុកឱ្យនាងតាមសម្លឹងរង់ចាំចម្លើយ។

មិនបង្អង់នាងនិយាយបន្ថែម៖

«យប់មិញស្នងការ Roy ជួបខ្ញុំ! គេនោះដូចជាមិនយល់ស្របរឿងចាប់ប៉ូលិសចូលនិវត្តន៍ម្នាក់ហ្នឹងសោះ!»

«អ្នកណានិយាយដើមខ្ញុំ?»

ស្នងការ Roy បង្ហាញខ្លួននៅមាត់ទ្វារធ្វើឱ្យស្រីស្អាតដូរទឹកមុខតែនាងមិនងាកទៅទេ។

«ពូធីណាញ៉ាំអីព្រលឹមម៉េះ?»

ប៉ូលិសធីណាធ្វើមុខស្លីសម្លឹងស្នងការក្មេងដែលបង្ហាញខ្លួនទាំងមុខញញឹមប៉ប្រឹមដូចគ្រាប់ជីគាត់និយាយហាក់ងឿងឆ្ងល់ខ្លាំង៖

«បាត់លោកស្នងការទៅណាមិនឃើញដំណឹងសោះ បងសាម៉ុនឱ្យគេតាមរកពេញហ្នឹង!?»

ស្នងការអង្គុយភឹះមកលើសាឡុងទន់ល្មើយរបស់ផ្ទះអភិជន។ គេនិយាយទាំងងាកមកសម្លឹង Roseទោះបីនាងធ្វើឱ្យអេានមុខជំទាស់ក្រចក។

«ខ្ញុំតប់ប្រមល់ពេក ដកឃ្លាខ្លះ!»

ទោះបីអាការៈ Roy មើលទៅហាក់បីដូចជាធ្វើវាហីនឹងឈ្មោះ«ឱត សាម៉ុន»អនាគតឪពុកក្មេកដែលគេធ្លាប់តែគោរព តែប៉ូលិសធីណានិយាយមែនទែន៖

«លោកគួរទូរសព្ទទៅរកឪពុកក្មេកឥឡូវនេះ! ខ្ញុំឡើងទៅមើលមហាវីនសិន!»

បុរសនោះក្រោកទៅបាត់។ Roy ប្តូរទឹកមុខទៅជាស្រងូតមួយរំពេចពេលរំលឹកអំពីឱត សាម៉ុនធ្វើឱ្យRose សើចខឹកៗចំអក។

គេសួរនាងដែលនៅអង្គុយពីចំហៀងទាំងដៃលូកទាញយកទូរសព្ទ ចេញពីហោប៉ៅ ហើយត្រៀមចុច។

«សើចស្អីគេ? តួកំប្លែង?»

នាងនៅតែមិននិយាយ គេឈប់ចុចទូរសព្ទបែរជាលោទៅក្បែរនាងហើយលើកដៃក្រសោបកាយ។ ដៃម្ខាងរបស់គេច្បូតសក់នាង ដែលវែងអន្លាយធ្វើឱ្យស្រីស្អាតសៅហ្មងច្រាននាយចេញ។

«យកដៃគគ្រិចរបស់លោកចេញ Roy !»

ដល់វេនគេសើចក្អាកក្អាយម្តង គឺសើចយ៉ាងវែង ក្រោមកែវភ្នែកសម្លក់របស់នាង។ មិនយូរប៉ុន្មាននាងស្ទងការបង្អង់សំឡេង ព្រោះត្រចៀកស្តាប់ឮសូរអ្វីម្យ៉ាងលាន់មកពីជាន់ខាងលើ.....

គេបែរមុខសម្លឹងជុំវិញហើយស្រែកសួរ៖

«មហាវីននៅឯណា?»

មិនមានចម្លើយ ព្រោះគ្រប់គ្នាកំពុងភ្ញាក់ផ្អើលនឹងស្នូរជង្ហើមហត់គឃូសមួយព្រមជាមួយការសុំជំនួយអួលៗម្តងឮម្តងមិនឮ៖

«ជួយ.....ផង!.....ជួយ!»

រហ័សដូចផ្លេកបន្ទោរ Rose ស្ទុះក្រោកភ្នែកសម្លឹង សំដៅទៅជណ្តើរចំណែក Roy ក្រោកឈរសន្សឹមៗ ដោយចំហមាត់ផ្លុង។

នៅជាន់ខាងលើ មហាវីនរត់មកដល់មាត់ជណ្តើរ ហើយស្នាមឈាមប្រឡាក់ពាសពេញ អាវរាត្រីពាណ៌សស្វាចរបស់គេ។

នៅខាងលើគ្មានអ្នកណាទេ សូម្បីតែប៉ូលិសឈ្មោះធីណាដែលទើបនឹងឡើងទៅ មានតែមហាវីនដែលកំពុងដួលស្រុញស្រវ៉ាតោងបង្កាន់ដៃជណ្តើរជាប់។

Rose ស្រែកភ្លាត់សំឡេងហើយប្រញាប់រត់ឡើងទៅតែត្រូវ Roy លូកដៃទាញឃាត់ច្រានឱ្យត្រឡប់ក្រោយ។

ដោយកែវភ្នែកក្តៅគគុករបស់ស្នងការគេនិយាយរអ៊ូម្នាក់ឯង៖

«អញស្មានអីចេះខុស!»

គេរអ៊ូហើយរត់ឡើងជណ្តើរក្នុងគោលដៅទៅទាញយករាងកាយបុរសកន្ទាត់អ្នកមានឱ្យចុះមកក្រោម។

មហាវីនបិទភ្នែកលែងដឹងខ្លួនទៅហើយ ខុសពីមុននេះដែលគេទើបដឹងគេងើបមុខសម្លឹងទៅជួរជ្រៅសន្លឹមនៃគេហដ្ឋានជាន់ទីមួយ។ ធីណានៅរកមិនឃើញចំណែកមនុស្សប្រុសអាវយឺតខ្មៅ២នាក់រត់រឹងចម្ងាយប្រមាណ១០ម៉ែត្រប៉ុណ្ណោះពីមុខខ្លួន បានន័យថាគេទើបនឹងមកប្រដេញបាញ់មហាវីនបន្ថែមឱ្យបិទភ្នែកក្បែរបង្កាន់ដៃជណ្តើរជាមួយអាវុធគ្មានសំឡេងរបស់គេ។

«ឈប់អ្ហែង.....!»

ស្នងការស្រែកគំរាមខ្លាំ ហើយរត់ប្រដេញទៅតាមពីក្រោយជាមួយកាំភ្លើងតូចខ្លីក្នុងដៃ។ មកដល់របាំង ចុងក្រោយនៃគេហដ្ឋានពួកប្រដាប់អាវុធគេរួចម្នាក់ទៅក្នុងបន្ទប់ខាងចុង ចំណែកម្នាក់ទៀតងាកមកឃាត់ដំណើរស្នងការ....

ស្នូរកាំភ្លើងលាន់ខ្លាំ..... ជាសំឡេងផ្ទុះលាន់ចេញពីអាវុធខ្លួនឯង។ ចំណែកខាងសត្រូវវាគ្មានសំឡេងទេស្ងាត់ច្រៀបតែវាមានឥទ្ធិពលហាក់បីដូចជាដុំដែកដ៏មហាក្តៅចាក់ទម្លុះទ្រូងនាយ។

វគ្គ ការព្រមាន

ពេលនេះវាសនាមហាវីនមិនដឹងនៅឯណាទេ ចំណែកគេបើកភ្នែកមកវិញឃើញខ្លួនឯងក្នុងមន្ទីរពេទ្យ ....

ស្រីម្នាក់កំពុងឈរបែរខ្នង គេមើលស្គាល់នាងថាអ្នកណាបានន័យថាស្មារតីមិនទាន់វង្វេងនៅឡើយហើយរបួសក៏មិនធ្ងន់ពេកដែរ។

«មហាវីនម៉េចហើយ?»

នាងងាកមកវិញយ៉ាងរហ័ស ហើយនាងសម្លឹងគេដោយយកចិត្តទុកដាក់។

«សួរថាមហាវីននៅឯណា?»

«សង្គ្រោះបន្ទាន់។!»

នាងឆ្លើយខ្លីធ្វើឱ្យដង្ហើមស្នងការកាន់តែហត់នឿយបិទភ្នែកយឺតៗ។

«តែពេទ្យថាមហាវីនគ្មានសង្ឃឹមទេ!»

នាងបន្ថែមប៉ុន្មានម៉ាត់នេះធ្វើឱ្យស្នងការបើកភ្នែកមកវិញ។ បន្ទប់នេះបិទទ្វារតែមើលចុះឡើង ទើបដឹងថា វាមិនទំនងជាមន្ទីរពេទ្យ។

គេប្រញាប់សម្លឹងពិនិត្យគ្រប់ជ្រុងជ្រោយយ៉ាងឆាប់រហ័ស។ នារីនេះទំនងយល់ចិត្តស្នងការ នាងដើរក្បែរនាយហើយអង្គុយក្បែរនាយ ជាមួយនិងស្នាមញញឹមៈ

«លោកពាក់អាវក្រោះអ៊ីចឹងរហូតទោះមិនមែនក្នុងបេសកកម្មក៏ដោយហ្អីស្នងការ?»

គេរេភ្នែកមកសម្លឹងមុខនាង។

នាងដឹងអស់ហើយថាគេមិនបានរបួសធ្ងន់ទេ ព្រោះគេមានអាវដែកពីក្នុង ប៉ុន្តែនាងយកគេមកទីនេះបានដោយរបៀបណាហើយហេតុអ្វី បានជាដៃគេកម្រើកមិនបាន។

ត្រូវហើយ ដៃទាំងពីរជាប់ខ្នោះ??

«ខ្ញុំគិតថារហូតដល់ពេលនេះ មហាវីនស្លាប់ហើយ! គ្រាន់តែប៉ូលិសគេមិននិយាយ!»

Roy ខំផ្ចង់ស្មារតី រំលឹកឡើងវិញនូវហេតុការណ៍ទាំងឡាយនៅឯទីកន្លែងកើតហេតុ។ សំឡេងរន្ធត់ស្លុតរបស់មហាវីនដែលគ្រប់គ្នាបានឮនាពេលចុងក្រោយ គឺការស្នើសុំជំនួយមុនពេលគេបិទភ្នែកទៅ។

នារីនេះមើលយ៉ាងណាក៏មិនឃើញស្លាកស្នាមសោកសៅក្នុងកែវភ្នែកនាងសោះ។

«នាងបានធ្វើអីខ្លះអ្នកRose?»

គេពោលសួរជាមួយបបូរមាត់ដែលក្រៀមក្រោះសឹងរហែកស្បែកស្រក់ឈាមមកបាន។ នាងមិនឆ្លើយងាកទៅចាក់ទឹកមួយកែវមកហើយបញ្ចុកនាយ។

«មួយកែវនេះ ខ្ញុំសងអំពើល្អដែលលោកនិងពូលោកបានជួយខ្ញុំនៅ Manchester! រឿងរ៉ាវជិតចប់ហើយ! ខ្ញុំនឹងដោះលែងលោកពេលខ្ញុំចេញផុតពីទីនេះ!»

ភាពខូចចិត្តកើតឡើងក្នុងកែវភ្នែកស្នងការ។

គេក្រេបទឹកបានបន្តិចក៏ឈប់ព្រោះ«ឆ្អែត»។ ចំណែកនារីនេះសម្លឹងផ្តោតទៅលើប្រតិកម្មរបស់គេ។នៅចំពោះមុខសំណួរធំសម្រាប់នាងគឺថា ហេតុអ្វីក៏បុរសនេះ មើលទៅគេហាក់ក្រៀមស្រពោន តែ គេហាក់គ្មានទេភាព«ភ្ញាក់ផ្អើល»?។

Rose ជ្រួញចិញ្ចើមសម្លឹងមើលភាពគ្មានប្រតិកម្មរបស់គេ ហើយដរាបណាគេកាន់តែនឹងថ្កល់ដរាបនោះនាងកាន់តែមានពិភាល់នៅមិនសុខ។

ពេលនារីនេះនៅកាន់កែវធ្វើឆ្ងល់ គេនិយាយតិចៗមាំៗ៖

«ទៅសារភាពទៅ Rose ភ្ញាក់ខ្លួនឡើង!»

នាងមិចភ្នែកសម្លឹងមុខសមត្ថកិច្ចដែលជាប់ក្នុងចំណង។ «មិញលោកនិយាយថាម៉េច Roy?»

នាងខ្សឹបសួរតិចៗ មកលើកែវភ្នែកស្រពាប់ស្រពោនរបស់ស្នងការ។

«លោកដឹងអ្វីខ្លះ?»

នាងសួរសំណួរនេះ ពេលដែលគេនៅតែមិននិយាយហើយសម្លឹងមុខនាងមិនដាក់។

នាងមានអារម្មណ៍ថា កម្តៅនៃភាពអាម៉ាស់និងមោទនភាព លាយបញ្ចូលគ្នាច្របូកច្របល់ហើយស្ដែងចេញតាមរយៈ ខ្យល់ដង្ហើមរបស់ខ្លួនដែលសាយភាយនៅចំពោះមុខបុរសនេះ។

Roy ហាក់មិនបានភ្ញាក់ផ្អើលដដែល ទោះជានាងដូរទឹកមុខញឹកញាប់ម្តងភ័យព្រួយម្តងខឹងសម្បារម្តងកម្សត់។

«នាងស្អាតយ៉ាងនេះ មានអ្នកស្រលាញ់ស្មោះយ៉ាងនេះ ហេតុអ្វីទៅធ្វើអំពើអាក្រក់បំផ្លាញខ្លួនឯងវិធីតា?»

«លោកឯងដឹងរឿងអីខ្លះ?»

នាងនិយាយខ្សឹបៗហាក់ខំប្រឹងបិទបាំងលាក់រលកសូរសំឡេងដែលរញ្ជីរញ្ជ័រពីបំពង់កខ្លួនព្រោះថាមនុស្សក្លាហានប៉ុនណា គង់តែធ្លាក់ភ័យ នៅពេលប្រឈមមុខនឹងអ្នកណាម្នាក់កំពុងដឹងអាថ៌កំបាំងរបស់ខ្លួនច្បាស់ដូចថ្ងៃ។

«នាងគិតថា គ្រប់គ្នាគេល្ងង់?»

Roy ឆ្លើយភ្លាមៗដោយបង្កប់ការស្ដីបន្ទោសក្នុងពន្លឺភ្នែក។ ទោះបីស្រីម្នាក់នេះរក្សាភាពស្ងប់ស្ងាត់ដោយគ្មានការបញ្ចេញសំឡេងអ្វីបន្ថែម ប៉ុន្តែនាយយល់ពីសភាពជ្រួលច្រាលរបស់នាង។

«អាឆ្កួតណាសន្យានឹងនាងថាបន្ទាប់ពីឧក្រិដ្ឋកម្មច្រើនយ៉ាងនេះហើយ នាងអាចនឹងរួចខ្លួនចេញពីស្រុកខ្មែរ? នាងមានតែផ្លូវចុងក្រោយមួយប៉ុណ្ណោះ ទៅសារភាព ខ្ញុំនឹងជួយនាង»

ផាច់!

ថ្ពាល់ស្នងការរងមួយដៃ ងឹងដល់ភ្នែក។

Rose ប្ដូរពីស្ងាត់ទៅជាស្រែកគំហកឮៗ៖

«ប្រាប់រួចហើយប៉ូលិសពួកឯងនេះ គ្មានបានការអីទាំងអស់!»

គេនៅស្ងៀមទុកឱ្យនាងនិយាយជាមួយសង្វាក់ដើមទ្រូងដែលហត់គឃូស។

នាងនិយាយបន្តទាំងកែវភ្នែករលោងដោយទឹកភ្នែក៖

«បើពួកឯងបានការឯងមកដេកជាប់ខ្មោះអ៊ីចឹងកើតដែរអត់ ស្នងការអត់ប្រយោជន៍ស្នងការល្មោភកាម ស្នងការបានតែអួត?»

ថាចប់នាងសើចខឹកៗ ហើយទឹកភ្នែកស្រក់មក.....

ភាគទី៤៨

វគ្គ ជម្រះបញ្ជី

ឱត សាម៉ុនអង្គុយក្នុងបន្ទប់របស់គាត់ហាក់បីដូចជាកំពុងរង់ចាំការមកអ្នកណាម្នាក់។

ស្ទូរម៉ូតូរបស់ចិត្រា នៅខាងក្រៅ។ ឧត្តមសេនីយ៍ហាក់មិនមានការភ្ញាក់ផ្អើលអ្វីសូម្បីតែនឹងងើបមុខទៅសម្លឹងក៏ទេ។

ផ្ទះនេះស្ងាត់ខុសសព្វដង អ្វីៗពិតណាស់ដូចជាមានការរៀបចំទុកជាមុនសូម្បីតែពូហឿនដែលរត់មកបើកទ្វារក៏មុខស្លូតក្រៀមដែរ។ គាត់អោនមុខជ្រប់ពេលប្រទះនឹងទឹកមុខខ្មៅរោលរបស់នាយសក្តិបួន។

គ្មានអ្នកណានិយាយរកអ្នកណាមួយម៉ាត់ ចិត្រាឡើងសំដៅផ្ទះធំ។ គេសង្ឃឹមថាប្រសិនបើអមរាជាមិននៅផ្ទះថ្ងៃនេះគ្រប់យ៉ាងនឹងកាន់តែប្រសើរ។

ដើរកាត់ផ្ទះគេនឹកឃើញឡើងវិញដល់អនុស្សាវរីដំបូងៗដែលគេធ្លាប់ដើរ ចូលមកក្នុងនាមជាអង្គរក្សស្មោះត្រង់ម្នាក់ ស្មោះរហូតដល់ពេលនេះនិយាយលែងចេញ។

«ខ្ញុំត្រូវការឱ្យលោកចេញលិខិតសុំទោសពូខ្ញុំហើយដោះលែងគាត់!»

លោកឱិត សាម៉ុន មិនអើពើនឹងសំឡេងរបស់គេទេ ព្រោះគាត់នៅតែផ្ចង់នឹងការវាយឯកសារក្បែរតុ។ កែវកាហ្វេគាត់នៅហុយទ្រលោមក្រអូបឆួលធ្វើឱ្យអ្វីៗគ្រប់យ៉ាងរំលឹកមកវិញ។ វាកើតឡើងដូចសុបិនមួយ ដែលខ្លួន ធ្លាប់បានដាក់ចិត្ត គោរពនិងជឿជាក់មនុស្សម្នាក់នេះ ទីបំផុតការពិតមួយ ធ្វើឱ្យខ្លួនត្រូវគេបង្ខំឱ្យក្លាយមកជាមនុស្សដែលលែងអាចទុកចិត្តអ្វីគ្រប់យ៉ាងបាន លែងទុកចិត្តអ្នកណាទាំងអស់។

ពូរបស់គេ នៅសុខៗ ត្រូវចាប់ខ្លួនហើយ។ រឿងនេះអ្នកណាក៏ដឹង។ ស្នាដៃនិងកេរ្តិ៍ឈ្មោះក្រអូបសាយរបស់គាត់ស្រាប់តែនៅសុខៗត្រូវរងបំផ្លាញហើយ វាសនាគាត់ចុងក្រោយ ដែលធ្លាប់ជាមេប៉ូលិសមានសមត្ថភាព មានគេគោរពពេលនេះត្រូវស្ថិតនៅក្នុងកណ្តាប់ដៃនៃពួកប៉ូលិសត្បាញអាយ ពួកពាក់មុខក្លែងក្លាយអស់ទាំងនេះ។

«ពូខ្ញុំគ្មានដឹងអីទាំងអស់! ចុងក្រោយពួកលោកបំបែកក្តីមិនបាន បំណាច់នឹងធ្លាក់សក្តិក៏យកពូខ្ញុំមកទទួលទោស!»

ឱិត សាម៉ុន ដកដង្ហើមធំហើយងើបមុខមក។ ដៃគាត់ក៏ឈប់ដៃលែងធ្វើការ។ គាត់និយាយមួយៗរក្សាអាការៈនឹងនៈ

«ព្រោះលោកកំពុងខូចចិត្ត! ខ្ញុំយល់ៗ! ពេលនេះលោកនិយាយអ្វីក៏ខ្ញុំមិនប្រកាន់! តែជាតិចិត្រា ខ្ញុំចង់ឱ្យលោក ចាំរឿងមួយ មិនមែនបានន័យថាសកម្មភាពនេះ អាចជួយពូលោកបាននោះទេ!»

គេបានឆ្លងកាត់ការសម្រេចចិត្តច្បាស់លាស់ហើយមុនពេលបង្ហាញខ្លួននៅទីនេះក្នុងពេលនេះ ទោះយ៉ាងណាគេមិនឱ្យឱិត សាម៉ុនប្រើហេតុផលអ្វី មកបោកបញ្ឆោតបានសាជាថ្មីទៀតនោះទេ។ ចិត្រាធ្វើមុខស្មើអង្គុយចុះមួយៗលើសាឡុងដោយមិនចាំបាច់មានការអញ្ជើញ។

«ខ្ញុំនឹងបកអាក្រាតលោក!»

គេនិយាយខ្លីៗធ្វើឱ្យជនចំណាស់ សើចតិចៗ។

គេនិយាយបន្តៈ

«លោកសប្បាយចិត្តបណ្តោះអាសន្នបាន ឱិត សាម៉ុន! តែបន្តិចទៀតលោកសើចលែងសមហើយ»

អ្នកណាម្នាក់គោះទ្វារតុៗ។ ចិត្តនាយផ្លុះធ្លាយវេទនា ព្រោះស្នូរគោះស្រាលៗដឹងហើយថាជាអ្នកណា។

អមរាជាចូលមកជាមួយទឹកមុខស្រពោន។ នាងសម្លឹងគេដែលគេមិនងាកទៅមើលមុខនាងទាល់តែសោះ ចំណែកឱិត សាម៉ុននៅគងអន្ទាក់ខ្លាធ្វើហី។

តាមពិតនាងនៅផ្ទះ..... ប៉ូលិសកម្សត់យើងគិតផងចិត្តរារែកហេងហាងផង។ គេដឹងថា ឧត្តមសេនីយ៍នេះ ជាមនុស្សពុតត្បុតជាខ្លាលាក់ក្រចក។ គាត់ដឹងថាអមរាជាជាចំណុចខ្សោយរបស់ខ្លួនបានជាបញ្ជូននាងមក ពីដើមរៀងមក នាងជាតួអង្គនៅក្នុងឆាកល្ខោនរបស់គាត់។

ស្តាយណាស់ យើងស្រលាញ់គេ គោរពឪពុកគេ រក្សាសម្តីជាអង្គរក្សស្មោះស្ម័គ្រសុខចិត្តចូលស៊ងក្នុងល្ខោន ជួយជីវិតកូនគេ មិនស្តាយសូម្បីសង្ខារខ្លួនឯង! ធ្វើរឿងដែលសូម្បីតែពេលធម្មតាមិនដែលជឿថាខ្លួនឯងអាចធ្វើបាន! ពេលនេះដៃនៅរបួសមិនទាន់បាត់ស្នាម ឈាមនៅកកមិនទាន់ជម្រះការឈឺចាប់អស់ តែវាមកត្រូវគ្របដណ្តប់បន្ថែមដោយសេចក្តីអាម៉ាស់ដែលត្រូវចាញ់បោកឪកូនផ្ទះនេះ គួរឱ្យសង្វេគខ្លួនឯង។

«ប៉ា! បងចិត្រាត្រូវការកាហ្វេឬតែ?»

នាងធ្វើដូចមិនដឹងរឿងធ្វើឱ្យចិត្តនាយក្ដៅមួហ្មង។ គេធ្វើមុខក្រញូវមិននិយាយ។ ឪពុកមានជាឧត្តមសេនីយ៍មានកេរ្តិ៍ឈ្មោះត្រូវគេចាប់វាយខ្នោះចតផ្ញើលភ្នំពេញមកធ្វើដូចមិនដឹងរឿងបានដែរ?

«កូនឯងចេញទៅសិនអមរាដា! ប៉ាមានការសំខាន់ត្រូវនិយាយគ្នា!»

នាងហាក់រារែកមុនពេលបែរខ្នងចេញទៅ។ ឪពុកហៅឃាត់វិញ៖

«កូន! កូនដា!»

«ចាំ!»

នាងបែរមកវិញដោយកែវភ្នែកស្លូតស្លប់ហើយ ឆ្លើយចោលភ្នែកមួយជុំឱ្យបានសម្លឹងមុខនាយផង។ចិត្រាធ្វើធ្មឹងដូចកាលដែលនាយទៅឈរយាមនាងរៀនភ្លេងក្បែរបង្អួច។

«កូនឯងជូនម៉ាក់ឡើងទៅលើឱ្យផុត! ប៉ាមិនហៅកុំចុះមក!»

«ចាំ!»

នាងនិយាយផងចាកចេញយឺតៗផង។

បេះដូងនាយដាច់ដោចពេលយល់ពីសេចក្ដីស្នេហាដែលនារីនេះមានមកលើខ្លួន។ ប៉ុន្តែសម្រាប់ការងារចំពោះមុខនេះ គឺនាយត្រូវតែបញ្ចប់បេសកកម្មឱ្យហើយសិន។ ស្នេហាមិនមែនជារឿងទីមួយទេសម្រាប់ប៉ូលិសម្នាក់ៗ។

មិនយូរប៉ុន្មាននាយចាប់ផ្ដើមកាត់ចិត្តចោលស្រមោលស្រីស្អាត ហើយសួរឪពុកម្នាក់នេះ៖

«ទទួលខ្ញុំមកជាអង្គរក្សលោកចង់យកខ្ញុំធ្វើសាក្សីក្នុងសំណុំរឿងដែលលោកបង្កឡើងខ្លួនឯងហើយទទួលមកដោះស្រាយដោយខ្លួនឯងដើម្បីទទួលការសើ្ងចសរសើរ! »

«ស្អីទៅដែលធ្វើឱ្យឯងគិតអ៊ីចឹង!?»

ចិត្រាលូកដៃទៅចុចបិទសោទ្វារ ព្រោះគេទទួលអារម្មណ៍ថាស្រីស្អាតនៅឈរបែរខ្នងទីនោះនៅឡើយ។

ដោតមិនអស់ចិត្ត នាយសក្តិបួន គេទាញវាំងននបិទបាំងទាំងផ្ទាំងកញ្ចក់ ហើយងាកមកញញឹមបង្កប់ក្តីឈឺចាប់ដាក់គូសន្ទនា៖

«ខ្ញុំគួរតែសង្ស័យតាំងពីដំបូងឡើយ! គួរតែដឹងថាហេតុផលអីដែលប៉ូលិសធម្មតាៗដូចខ្ញុំត្រូវបានគេហៅឱ្យមកធ្វើជាអង្គរក្សនៅផ្ទះគេ ហើយឱ្យតាមការពារកូនស្រីរបស់គេ! ហេតុអ្វីត្រូវគ្រាន់តែមានតួនាទី ធ្វើជាអង្គរក្សចាំបាច់ ឱ្យចូលស្តាប់ការជជែករបស់ពួកឧត្តមសេនីយ៍ក្នុងសំណុំក្តីមនុស្សស្រីបាត់ខ្លួន? ចុងក្រោយ លោកឱ្យខ្ញុំចូលធ្វើជាអ្នកស៊ើប គោលដៅគឺលោកចង់ឱ្យខ្ញុំធ្វើជាសាក្សីខាងលោក ហើយឈរមើលលោកចាប់ពូខ្លួនឯងដាក់គុក? »

ឱត សាម៉ុននិយាយកាត់ក្នុងសព្ទសំឡេងធម្មតា៖

«បើពូឯងគ្មានទោស តើពីណាចាប់គាត់ដាក់គុកបាន?»

«ភស្តុតាងនិងសាក្សីជាអន្ទាក់!» គេនិយាយតវ៉ាតឹងសរសៃក។

«អ៊ីចឹងឯងមានពេល៤៨ម៉ោង មុនប៉ូលិសបញ្ជូនពូឯងឡើងតុលាការ រកភស្តុតាងមក បង្ហាញថា ទឡ្ហីករណ៍របស់ប៉ូលិសជារឿងផ្លិនភ្នែក!»

ចិត្រាក្រោកឈរប្រឈមនឹងបុរសនេះ។

«ខ្ញុំដឹងច្បាស់លោកឯងដឹងច្បាស់អំពើអាក្រក់មិនអាចគ្របពីលើរឿងល្អបានទេ! ថ្ងៃដំបូង ខ្ញុំចូលមកដល់ផ្ទះនេះ! លោកឯងមានចេតនាទុកឯកសារនៅជាន់ខាងលើ គឺចង់ឱ្យខ្ញុំមើលដើម្បីឱ្យដឹងថាមនុស្សស្រីទាំងអស់មានសភាពយ៉ាងណានៅក្នុងពេលបាត់ខ្លួន! ជារៀងរាល់ពេលលោកឯងសួរនាំពីពូខ្ញុំធ្វើហាក់ដូចជាគោរពកោតសរសើរគាត់តាមពិតលោកឯងចង់ស៊ើបមើលថា តើពូខ្ញុំនិងខ្ញុំមានទំនាក់ទំនងនឹងគ្នាដែរទេ? លោកឯងប្រឌិតតាហោរា ឈ្មោះពាងឡើងមក ហើយបង្រៀនឱ្យគាត់និយាយរឿងដែលលោកឯងរៀបចំ ហើយនាំខ្ញុំទៅជួបគាត់ដើម្បីឱ្យខ្ញុំវិលវល់វង្វេង។ ពូខ្ញុំមិនដឹងរឿងអីទាំងអស់ លោកឯងប្រើកម្មវិធីរបស់មហាវីនដែលប៉ូលិសស៊ើបដឹងជាកន្លែងចាប់ស្រី! ពួកប៉ូលិសចូលនិវត្តន៍ទាំងអស់ត្រូវលោកឯងបញ្ឆោតឱ្យធ្វើរឿងនោះ ហើយចុងក្រោយលោកឯងយកតួអង្គនិស្សិតកាងសាលាឈុនរាជឱ្យទៅលែងស្រីៗចេញមកវិញ។ ពេលគ្រប់យ៉ាងដល់ដំណាក់កាលទម្លាក់លើអាណិកជន Lorenzo លោកឯងឱ្យតាពាងរត់ហើយចាត់គ្នាទៅបិទមាត់គាត់ ស្នងការRoyមានការសង្ស័យលើរឿង

នេះក៏ចេញទាំងម៉ោងបីទាបភ្លឺទៅពិនិត្យសពដោយខ្លួនឯង ព្រោះមិនទុកចិត្តមនុស្សរបស់លោក ចុងក្រោយក៏បាត់ខ្លួនដល់ពេលនេះ។ ពេលលោកឯងប្រកាសចាប់ខ្លួន Lorenzo ក៏បង្ខំអតីតប៉ូលិសគេចខ្លួនអស់នោះឱ្យខលទៅពូខ្ញុំរកជំនួយ! ពូខ្ញុំហេតុតែជឿពួកគេ គេគិតថាពួកគេមានភស្តុតាងជួយលាងទោស Lorenzo ជាកូនប្រុសពួកម៉ាកគាត់ គាត់ក៏ខំទៅតាមការណាត់ជួប!ពួកលោកឯងឃើញគាត់ពីចម្ងាយក៏សំឡេះប៉ូលិសចូលនិវត្តន៍ទាំងនោះ ហើយទម្លាក់កំហុសទាំងអស់មកលើពូខ្ញុំនិងមិត្តរបស់គាត់! សាក្សីចុងក្រោយគឺមហាវីនលោកឯងបានប្រើគេរហូតមកក្នុងការធ្វើបាប Lorenzo ចុងក្រោយលោកឯងព្រមពន្លែងគេចេញដោយគ្មានហេតុផល ហើយបណ្តោយឱ្យប៉ូលិសបក្សពួកលោកឯងឈ្មោះធីណាជាអ្នកផ្តាច់ជីវិតគេ? ល្បិចរាក់កំផែលអស់នេះមានតែពួកប៉ូលិសគ្មានសមត្ថភាពដូចពួកលោកឯងដែលរកឃើញយកមកធ្វើបាបអ្នកដទៃ!»

ឧត្តមសេនីយ៍ ទះដៃតិចៗហើយសរសើរ៖

«ឆ្លាតវៃហើយវិភាគបានល្អិនល្អន់មានលំដាប់លំដោយល្អ!»

ពាក្យសរសើរជាជំនាញរបស់មនុស្សចាស់ម្នាក់នេះហើយដែលពេលនេះនាយទទួលស្គាល់ថាវាជាការ«ចំអក»គួរឱ្យឈឺចាប់មួយ។ ប្រការនេះ ធ្វើឱ្យចិត្តនាយសក្តិបួនកាន់តែឆាបឆួល។ គេនិយាយព្នៗក្នុងចេតនាឱ្យអមរាជាបានស្តាប់ពីពុតត្បុតដ៏អន្សតិរ្យិយរបស់ឪពុកខ្លួន៖

«លោកឯងមិនត្រឹមតែជាប៉ូលិសចេះច្បាប់ហើយល្មើសច្បាប់ ថែមទាំងជាកញ្ជ្រោងកញ្ចាស់លាក់កន្ទុយ! លោកឯងប្រើប្រាស់មិត្តភ័ក្តិរបស់កូនស្រីខ្លួនឯងអ្នកនាងផានូឱ្យទៅមានគ្រោះថ្នាក់ហើយឯកមានមិត្តរបស់ខ្ញុំទម្រាំប្រថុយគ្រោះរត់មកដល់ភូមិ លោកឯងចាត់ឈុនរាជទៅរកពួកគេ ចុងក្រោយពេលអាមានខលមកប្រាប់លោកឯងដឹងទីតាំងពួកគេកាលណាឱ្យមនុស្សទៅតាមចាប់ពួកគេមិនឱ្យមកភ្នំពេញវិញបាន? លោកឯងហាមមនុស្សស្រីរងគ្រោះទាំង៤នាក់មិនឱ្យជួបប៉ូលិសនិយាយពីការពិត ពេលនេះ ពូខ្ញុំនៅក្នុងកន្លែងប៉ូលិសទាំងគ្មានកំហុស បើលោកឯងអស់ពាក្យនិយាយឆាប់ទៅសុំទោសពូខ្ញុំហើយដោះលែងគាត់ចេញមកឱត សាម៉ុន!»

ឱត សាម៉ុនសួរបញ្ច្រាសមកវិញ៖

«ជាតិចិត្រា! លោកទន្ទេញរត់មាត់ថា ពូខ្លួនត្រូវគេដាក់អន្ទាក់ ប៉ុន្តែគ្រប់យ៉ាងដែលលោកបានទន្ទេញយកមកនិយាយគឺសុទ្ធតែជា សេចក្តីកាត់ស្មានគ្មានភស្តុតាង គ្មានសាក្សីដឹងឮ! ឯណាស្នងការ Roy?ឯណាឯកមាន? ឯណា Lorenzo?ចំណែកប៉ូលិសចូលនិវត្តន៍ស្លាប់ជាង១០នាក់គឺយើងបានទៅដល់ឃើញផ្ទាល់នឹងភ្នែក ក្នុងផ្ទះមានក្រយៅដៃរបស់ពូឯងមិនប៉ូលិសម្នាក់ទៀតចូលតាមទ្វារក្រោយ ហើយក្រៅពីនាក់ស្លាប់គ្មានក្រយៅដៃអ្នកផ្សេងនោះទេ!»

គេសើចចំអកយ៉ាងវែង។ ជាស្នាមសំណើចដែល កូនប៉ូលិសម្នាក់មិនដែលហ៊ានធ្វើនៅចំពោះមុខអ្នកដែលពាក់សក្តិធំជាងខ្លួននោះទេ។ គេបានឈានដល់ចំណុចកំពូលនៃការរើបម្រះទៅហើយ ពេលនេះទៅជាស្អីក៏មិនអាចបំភាន់ចិត្តគេតទៅទៀតបានដែរ។

«ផ្ទះកើតហេតុមួយ គ្មានស្នាមក្រយៅដៃសោះ! មានតែរបស់អ្នកដែលត្រូវគេចោទ? ទាំងអស់នេះជាហេតុផលសំអាងសម្រាប់ឱ្យតុលាការបកសក្តិពួកប៉ូលិសភ្លីភ្លើដូចលោកឯង! ខ្ញុំក៏អាចធ្វើបានដូចគ្នាខ្ញុំចាប់អ្នកផ្ទះលោកឯងទៅហើយសម្លាប់ចាំខលហៅលោកឯងទៅតាមក្រោយ! ពេលនោះខ្ញុំសំអាតភស្តុតាងអស់ហើយ! វានៅសល់តែស្នាមដៃលោកឯងប៉ុណ្ណោះ តោះបើលោកឯងគ្មានហេតុផលសម្លាប់អ្នកផ្ទះ តែប៉ូលិសល្ងីល្ងើនិងយកក្រយៅដៃដែលគេរកឃើញលើអាវុធ លើជញ្ជាំងដើម្បីដាក់ទោសលោកឯង!»

លោកឱិត សាម៉ុន ហាក់មិនបានខឹងសម្បារត្រឡប់មកវិញទេ គាត់ក្រោកឡើងមកហើយដើរសំដៅមកកៀកស្មាគេ។

នេះជាសកម្មភាពដែលគាត់ធ្លាប់តែធ្វើរាល់ដង ក៏ជាសកម្មភាពដែលបានធ្វើឱ្យកូនប៉ូលិសម្នាក់មានទឹកចិត្តជាទីបំផុតហើយជឿគាត់ជាទីបំផុត។

ពេលនេះ គេរលីងរលោងហើយគ្រវាសដៃគាត់ចេញ។

«ឈប់ឆ្កិនភ្នែកទៅ នៅកន្លែងនេះមានតែយើងពីរនាក់ទេតើ!»

ឱិត សាម៉ុនដកដង្ហើម ក្នុងភាពស្ងប់ស្ងាត់ហើយបែរទៅច្រតដៃក្បែរឡេបថប់។

គាត់ហាក់បានត្រៀមខ្លួនរួចរាល់ហើយក្នុងការចាប់ផ្តើមនិយាយៈ

«បើឯងចោទខ្ញុំសម្លាប់អ្នកផ្ទះខ្លួនឯង ឯងមានក្រយៅដៃតែឯងគ្មានហេតុផលអាចនឹងបញ្ចុះបញ្ចូលឱ្យតុលាការយល់ស្របទេចិត្រា!»

សម្ដីគាត់ធ្វើឱ្យគេផ្ទុះកំហឹងជាងមុនគេគំហកវិញ៖

«ចុះចោទថាពូខ្ញុំសម្លាប់មន្ត្រីចូលនិវត្តន៍ទាំង១១នាក់លោកឯងមានហេតុផលស្អី? ពូខ្ញុំគាត់ទៅធ្វើរឿងអស់ហ្នឹងធ្វើអី?»

ឱត សាម៉ុនបំបែរកំព្យូទ័រមកបង្ហាញនាយ ធ្វើឱ្យចិត្រសម្លឹងខ្មែរពីចម្ងាយ។

បុរសចំណាស់ចាប់ផ្ដើមនិយាយ៖

«ជាយូរណាស់មកហើយ! ពូឯងធ្លាប់គិតថាចង់ឱ្យកូនប្រុសគេនឹងកូនស្រីរបស់ភីណាផ្សារសាច់ឈាម! ក្រោយមក Lorenzo បង្ហាញខ្លួននៅផ្ទះមេធាវីជំនិតនៅសហរដ្ឋអាមេរិកក្នុងនាមជាកូនប្រុសធម៌ ព្រោះក្មេងស្រីត្រូវបានគេដឹងថា មានជំងឺកំណាចនាងមិនអាចរស់បានយូរ! ក្រោយពេលនីងនីង ស្លាប់ទៅ សម្បត្តិទ្រព្យទាំងអស់របស់គ្រួសារនោះក្លាយមកជាកម្មសិទ្ធិរបស់ Lorenzo! ពូរបស់ឯងធ្លាប់បានទៅលេងពួកគេ ហើយត្រូវរងការមិនគោរពពីក្មេងប្រុសកូនធម៌នោះ! ពូឯងបានចងគំនុំគេទុកហើយរៀបចំគម្រោងការជាច្រើនបោកគេឱ្យមកកាន់ស្រុកខ្មែរ! ពូរបស់ឯងបានប្រើមនុស្សឈ្មោះដេវីដឱ្យបង្កើតតួអង្គតាពាងហើយបោកប្រាស់ទាំងសងខាងគឺបោកឱ្យ Lorenzo ព្រមជឿតាមពីរឿងមនុស្សស្រីអច្ឆរិយ៣៥នាក់កើតឆ្នាំ២០០០។ ក្រោយមកដេវីដដដែលក៏បានមកបោកប្រាស់មហាវីនឱ្យបង្កើតកម្មវិធីសមោសរពណ៌ព្រះចន្ទ! នៅពេលដែលទាញរឿងទាំងពីរឱ្យកើតឡើងទន្ទឹមគ្នាបានហើយ ពូរបស់ឯងចាប់ផ្ដើមបញ្ចុះបញ្ចូលពួកប៉ូលិសចូលនិវត្តន៍ ដែលសំងំបម្រើការនៅផ្ទះអ្នកមានទាំងបួននោះឱ្យចេញប្រតិបត្តិការ ចាប់ស្រីៗទាំងនោះក្នុងរវាងពេល៣២ម៉ោងបន្តបន្ទាប់គ្នា។ យើងមានភស្តុតាងវេរលុយជាច្រើនពីទ្រព្យសម្បត្តិ ពូរបស់ឯងឱ្យទៅ ឈ្មោះដេវីដ និងពួកប៉ូលិសចូលនិវត្តន៍! មិនតែប៉ុណ្ណោះ ដោយសារតែគាត់ធ្លាប់ជាប៉ូលិស គាត់នៅតែនៅមានកូនប៉ូលិសជាច្រើនព្រមដើរតាមនិងស្ដាប់បង្គាប់! ប្រតិបត្តិការទាំងអស់ធ្វើធ្វើឡើងដោយមានទម្រង់ដូចជាស្នាដៃរបស់ប៉ូលិសបេះបិទ គឺមានចេតនាឱ្យសមត្ថកិច្ចវិលវល់សង្ស័យលើគ្នាឯង! ចុងក្រោយបង្អស់ ពេល Lorenzo រើខ្លួនលែងរួច ពូរបស់ឯងចាប់ផ្ដើមកម្ចាត់ក្រុមប៉ូលិសចូលនិវត្តន៍ចោល!»

ចិត្រាក្រពាត់ដៃធ្វើសោះអង្គើយ។ សម្ដីលោកឌិត សាម៉ុននិយាយដូចក្មេងបៀមដៃ ដែលទើបនឹងរៀនសរសេររឿងល្ខោន។ គ្មានភាពប្រាកដនិយម គ្មានវត្ថុសំអាងត្រឹមត្រូវ ហើយចេះតែសូត្រមករូ ដូចជាកំពុងលេងសើចនឹងខ្លួន។ គេដឹងហើយថាពួខ្លួនគ្មានលុយច្រើនយ៉ាងនេះ រឹតតែគ្មានគំនិតជាមនុស្សប្រកែប្រកាន់ក្មេងរហូតដល់ចងគំនុំអ្វីនឹង Lorenzo ដល់ថ្នាក់រៀបចំគម្រោងការកក្រើកមេឃធ្វើបាបគេនោះឡើយ។ ល្ខោនទាំងនោះរៀបឡើងមក មិនស៊ីសង្វាក់ រឹតតែមិនសមថាវាស្ថិតនៅក្នុងគម្រោងការ មួយខ្សែជាមួយគ្នា។

គេនៅស្ងៀមគាត់និយាយបន្ថែម៖

«ខ្ញុំហៅឯងមកនៅក្បែរខ្ញុំ ព្រោះតាំងពីដំបូងឡើយមកខ្ញុំដឹងថាក្ដីនេះវាលើសពីសមត្ថភាពរបស់ខ្ញុំទៅហើយ! ខ្ញុំគ្រាន់តែសង្ឃឹមថាពួរបស់ឯងនឹងជួយបំភ្លឺឯងខ្លះ កាលបើគាត់ឃើញក្មួយខ្លួន ជាសមាជិកម្នាក់នៅក្នុងក្រុមក្រុមដោះស្រាយក្ដីនេះដែរ!»

គេនៅស្ងៀមគាត់និយាយបន្ត ៖

«ឯងនៅចាំបានទេចិត្រា! ខ្ញុំតែងតែរំលឹកពីឈ្មោះសេតវិទូខ្ញុំស្អប់ស្អែងគេណាស់ ខ្ញុំមិនដែលគិតទេថា គេនៅពីក្រោយរឿងទាំងអស់នេះ តែយប់មុន រដ្ឋលេខាធិការសូម៉ាស៊ីធឿន បានដាស់គ្រប់គ្នាឡើងប្រជុំទាំងម៉ោងបីទៀបភ្លឺ ខាងស៊ើបអង្កេតបច្ចេកវិទ្យាគេរកឃើញការជាប់ពាក់ព័ន្ធរបស់ពូឯងសេតវិទូនិងរឿងធំដុំមួយរបស់ឪពុកម្ដាយក្មេងស្រីទាំង៤ មេធាវីសូត្រដោយមានការទូទាត់វេរលុយប្រើក្រុមហ៊ុនរបស់អ្នកស្រីសូត្រនិស្ស័យជាភរិយារបស់ពូឯង!»

ចិត្រានិយាយកាត់ទាំងកំហឹង៖

«លោកពូអ្នកមីងរបស់ខ្ញុំជាមនុស្សរកស៊ីត្រឹមត្រូវជាមនុស្សមានកិត្តិយសក្នុងសង្គម! ប៉ូលិសអស់លោកគ្មានសមត្ថភាពធ្វើប៉ូលិសទេឌិត សាម៉ុន ពាក់សក្ដិនាំតែខ្មាសក្មេង! ល្ខោន internet ប៉ុណ្ណឹងៗសូម្បី Lorenzo និង មហាវីនសុទ្ធតែមានលទ្ធភាពលេង ហេតុអ្វីអាចង្រៃណាម្នាក់នោះវាមិនចេះលេងមកលាបពណ៌លើពូខ្ញុំ? ប៉ូលិសមិនប្រឹងស៊ើបដើម្បីការពារអ្នករងគ្រោះដែលជាអតីតប៉ូលិសដ៏មានគុណសម្បត្តិម្នាក់បែរជានាំគ្នាជាន់គាត់ថែម?»

ឱត សាម៉ុនលើកដៃអោបទ្រូងហើយជាបណ្ដើរៗទឹកមុខគាត់បញ្ចេញអាការៈឈឺចាប់។ ប្រសិនបើចិត្រាចាប់អារម្មណ៍តែបន្តិច គេនឹងដឹងថា គ្រាប់កាំភ្លើងគ្មានសំឡេងដែលបានបោលមកបំបុកទ្រូងប៉ូលិសចំណាស់ គឺមានប្រភពមកពីមាត់ទ្វារ។

«វ៉ាយវ៉ាប់បកស្រាយអស់ចិត្តហើយឬនៅ?»

សំឡេងមនុស្សដែលគេធ្លាប់ស្គាល់លាន់ឮមក មកហើយម្ចាស់កាំភ្លើងក៏ដើរមកទើមៗ ជាមួយអាវុធមានកាណុងវែងក្នុងដៃ។

«ឌុកសេណាកា?»

គេបានត្រឹមហៅឈ្មោះនេះស្ងាត់ៗក្នុងចិត្តពេលឃើញវត្តមាន ប្រធាននាយកដ្ឋានបច្ចេកវិទ្យាដែលបង្ហាញខ្លួនជាមួយជាមួយទឹកមុខរីកប៉ប្រឹម។

ចិត្រាឈរស្ទុះបចំហរមាត់ព្រោះមិនយល់ការណ៍។ យើងចាក់ទ្វារពីក្នុងច្បាស់ណាស់ គេអាចគាស់ចូលមកបាន?

ចំណែកឱត សាម៉ុនទន់ជើងដួលត្មោលនៅនឹងកែវភ្នែកតក់ស្លុតរបស់នាយ។

គេសួរខ្លួនឯង សួរហើយសួរទៀតថា គេមិនបានបាញ់ផ្កាយបីម្នាក់នេះទេ តើហេតុអ្វីអ្នកដែលទើបនឹងបង្ហាញខ្លួនបាញ់ប្រហារគាត់ធ្វើអ្វី?

«ឯងជាអ្នកបាញ់គាត់ ព្រោះគាត់ដឹងការពិតពូឯង! ឱត សាម៉ុនទៅស្រុកខ្មោចហើយ ចំណែកឯងនឹងពូឯង គ្មានអ្នកណាចេញពីទ្រុងបានជារៀងរហូត!»

ឌុកសេណាកានិយាយចប់ក៏លើកស្ទ័យកាំភ្លើងវាយមករកនាយសក្តិបួនធ្វើឱ្យគេប្រញាប់រកច្រកគេចទាំងចិត្តនៅងឿងឆ្ងល់គ្មានចម្លើយ។

«ហេតុអីទាន!»

គេស្រែកផង លូកដៃទៅលើកចូតាំងមកប្រឆាំងរងការពារអាវុធដ៏ដំណំនោះ។ ចូផ្កាមាំប៉ុនណាគង់នៅតែបែកខ្ចាយរុះរោយរាយពេញឥដ្ឋ ព្រោះតែរងស្ទ័យកាំភ្លើងមិនបានចុះទម្រាំក្បាលខ្លួនដែលផ្ទុកដោយខួរនិងលោហិត?

នាយលើកកំភួនដៃស្ដាំរងខ្ទាច់ធ្វើឱ្យឧកសេណាកាចោលអាវុធមកជាលើកទីបី ទាំងញញឹមជូរចត់៖

«ដៃអ្នែងហ្នឹងអ្វីបំបែកកញ្ចក់ឡានអញអាកូនត្រេន?»

បើប៉ូលិសចំណាស់នេះដឹងថា គេអាចប្រើកែងដៃបុកទម្លាយកញ្ចក់ឡានទំនើបបានហេតុអ្វីគាត់មិនព្រមគិតផងថា គេគង់តែអាចប្រើវាបំបាក់កាំភ្លើងវែងនេះបានដូចគ្នា?

ចិត្រាដឹងថាខ្លួនឯងជាប៉ូលិសស្ទើរពិសោធ ឆេវឆាវ គំនិតមិនជ្រៅមិនទូលាយខ្វះចិត្តសាស្ត្រដើម្បីជីកយកឫសគល់ នៃបណ្ដារឿងរ៉ាវចាក់ស្រេះនានា គេច្បាស់ណាស់មិនអីបន្តិចណាទេអំពីបំណងឧកសេណាកានិងហេតុផលដែលតានេះនៅសុខៗមកបង្ហាញកាយ កណ្ដាលផ្លូវហើយបាញ់ប្រហារឱតសាម៉ុន? ដូច្នេះគេពិតជាមិនអាចដេកដួលទាំងអោបជាប់នូវសេចក្ដីងឿងឆ្ងល់ទៅជាមួយឡើយ អ្វីដែលនាយសក្ដិបួនចំណាប់ជាងគេគឺប្ដូរស្មៀតទាន់ពេលបញ្ចេញកម្លាំងទាន់សភាពការណ៍។

គេរលាស់ដៃមកច្បាមដណ្ដើមយកកាំភ្លើង....

ក្នុងពេលដែលផ្នែកទាំងសងខាងនៃអាវុធវែងត្រូវចែកគ្នាគ្រប់គ្រងដោយភាគីទាំង២ ឧកសេណាកាចាប់ផ្ដើមប្រើកម្លាំងខ្លាំងជាងមុនប្រាថ្នា ប្រទាញដណ្ដើមយកមកវិញ។

«ហេតុអីមិនបញ្ជូនតានេះទៅតុលាការ? ហេតុអ្វីបាញ់គាត់!»

ឧកសេណាកាញញឹមហើយចុងក្រោយគាត់កេះកៃ ព្រោះកាណុងគឺនៅខាងអ្នកសួរ។

រាងកាយនាយសក្ដិបួនរបូតជំហរបើុងថយក្រោយផ្ងារគ្រាំមួយទំហឹងកូនប្រុសទៅលើសាឡុងធំ។

គេមិនដឹងឈឺមិនដឹងក្ដៅ គ្រាន់តែមានអារម្មណ៍ឈៀបៗលើទ្រូង ហើយជំហរបាត់ត្មោលលែងឈរបាន។ នេះឬអារម្មណ៍ត្រូវគ្រាប់កាំភ្លើងដែលត្រូវមួយកន្លែងសោះ វាអាចបង្វាំងរាងកាយទាំងមូលឱ្យគាំងក្រោកលែងរួច? គេសួរខ្លួនឯងសួរហើយសួរទៀត។

ប៉ូលិសវិកលមកពីណាមិនដឹងរឿងម្នាក់នេះ បាញ់យើងចំកន្លែងស្លាប់ ឱ្យយើងស្លាប់ទៅទាំងមិនបានរកយុត្តិធម៌លាងភាពស្អាតស្អំដណ្ដើមកេរ្ដិ៍ឈ្មោះពូយើងមកវិញ?

គេនៅបើកភ្នែកឆ្វក់ៗសម្លឹងម្ចាស់កាំភ្លើងដែលអោនមកមើលដោយសប្បាយចិត្ត។

«ហេតុអី?»

នេះជាសម្ដីពីរម៉ាត់គត់ដែលគេអាចនិយាយបាន ក្នុងចំណោមសំណួររយពាន់ទៀត។ បុរសនោះមិនឆ្លើយ ប៉ុន្តែគេបែរជានិយាយអ្វីផ្សេង៖

«បើកូនយើងនៅរស់! វាធំប៉ុនឯងដែរហើយ!»

ចិត្រាចងចិញ្ចើម។ បុរសនេះជាអ្នកសិក្សាល្បីឈ្មោះមានប្រវត្តិមកពីប្រទេសអាល្លឺម៉ង់។ គេមានរឿងរ៉ាវអ្វីបានជាមកបង្ហាញខ្លួនហើយនិយាយស្ដីឡប់ៗគ្មានក្បាលកន្ទុយនៅទីនេះ?

«យើងមិនចង់បាញ់ឯងទេ! យើងគ្រាន់តែចង់ឱ្យវានោះទៅឋានខ្មោច!»

គេងាកទៅរកឱត សាម៉ុន ដែលដេកដួលហើយគាត់ចាប់ផ្ដើមកម្រើកតិចៗ ហាក់ដឹងខ្លួនមកវិញបន្ទាប់ពីបេះដូងបានត្រូវគាំងមួយខណៈ ព្រោះកម្លាំងគ្រាប់សំណ។

ឃើញឱត សាម៉ុនវារប្រវេប្រវា ឌុកសេណាកាបែរទិសដៅទៅរកគាត់។

«ឯងនៅពីក្រោយរឿងអស់នេះ?»

ឱត សាម៉ុនសួរខ្សាវៗ ធ្វើឱ្យឌុកសេណាកាស្ពោះទឹកមាត់ហើយនិយាយខ្សឹបៗម៉ាត់ៗ៖

«ចូលចិត្តដឹងការពិត ពេលជិតដាច់ខ្យល់ងាប់ម៉េះ អ្ហះអាល្ងង់?»

ចិត្រាកាន់តែវិលវល់។ គេបើកភ្នែកភ្លឹះៗផ្ទៀងស្ដាប់ពេលដែលរាងកាយហាក់មិនអាចកម្រើកបាន។

«កូនប្រុសឯងស្លាប់៨ឆ្នាំហើយ! ឯងនៅតែចងគំនុំកើត? ឯងគិតថាយើងជាអ្នកធ្វើឱ្យវាស្លាប់?»

ឌុកសេណាកាក្រហមភ្នែក។ បុរសជើងឆើតខាងInternetម្នាក់នេះមិនឆ្លើយនឹងសំណួរបែរជានិយាយបន្ថែមដូចនិយាយឱ្យខ្លួនឯងស្ដាប់៖

«ឯងមិនដែលមានកូនប្រុស! ឯងមិនដែលឃើញកូនឯងជាកំពូលជើងឯក ដែលអាចធ្វើការស្មើមនុស្សចាស់នៅពេលវាទើបតែមានអាយុ១៨ឆ្នាំ! ឯងមិនដែលអង្គុយក្បែរវាជជែកពីរឿង

អាថ៌កំបាំងនៃបណ្តាញinternetរាល់យប់ ហើយយប់មួយស្រាប់តែវាលែងបានវិលមកផ្ទះ! ឪវាដែលកំពុងដេកអោបខ្នើយរង់ចាំវា ស្រាប់តែទទួលទូរសព្ទមកថា វាស្លាប់ក្នុងគុកហើយ!»

«កូនឯងសម្លាប់ខ្លួនជាកំហុសយើង? កូនឯងធ្វើខុសព្រោះឪវាមួយថ្ងៃៗមិនដឹងល្អអាក្រក់មោទនភាពនិងអាល្បែងhackerអស់នេះផ្ទុងផ្តើមបង្ហំកូនឱ្យធ្វើអ្វីដែលមិនសមនឹងវាធ្វើ ចុងក្រោយកូនឯងបានជ្រុលខ្លួនធ្វើខុស ឯងនៅមិនព្រមលើកទឹកចិត្តឱ្យវាកែខ្លួនបែរជាបន្ទោសអ្នកដែលអនុវត្តច្បាប់! កូនប្រុសត្រូវឯងទំយើ ដើរផ្លូវខុសរហូតដល់ហ៊ានរៀបអាវុធកូដ បំផ្លាញប្រព័ន្ធការពារគណនេយ្យធនាគារជិតបានសម្រេច! វិបត្តិហិរញ្ញវត្ថុដែលនឹងប៉ះពាល់យ៉ាងដំណំទៅដល់វិស័យធនាគារទាំងមូល តើអ្នកណាទទួលខុសត្រូវ?»

ឱត សាម៉ុនតបវិញដោយស្អកស្អាះ

សម្តីរបស់ឱត សាម៉ុន ហាក់បីដូចជាមិនបានត្រូវរបួស ហាក់បីដូចជាមិនបានភ្ញាក់ផ្អើលដែលឧកសេណាកាបង្ហាញខ្លួន ហាក់បីដូចជា មិនបានគិតថាវេលានេះអវសានវាទរបស់ខ្លួនសោះ?

នេះជាអារម្មណ៍របស់ចិត្រាដែលដេកស្តាប់ ប៉ុន្តែខាងឧកសេណាកាវិញ គាត់ទំនងជាកំពុងរំជួលចិត្តពេកទេដឹងបានជា មិនបានយកចិត្តទុកដាក់គិតពីឈរសើច។

«អ្នកទាំងពីរមានរឿងអីជាមួយគ្នាហេតុអី អូសខ្ញុំចូលជាមួយ! ឧត្តមសេនីយ៍ឧកសេណាកា ខ្ញុំត្រូវការរស់ខ្ញុំត្រូវការលោងឈ្មោះឱ្យពូ? រឿងស្លាប់របស់កូនប្រុសលោកខ្ញុំមិនបានពាក់ព័ន្ធទេ! កុំអូសខ្ញុំចូលរួម!»

ឱត សាម៉ុនមិនរវល់នឹងចិត្រា គាត់បែរជាបន្តសម្តីទៅកាន់ខ្មាន់កាំភ្លើង៖

«រឿងចាប់កូនស្រីអ្នកមានឯងជាមេខ្លោង?»

ចិត្រានៅស្ងៀមបាត់មាត់ដូចគេចុក ពេលឮសំណួរនេះ។ ឧក សេណាកាសើចតិចៗជាមួយសូរសំឡេងសុភាពរាបសាររបស់គាត់។

សម្រាប់ចិត្រា ប្រសិនពេលនេះម៉ោងនេះ មិនបានដេកបៀមគ្រាប់សំណៃដោយដៃគាត់ ក៏ដូចជាបានឃើញទិដ្ឋភាពនៅនឹងកន្លែងដោយផ្ទាល់ភ្នែក គេគ្មានថ្ងៃជឿទេថាអ្នកជំនាញបណ្តាញសម្ងាត់និងជាមេប៉ូលិសជាន់ខ្ពស់ម្នាក់គឺជាឃាតករឈាមត្រជាក់អាចលើកកាំភ្លើងបាញ់សូម្បីតែប៉ូលិសដូចគ្នាបានដូច្នេះឡើយ។

សំឡេងឱតសាម៉ុននិយាយបន្ថែម៖

«នៅពេលកូនលោកពិនមឿនបាត់ខ្លួនទៅ លេខារបស់នាងឈ្មោះដេវីដត្រូវបានសួរចម្លើយដោយប៉ូលិស! ចម្លើយរបស់គេមានលក្ខណៈគួរឱ្យសង្ស័យច្រើនកន្លែង ដូច្នេះហើយការរស់នៅរបស់គេស្ថិតក្នុងកែវភ្នែកប៉ូលិសជានិច្ច! មិនយូរប៉ុន្មានយើងបានរកឃើញដេវីដម្នាក់ទៀតបង្ហាញខ្លួននៅក្បែរម្ចាស់រាត្រីសមោសរមហាវីន ដេវីដដដែលនោះក៏បានចូលទៅពាក់ព័ន្ធជាមួយ Lorenzo ទៀត! រឿងដែលសំខាន់គឺដេវីដនិងដាវីដពីរនាក់នោះមានទំនាក់ទំនងជាមួយគ្នា!»

ចិត្រាបើកភ្នែកធំៗ។ បានន័យថាតាំងពីអ្នកបាត់ខ្លួនទីបីគឺនាងពិនណាកូនស្រីរបស់ពិនមឿនប៉ូលិសរកបានតម្រុយមកទុកក្នុងដៃរួចទៅហើយ? ហេតុអ្វីខ្លួនមិនដឹងអ្វីសោះ ហើយហេតុអ្វីប៉ូលិសសុខចិត្ត រង់ចាំរហូតដល់មានអ្នកបាត់ខ្លួនទីប្រាំកើតឡើង?

«អាចង្រៃឯងល្ងង់កប់ដី ត្រូវរធ្វើដូចឆ្លាតអីអ្ហា បើជិតទៅឋានខ្មោចហើយហ្នឹង?»

ឱុកសេណាកាព្រមានទាំងក្រអឺត ទុកឱ្យឱត សាម៉ុននិយាយបន្ត៖

«ឬមួយសូម្បីយើងជិតទៅជាខ្មោចហើយ ក៏ឯងមិនហ៊ានសារភាពការពិតដែរ?!»

ឱុកសេណាកា នៅស្ងៀមគិតចុះឡើង។ ចំណែកចិត្រាវិញបេះដូងលោតឱុកដាក់ដៃអោបមុខរបួស ភ្លេចគិតពីឈាមដែលហូរចេញមករឹមៗនិងស្នាមផ្សារក្ដៅឆួល។

លោកឱតសាម៉ុនប្រែខ្លួនទាំងឈឺចាប់ តែគត់នៅប្រឹងប្រកែកតវ៉ាជាមួយប៉ូលិសពាល៖

«ឯងប្រើបងប្អូនភ្លោះពីនាក់ដែលមានឈ្មោះដូចតែមុខមិនដូចជាមនុស្សរបស់ឯងតាំងពីដើមរៀងមក! ការងារម្នាក់ជាអ្នកកៀរគរពួកមន្ត្រីដែលធ្លាប់ស្មោះនឹងសេតវិទូឱ្យទៅសំងំលាក់ខ្លួននៅបណ្ដាផ្ទះកូនស្រីអភិជនដែលពួកឯងបម្រុងចាប់! ឯងនាំខ្ញុំនិងឧត្ដមសេនីយ៍ពីរនាក់ទៀតទៅជួបសេតវិទូដល់ផ្ទះកាលពីខែមុន ដើម្បីអាត់វីដេអូនិងរូបបំភ័ន្តភ្នែកកុហកប៉ូលិសចូលនិវត្តន៍ទាំងអស់ថា យើងទាំងប្រាំសុទ្ធតែមានចំណែកនៅក្នុងគម្រោងការចាប់កូនស្រីៗអ្នកមានទាំង៤នេះដែរ! ពេលពួកគេធ្វើបានមួយករណីៗឯងក៏យកប៉ូលិសចូលនិវត្តន៍ទាំងនោះទៅលាក់មួយកន្លែងជុំគ្នាធ្វើដូចជាសភាពការណ៍មិនទាន់អាចឱ្យពួកគេចេញក្រៅ! ឯងដកទូរ

សព្វ និងផ្តល់អាហារគ្រប់គ្រាន់ដល់ពួកគេ ដូចដែលឯងបានធ្វើលើស្រីៗទាំងនោះដែរ! ចុងក្រោយឯងបោកប្រាស់ប៉ូលិសឈ្មោះសុខាឱ្យទាក់ទងទៅរកសេតវិទូហើយឯងដើរមុនមួយជំហានសម្លាប់សាក្សីឈ្មោះសុខាចោល ដើម្បីទម្លាក់រឿងហេតុសព្វសារពើពើលើស្មាសេតវិទូ! ឯងឱ្យឈ្មោះដេវីដជាជំនួយការផ្ទះពិនមឿនទៅបង្ហាញមុខពេលសុខាជិតស្លាប់ដូច្នេះម្នាក់នោះក៏សរសេរឈ្មោះគេទុកឱ្យសេតវិទូ ក្នុងករណីសេតវិទូប្រាប់រឿងនេះដល់ប៉ូលិស ឯងនឹងមានលេសថាដេវីដកំពុងនៅក្នុងគុក ធ្វើម៉េចចេញទៅសម្លាប់មនុស្សបាន? ដូច្នេះកំហុសប៉ូលិសចូលនិវត្តន៍នឹងកាន់តែធ្ងន់ធ្ងរ!»

«ពូយើងធ្វើស្អីឯង?»

ចិត្រាស្រែកសួរទាំងត្រដរក្រោកឡើងមកបានវិញភ្លេចអស់អារម្មណ៍បៀមគ្រាប់សំណទាំងអំបាលម៉ាន។ បេះដូងកូនប៉ូលិសលោតក្តុកក្តាក់នៅចំពោះការលាតត្រដាងចេញនវអំពើល្មើសរបស់ជនដ៏មានសក្តិយសនិងមានចំណេះជំនាញគួរឱ្យកោតសរសើរម្នាក់នេះ។ គេនៅតែរកមិនឃើញមូលហេតុដែលឧកសេណាកាត្រូវបំផ្លាញខ្លួនឯងគ្រានតែនឹងរៀបចំល្ខោននេះឡើង។

គេមិនទាន់ឮបុរសដៃឆើតខាងលេខកូដនិយាយអ្វីផងឱត សាម៉ុននិយាយបន្ថែមៈ

«គោលដៅវាពុំមែនពូឯងទេ! គឺខ្ញុំ! វាគ្រាន់តែអូសសេតវិទូមកចូលរួម ហើយចុងក្រោយវាមកដល់ទីនេះបាញ់សម្លាប់ខ្ញុំ រួចហើយចាត់ទុកថា ឯងជាអ្នកធ្វើជាហេតុធ្វើឱ្យសេតវិទូនិងឯងរងទោសមនុស្សឃាតនេះជំនួសវា!»

«និយាយអស់ចិត្តហើយ យល់បានច្បាស់ហើយ? អ៊ីចឹងក៏ដល់ពេលហើយ!»

ឧក សេណាកា បង្វែរកាណុងកាំភ្លើងមកចំឱត សាម៉ុនសាជាថ្មី  ជាហេតុធ្វើឱ្យចិត្រានឹកសោកស្តាយជាអនេកចំពោះកំហុសរបស់ខ្លួនដែលធ្វើប៉ូលិសយូរហើយស្មានថាខ្លួនឆ្លាតដែរ តែចុងក្រោយនៅតែរាក់កំផែល។

ភាគទី៤៩

ឧកសេណាកា មានបំណងប្រើខ្លួនឱ្យទទួលថាជាអ្នកសម្លាប់ឱត សាម៉ុន ព្រោះតែខឹងគាត់ចាប់ពូខ្លួនសេតវិទូ។ ល្ខោននេះមកដល់ទីបញ្ចប់ហើយ គឺមនុស្សអាក្រក់ពាក់ស្រោមមុខជាមន្ត្រីល្អពេលនេះកំពុងមានប្រៀប។ បន្តិចទៀតគេបញ្ជូនឱត សាម៉ុនដែលដឹងរឿងគ្រប់យ៉ាងទៅឋាននរកហើយបង្ហើយខ្លួនម្នាក់ទៀតទុកថាខ្លួនសម្លាប់ឱត សាម៉ុន ព្រោះតែខឹងគាត់ចាប់ពូក្រោយមកមិនដឹងធ្វើម៉េចក៏សម្លាប់ខ្លួនឯងតាមក្រោយ ចំណែកអ្នកដែលត្រូវជាប់ចោទជារឿងរហូតនោះគឺលោកពូរបស់ខ្លួន។

ឱត សាម៉ុនស្រាប់តែសើចក្អាកក្អាយធ្វើឱ្យឧកសេណាកាស្រលាំងកាំង។ ស្នូរបន្ទុះស្រួយស្រើបមួយគ្រាប់គត់ ធ្វើឱ្យកាំភ្លើងជននោះរបូតធ្លាក់ហើយឧកសេណាកាអោបកំភួនដៃដែលហូរឈាមច្រោកស្រែកដោយឈឺចាប់។

នៅក្បែរវាំងននមាត់បង្អួច ឯកមានបង្ហាញខ្លួនហើយរុញបើកបង្អួចកញ្ចក់ផ្លោះចូលមកក្នុង។

ឱត សាម៉ុនក្រោកឈរឡើងកណ្ដាលបន្ទប់ ហាក់បីដូចជាគ្រប់យ៉ាងត្រូវបានរៀបចំហើយជាស្រេច។គាត់ហាក់ដូចជាគ្មានរបួសជ្រៅទេ ក្នុងអ្វីដែលចិត្រាមើលឃើញពេលនេះ។

ឧកសេណាកាសម្លឹងឯកមាន ទាំងជ្រួលច្របល់៖

«ម៉េចក៏ឯងនៅទីនេះបាន?»

ឯកមានមិនមាត់ គេសម្លឹងមកចិត្រាហើយងាកភ្នង់ ម្ចាស់សំណួរជាប់ បណ្ដាលឱ្យឧកសេណាកា ស្រែកទាំងកំហឹង៖

«ពួកឯងចូលមក!»

គ្មានអ្នកណាទាំងអស់។ ឧកសេណាកាកាន់តែកើតក្ដីងឿងឆ្ងល់ ធ្វើឱ្យឱត សាម៉ុនញញឹមដៃអង្អែលកាំភ្លើងខ្លី៖

«នៅថ្ងៃដែលឯងបញ្ជូនមនុស្សមក ចាប់កូនស្រីខ្ញុំហើយបញ្ឆោតចិត្រាអង្គរក្សអមរាជាឱ្យចេញទៅរកឯកមាន ឯងបានប្រាប់ខ្ញុំជាស្រេចហើយថា ឯងបានទិញមនុស្សរបស់ខ្ញុំទុកប្រើក្នុងដៃឯង! អ្នកលាងឡានរបស់ខ្ញុំឈ្មោះ ហឿនបានផ្ដាច់ទំនាក់ទំនងទូរសព្ទក្នុងផ្ទះខ្ញុំទាំងអស់រួមទាំងលួចដាក់កូដបិទសេវា ទូរសព្ទខ្ញុំនិងឯកមាន! ឈុនរាជនិងឯកមានព្រមទាំងផានូចេញទៅ យើងដឹងថា មនុស្សរបស់ឯងនៅក្នុងផ្ទះយើងជាអ្នកឱ្យព័ត៌មានឯង! យើងបានរកឃើញ

លំហូរលុយមួយសន្ទឹកដែលឯងបានផ្ដល់ឱ្យអ្នកលាងឡានម្នាក់នោះ តាមរយៈAccរបស់មនុស្សឈ្មោះផ្សេង តែវាមានកូដបន្លំគណនេយ្យចេញពីប្រភពតែមួយគត់! ក៏ជាកូដដដែលដែលឯងបានប្រើទៅលើនាយPravidនិងជនជាតិអាល្លឺម៉ង់ ដើម្បីជួយឱ្យភាគី Lorenzo ឈ្នះ!»

ចិត្រាហួសចិត្ត។ រឹតតែអស្ចារ្យគេមិនដឹងទេថា ឯកមាននិងឱត សាម៉ុនបានទាក់ទងគ្នាក្នុងសំណុំរឿងនេះរហូតមក។ គេនៅស្ងៀមតែគេដឹងថាពូខ្លួនកំពុងមានសង្ឃឹម។

ឧកសេណាកាសើចក្អាកក្អាយ៖

«ហើយចុះឯងទិញអាកូនចៅស្នើរភ្លើងនេះប៉ុន្មានដែរឱត សាម៉ុនឱ្យវាធ្វើរនុកក្នុងឱ្យឯង? »

គាត់សំដៅឯកមានធ្វើឱ្យHackerក្រហមមុខងាំងនិយាយតវ៉ា៖

«យើងមិនមែនជាជ្រូកដែលត្រូវគេទិញទេវ៉ឺ! រហូតដល់យើងបិះស្លាប់នៅនឹងខេត្តក្រោមស្នាដៃបក្សពួករបស់ឯង យើងនៅតែជឿថាឱត សាម៉ុនកសាងរឿងអស់ទាំងនេះឡើង ព្រោះយើងបានខលមកជួបពួហឿនឱ្យដំណឹងស្រាប់តែមានគេតាមរកសម្លាប់យើងនិងផានូទៀត! យើងដឹងថាអាចង្រៃhackerណាម្នាក់ប្រាកដជាពូកែផុតលេខនៅស្រុកខ្មែរនេះ ដែលវាអាចបង្កើតVirusផ្ដាច់ទំនាក់ទំនងផ្សេងៗបានភ្លាមៗដូច្នេះយើងបានជ្រកលើដំបូលខ្ពស់បង្អស់នៃតំបន់បនស្រីមួយដែលឯងដេកស្មានមួយជាតិក៏ស្មានមិនដល់ដែរថា រលកសញ្ញានៅទីនោះមិនអាចឱ្យឯងគ្រប់ដណ្ដប់យើងបាន ប៉ុន្តែយើងអាចរកឃើញកូដនិងទីតាំងរបស់ឯង! ឈុនរាជគឺជាប្រធាននិស្សិតដែលមានបណ្ដាញនិស្សិតជាច្រើនជំនាន់នៅក្នុងដៃ! គេអាចជួយយើងឱ្យរកបាន ប្រវត្តិទាំងអស់របស់និស្សិតផ្នែកHackeហើយក្នុងនោះយើងរកបានថ្ងៃខែដែលកូនឯងស្លាប់ក្នុងគុក! វាជាលេខការពារដែលអាចជួយយើងឱ្យជ្រែកចូលទិន្នន័យរបស់ឯងបានដោយជោគជ័យ»

ទោះបីឯកមានស្នើរភ្លើង តែចុងក្រោយមនុស្សស្នើរភ្លើងម្នាក់នេះហើយដែលបានចូលមកបញ្ចប់មេអគ្គីដូចជាគេ។ នេះដូចពាក្យខ្មែរថា ឈាមស្រែកស្បែកហៅ។ ឧកសេណាកាកាន់តែចាញ់កាន់តែសើច។ គាត់និយាយទាំងញាក់ចិញ្ចើមសម្លឹងប៉ូលិសសក្តិបួនទាំងទ្វេរួមទាំងបុរសចំណាស់ម្ចាស់បន្ទប់ ហើយចុងក្រោយគាត់និយាយ៖

«ពួកឯងដឹង ក៏មិនឃើញមានស្នីបានការ! ភស្តុតាងមានអត់? យើងចុចបំផ្លាញវាអស់ដូចដុំអំបិលចោលទៅក្នុងទឹកបាន! ចំណែកឯងដឹងឯងយកមាត់ទៅនិយាយដាក់គុកយើងបានដែរពួកអាបំបង់បាយ? អ្ហះអាhackerលំៗ? »

ឯកមានក្រហមមុខ។ ឧកសេណាកានិយាយបន្តះ

«ឯងជាកូនចៅយើង ឯងមានស្នីមកស៊ូជាមួយមេខ្លួនឯងបាន! ឯងចេញអាក្បាច់hackedលេខឆ្នោតហ្នឹងហ្អី មិនចំណាយយកទៅលេងសៀកបោកក្មេងទៅ ក្រែងវាបានលុយដោះបំណុល?»

គាត់ងាកមកចិត្រាះ

«ឯងស្គាល់ហើយ ពាក្យថាឆ្លាតមួយជីវិតមកល្ងង់មួយដង្ហើមអាកូនត្រេន! អ្ហែងមានដៃទាំងពីរមាំជាងដែក នៅសាលាបង្វឹកអ្ហែងខ្លាំងជាងគេ វាយដែកបាក់ វាយឈើបែកវាយភ្លើងរលត់! តែវាមិនមែនមានន័យថា ធ្វើប៉ូលិសល្អ ត្រូវមានកែងឆែះធន់អ្ហែងនេះទេអាកូនត្រេន! គេត្រូវការខួរក្បាល! ពេលនេះ អញនៅតែអញ ពួកអ្ហែងទៅនិយាយអីក៏គ្មានបានការ! រឿងឧក្រិដ្ឋកម្មក្នុងលំហ បើសំអាតស្អាតហើយ គឺវាស្អាតជារៀងរហូត! ចំណែកករណីពូរបស់ឯង សេតវិទូ ភស្តុតាងប្រឡាក់ប្រតាកពេញដៃ ទោះបីគ្មានអ្នកណាជឿ ក៏ភស្តុតាងនៅតែជាភស្តុតាងសូម្បីតុលាការក៏គ្មានវិធីជួយពូឯងដែរ!»

ចិត្រាខាំមាត់តែនាយធ្វើអ្វីបាន?

«សំឡេងពូឯង ខ្ញុំថតជាប់ទាំងអស់!»

អមរាដាបង្ហាញខ្លួន ហើយលើទូរសព្ទមកទាំងមុខក្រហមឆៅ។

ឧកសេណាកាសើចក្អាកក្អាយបំបាត់អំណរក្នុងចិត្តជាតិចិត្រា។ ពួកគេបណ្តោយឱ្យបុរស នេះសើចចប់ទើបឯកមានសួរះ

«រៀនHackerដល់កំពូលត្រូវក្លាយជាមនុស្សមិនគ្រប់ទឹកអ៊ីចឹង?»

«ពួកអ្វែងហ្នឹងហើយមិនគ្រប់ទឹក! អញស្ទាងល្អណាស់! សម្តីថតសំឡេង យកទៅបង្ហាញតុលាការមានតែក្នុងកុនទេ! ឯងអាចបង្ខំខ្ញុំឱ្យនិយាយឯងអាចព្រួតគ្នាវាយដំខ្ញុំ! ភស្តុតាងសំឡេងយកទៅធ្វើចំណាត់ការច្បាប់ឯងដេកស្រមៃទៅ!»

ឱិត សាម៉ុននិយាយមួយៗកាត់ផ្តាច់ការស្មុគចិត្តរបស់ក្រុមយុវវ័យទាំងបី៖

«មិនបាច់ភ័យទេឧុកសេណាកា! នៅទៀបក្លីយប់មិញ រដ្ឋលេខាធិការគ្រាន់តែសាកឯងប៉ុណ្ណោះ ខាងស៊ើបអង្កេតបច្ចេកវិទ្យាគេរកឃើញការជាប់ពាក់ព័ន្ធរបស់ សេតវិទូនិងរឿងទំនាស់ ចរន្តសាច់ប្រាក់រវាង ឪពុកម្តាយក្មេងស្រីទាំង៤ដោយមានការទូទាត់វេលុយ ប្រើក្រុមហ៊ុនច្បាប់របស់អ្នកស្រីសូត្រនិស្ស័យជាភរិយាសេតវិទូ! តាមពិតទាំងនេះជាការបង្កើតភស្តុតាងក្លែងក្លាយឡើងដាក់បន្ទុកលើគ្រួសារប៉ូលិសចូលនិវត្តន៍ឱ្យពាក់ព័ន្ធក្នុងរឿធ្វើបាប Lorenzo! ប្រសិនឯងពិតជាប៉ូលិសស្មោះត្រង់ធ្វើការយុត្តិធម៌ តាមសមត្ថភាពឯង ឯងនឹងអាចរកឃើញថាតួលេខអស់ទាំងនោះ គឺក្លែងក្លាយវាមិនពិតនោះទេ! វាជាទិន្នន័យប្រឌិតឡើងដើម្បីធ្វើបាបសេតវិទូ!»

ចិត្រានិងឯកមានរីកមុខដូចគ្រាប់ជី ចំណែកឱិត សាម៉ុនទៅដកហូតយកទូរសព្ទពីដៃកូនស្រីមកកាន់ហើយនិយាយបន្ថែម៖

«បន្ថែមសំឡេងនេះទៀត គ្រប់យ៉ាងរឹតតែធ្ងន់! ហើយមួយទៀត ស្នងការ Roy ក៏ប្រហែលជាមានសាក្សីអាចនិយាយរឿងរបស់លោកបានច្រើនទៀតដែរ កុំព្រួយខ្លាចតុលាការពិបាកកាត់ក្តីលោក!»

ឧុកសាណាកាគ្រវីក្បាលហួសចិត្ត៖

«ឯងទៅសង្ឃឹមអីមិនសង្ឃឹម សង្ឃឹមអាក្មេងម៉ូណោះ វាទៅស៊ីស្នូលដីបាត់ហើយមិនដឹងថ្មើរហ្នឹង?»

ចិត្រាងាកមើលមុខឱិត សាម៉ុន ធ្វើឱ្យបុរសចំណាស់ញញឹម ដោះអាវគាត់ចេញជាមួយនឹងសម្តីបញ្ជា៖

«ចិត្រាដោះអាវឯងចេញទៅ!»

គេត្រូវបានម្ដាយឱ្យពាក់អាវថ្មីនេះតាំងពីផ្ទះមក។ គេមិននឹកស្មានទេថា ឱត សាម៉ុនបានឱ្យអាវការពារគ្រាប់នេះទៅម្ដាយគេ ដើម្បីឱ្យគេការពារជីវិតពីគ្រាប់កាំភ្លើងរបស់ឌុក សេណាកា។

ឧត្តមសេនីយ៍ម្នាក់នេះ បានរៀបឆាកល្ខោននេះឡើង គេទើបនឹងយល់ការណ៍ហើយមានអារម្មណ៍អៀនខ្មាស និងយល់ថាខ្លួនឯងពិតជាកំពូលមនុស្សល្ងង់លើលោក។

ឱត សាម៉ុនវាចាបន្ថែម៖

«អាវខ្ញុំការពារគ្រាប់បានល្អ! អាវលោកសក្តិបួនជាតិចិត្រាក៏ដូចគ្នា! ខ្ញុំកុម្ម៉ង់មកច្រើនណាស់ មហាវីនក៏មាន ហើយស្នងការRoyក៏គេប្រហែលជាមិនភ្លេចពាក់វាដែរមើលទៅ!»

ឌុក សេណាកាថ្លោះទឹកមុខ.....

វគ្គ ស្នងការ Roy

គ្មានអ្នកណាយល់ពីអារម្មណ៍របស់មនុស្សម្នាក់ដែលដៃជាប់ខ្នោះ ហើយភ្នែកទាំងគូផ្តោតលើមនុស្សស្រីស្អាតម្នាក់ដែលមានអាថ៌កំបាំងដូចខ្មោចព្រាយចោមព័ទ្ធជាមួយកាយវិការប្លែកៗ។

នាងពិតជាកាន់កាំភ្លើងស្ទាត់ជាងដែលអ្នកផងគិត ហើយពេលនេះទៀតកាណុងកាំភ្លើងទំនើបនេះបានបុកផ្ទឹបមកលើទ្រូងនាយ។

ប្រសិនបើនាងកេះកៃវាតែបន្តិច ទ្រូងស្នងការនេះនឹងធ្លុះហើយគ្រប់យ៉ាងនឹងចប់។

«នាងចាំបាច់ត្រូវសម្លាប់មនុស្សបញ្ចប់អនាគតខ្លួនឯងដែរទេ?»

«មនុស្សដូចខ្ញុំ ស្អីក៏អាចធ្វើបានដែរស្នងការ Roy!»

នាយងើបមុខទៅថើបបបូរមាត់នាង ធ្វើឱ្យនាងប្រើដៃឆ្វេងសងមកវិញផាច់។

គេនៅតែញញឹមក្នុងសភាពព្រាននារី ទោះដៃទាំងពីរកំពុងជាប់ដូចគេចងស្លាបសេកទៅក្រោយ។ពេលនាងសម្លក់ធ្វើមុខមាំ ហើយបែរមុខចេញដៃម្ខាងភ្ជង់នាយដៃម្ខាង ចុចទូរសព្ទ។

ស្នងការផ្តើមខ្សឹបខ្សៀវ៖

«នាងរង់ចាំដំណឹងឌុក សេណាកា?»

ស្រីស្អាតងើបមុខមកវិញមួយរំពេច ហើយសម្លឹងស្នងការហាក់តក់ស្លុត។ ជាមួយប្រស្រីភ្នែករីកធំឡើងៗហាក់កំពុងជ្រួលចិត្តជាខ្លាំង នាងខាំមាត់គំហកៈ

«សួរថាលោកឯងដឹងរឿងស្អីខ្លះ?»

ស្នងការRoyហារមាត់ធំៗ សើចចំអកដល់ភាពតក់ស្លុតរបស់នាង។ គេសើចហើយសើចទៀតបញ្ឈឺអារម្មណ៍តក្កមារបស់នារីនេះ រហូតដល់នាងនៅសំងំពិនិត្យឫកពានាយលែងបានទៀតក៏បំបែរចុងកាណុងមកប្រឡោះមាត់នាយម្តងៈ

«បើឯងមិនឈប់សើច ឯងធ្លាយបំពង់ក!»

គេស្រែកឡុលៗ ព្រោះកាណុងភ្ជង់សឹងដល់កន្លើតបាយៈ

«គ្មានគ្រាប់ទេអូន!»

នាងអោនស្តាប់ច្រើនដងទាំងជ្រួញចិញ្ចើមហើយរេភ្នែកមកសម្លឹងកាណុងខ្លួនឯង។

ស្រីស្អាតសើចបញ្ឈឺមុនពេលខាំមាត់និយាយៈ

«បាន! បើថាចង់ងាប់ក្លាយជាខ្មោចគ!»

នាងកេះកៃ ហើយកេះច្រើនដង ទាំងបើកភ្នែកក្រឡោតៗ។

«ស្អីគេ?»

ស្រីស្រស់ដៀងមករកបុរសនេះ។ នឹកឃើញមួយរំពេចថា មុននេះនាងបានចេញទៅបន្ទប់ទឹក។ ព្រោះតែសំអាង ថាដៃគេជាប់ចំណង នាងដាក់កាំភ្លើងចោលតែដាក់ឆ្ងាយពីគេណាស់ ហេតុអ្វីគេធ្វើបាន គេដោះគ្រាប់ចេញដោយវិធីណា?

នាងឆើតឈ្ងោកមកទាញដៃស្នងការដែលជាប់ចំណងមកពិនិត្យ។ ដៃនាយជាប់ម៉ឺងក្នុងខ្នោះនៅឡើយ តើគេធ្វើម៉េចបាន?

Rose ងើបមុខឡើងមកវិញ ហើយដៀងភ្នែកឆ្វេងស្តាំយ៉ាងរហ័សដើម្បីនឹងពិនិត្យ ស្ថានភាពក្រោយខ្នងខ្លួនឯង។

នាងក្រោកឃឹតៗ ហើយសម្លឹងសម្លក់ស្នងការគ្លែរមិនមាត់មិនក។ ចុងក្រោយគេស៊ីញ៉ូនាងឱ្យងាកទៅ។

ទូរទស្សន៍ចាប់ផ្ដើមបើកដោយខ្លួនឯង។

អ្នកណាជាអ្នកកាន់តេឡេបញ្ជា?

នាងកំពុងស្វែងរកមើលទាំងចិត្តភ័យតក់ក្រហល់ ស្រាប់តែមិនទាន់រកឃើញផង សំឡេងក្នុងទូរទស្សន៍បង្ខំនាងឱ្យងាកទៅយ៉ាងរហ័សដូចផ្លេកបន្ទោរ។.... ព្រោះនោះគឺមហាវីន.....

«ខ្ញុំនឹងឡើងសវនាការក្នុងពេលឆាប់ៗនេះ បកអាក្រាតពីភាពស្អាតស្អំរបស់កម្មវិធីសមោសរពណ៌ព្រះចន្ទព្រមទាំងលាតត្រដាងពីអន្ទាក់មនុស្សអាក្រក់មួយក្រុម ដែលបានប្រើប្រាស់កម្មវិធីរបស់ក្រុមហ៊ុនខ្ញុំទៅពាក់ព័ន្ធជាមួយនិងការបាត់ខ្លួនភ្ញៀវរបស់ខ្ញុំ!»

«ក្រែងវាស្លាប់ហើយ?»

នាងរអ៊ូតិចៗទាំងសង្វាក់ដង្ហើមលើទ្រូងលោតញាប់ចុះឡើង។

«ខ្ញុំចេះពាក់អាវក្រោះ! ស្មានថា មហាវីនមិនចេះពាក់?»

Roy សួរមកក្នុងសព្ទសំឡេងហាក់វាហីមិនខ្វីខ្វល់ដល់អាការៈតប់ប្រមល់របស់នាង។ ពេលនាងនៅទ្រឹងព្រោះភាំង គេស៊កសៀតឱ្យបន្ថែម៖

«ថៅកែនាង ធ្លាប់ត្រូវបានពួកនាងសម្លាប់ជិតស្លាប់ម្ដងហើយ Rose! នាងគិតថាលើកនេះប៉ូលិសព្រមឱ្យពួកមនុស្សក្រៅច្បាប់សម្លាប់សាក្សីបានមែនក៏អី?»

នារីនេះមានភ្នែកក្រហមដូចរងើកភ្លើង។ នាងឈរភ្លឹក សម្លឹងរូបរាងឱុកសេណាកាដែលត្រូវបានវាយខ្ទោះបណ្ដើរចេញពីផ្ទះ ឱិត សាម៉ុន។

ស្រីឡូយឆាយថយក្រោយក្រាកៗ មួយជំហានហើយមួយជំហានទៀត។

«វាមិនអាចទៅរួចទេ!»

Rose និយាយម្នាក់ឯង ប៉ុន្តែស្នងការនៅតែចចេសតបតជាមួយនាង៖

«ក្រដាសខ្ទប់ភ្លើងស្មានថាជិត?»

ម្ដងណេះ នាងបែរខ្វាកមករកគេ។ កែវភ្នែកនាងពោរពេញទៅដោយកំហឹងអាឃាត ក្នុងពេលសម្លឹងមើលមកស្នងការ។

«អាប៉ូលិសបោកប្រាស់! ឯងដឹងរហូតមកតើមែនដែរទេ?»

ស្នងការលែងញញឹម នាយសម្លឹងនារីនេះយ៉ាងមុត។ នាងចូលមកកាន់តែជិតហើយជះសម្ដីកាន់តែលែងអាចគ្រប់គ្រងខ្លួនឯងបាន៖

«ឯងដើរតួបំភ័ន្តយើង! ឯងថាស្រលាញ់យើង! អាតួល្ខោន អាមនុស្សល្បិច»

«ដូចគ្នាដែលនាងដើរតួធ្វើស្រលាញ់ Lorenzo នោះដែរ វិធីតា! តាមពិតនាងរៀបគម្រោងទាញគេទៅទម្លាក់នរក! នាងនឹងខ្ញុំអ្នកណាឆ្នើមជាងខាងសម្ដែង? ពាក្យល្បិច ពាក្យបោកនាងសន្សំសំចៃទុកប្រើខ្លួនឯងចុះ!»

ថ្ពាល់ស្នងការត្រូវមួយដៃទៀត តែនាងទប់វាមកវិញ ព្រោះលែងចង់ទះ។ ចិត្តនាងគឺចង់កាប់សម្លាប់ មិនមែនធ្វើឱ្យថ្ពាល់គេហើមពោរនោះឡើយ។ បុរសនេះមើលពីក្រៅទៅឡប់ៗ ចរិតអន់មហាអន់ សម្ដីក្មេងក្មាង រាងកាយគ្មានក្បាច់គុនខ្ពស់ គ្មានសមត្ថភាពវាយតប់សាហាវអីដុំកំភួន តែហេតុអីគេក្លាយជាតួឯកនៅពេលចុងក្រោយ?

គេលេងល្បិចរហូតមកឱ្យនាងខ្វះការប្រុងប្រយ័ត្ន? នេះជាវិជ្ជាមួយក្នុងចំណោមចិត្តសាស្ត្រសាហាវៗរបស់ពួកប៉ូលិស?

គ្មានពេលណាឈឺចិត្តស្មើពេលនេះឡើយ។ សម្រាប់មនុស្សម្នាក់ដែលតែងគិតរហូតមកថាខ្លួនឆ្លាតលើសគេនោះ គ្មានអ្វីឱ្យឈឺចាប់ស្មើនឹងពេលដែលត្រូវបំបាក់នៅក្រោមស្នាដៃមនុស្សខ្លួនធ្លាប់មើលរំលងថាគេគ្មានបានការនោះទេ។

«នាងគិតថាខ្លួនឯងឆ្លាតរហូតអាចហោះរំលងសំណាញ់ច្បាប់បាន? នាងគិតថា តាំងពីដើមរាងមក មនុស្សស្រីម្នាក់មានដែលប្រវត្តិមិនច្បាស់លាស់ មានលុយចាយសឹងក្រាលដើរបានមានទំនាក់ទំនង ទាំងខាងមហាវីនទាំងខាង Lorenzo ដែលភាគីទាំងពីរមានរឿងត្រូវប្រខាំគ្នា! នាងគិតដូចម្ដេចថា ខ្លួនឯងមិនជាប់ក្នុងបញ្ជីគោលដៅរបស់ប៉ូលិស! នាងមើលងាយប៉ូលិសខ្មែរពេកបានជានាងមានថ្ងៃនេះ!»

Rose ភ្នែកគិតចុះឡើងទាំងកាឡាហល។ នាងដូចអ្នកអានពេលនេះដែរ នាងមិនយល់ថា ក្រុមប៉ូលិសដែលនាងមើលស្រាល ដឹងរឿងអស់នេះតាំងពីពេលណាមក?

ក្នុងភាពតក់ក្រហល់ខ្វល់ខ្វាយ ស្រីស្អាតលូកដៃមកច្បាមសក់នាយប៉ូលិស ហើយអង្រួនក្បាលគេ។

«ប្រាប់មក! អ្នកណាដឹងរឿងនេះខ្លះ?»

បុរសមិនមាត់ ធ្វើឱ្យនាងកាន់តែកើនផ្ទុះកំហឹងទម្លាក់ដៃពីក្បាលគេហើយបែរក្រោយមកទាញថតតុស្វះស្វែងរកអាវុធថែម។

កាំភ្លើងមួយទៀតត្រូវបាននាងដកពិនិត្យគ្រាប់។ Rose ប្រហែលជាអស់សង្ឃឹមណាស់ហើយ

ព្រោះគេឃើញនាងឈរបែរខ្នងហើយច្រត់ដៃនឹងតុ ដកដង្ហើមហត់គឃូស។

«ខ្ញុំឱ្យប្រដាប់តាមដានទីតាំងឱ្យនាង! ដៃកឆក់នោះ បានជួយឱ្យខ្ញុំដឹងថា នាងមិនមែនជាអ្នករងគ្រោះដូចអ្នកបាត់ខ្លួនទាំង៤មុនទេ!»

នាងបែរមកវិញសម្លឹងគេដោយភ្នែកគ្រលួងៗ។ នារីនេះទំនងទើបនឹងដឹងច្បាស់ថា ពេលដែល Royស្គាត់ ជួបប៉ាវកាហ្វេនាង គេនៅមិនទាន់ដឹងពីសមាសភាពនាងនៅឡើយ រហូតដល់ពេលដែលនាងក្លែងធ្វើជាបាត់ខ្លួន....

«ឯងកុហក!»នាងខាំមាត់និយាយ។ ទងបុប្ផាស្រស់ប្រផូរត្រូវស្រោបឡើងដោយកាយវិការសាហាវគ្មានអ្នកណាអាចស្មានដល់។ នាងនិយាយបន្ថែមម៉ាត់ៗ៖

«រាល់ដង ឱ្យតែយើងមិនចង់ឱ្យឯងដឹងនិងឮពីទីតាំង ពីអ្វីដែលយើងកំពុងនិយាយ កំពុងធ្វើ! យើងតែងតែបង្ខាំងរលកសញ្ញាពីអាឧបករណ៍ចង្រៃនោះ!»

«ចុះពេលនេះនាងបានបង្ខាំងវាទៀតដែរអត់ Rose?»

គេសួរទាំងរលោស់ខ្លួនក្រោកចោលខ្នោះដៃ។ ទោះយ៉ាងណាពេលនេះនាងឈប់ខ្វល់ថាគេជាប់ចំណងឬអត់ទៀតហើយ Rose កំពុងវ័ណ្ឌកក្នុងការស្វែងរកឧបករណ៍តាមដានទីតាំងដែលសង្ស័យថាRoy បានលួចបង្កប់លើខ្លួននាង។

ចុងក្រោយ នាងនៅស្កុបហើយបើកភ្នែកធំៗ។

នាងនឹកដល់ពេលវេលាចុងក្រោយនៅផ្ទះមហាវីនដែលគេ..... គេឈប់ចុចទូរសព្ទបែរជាលោមកក្បែរនាងហើយលើកដៃក្រសោបកាយ។ ដៃម្ខាងរបស់គេច្បូតសក់នាង ដែលរវែងអន្លាយ «យកដៃគគ្រិចរបស់លោកចេញRoy!» ពេលនោះ គេសើចក្អាកក្អាយ ក្រោមកែវភ្នែកសម្លក់របស់នាង។

សំឡេងមនុស្សបង្ហាញខ្លួនពេញពេញបន្ទប់ ប្រឆាំងនឹងបេះដូងនាងដែលបម្រុងនឹងគាំងលែងលោត។

ប៉ូលិសមកដល់យូរហើយ នាងទើបតែដឹង!

នារីនេះថយសន្សឹមៗទៅក្បែរបង្អួចទាំងគ្រវីក្បាលមិនព្រមជឿលើអ្វីដែលខ្លួនកំពុងប្រឈមមុខ។ព្រះអាទិត្យចោលកាំរស្មីស្រងូតមកលើផ្ទាំងវាំងននពណ៌បៃតងធ្វើឱ្យភាពងងឹតត្រូវចោលទៅម្ខាង នាងចាប់ផ្ដើមនិយាយរអ៊ូក្នុងភាពរវើរវាយៈ

«គម្រោងការល្អយ៉ាងនេះ! ប្រើមនុស្សសុទ្ធតែអស្ចារ្យ! ប៉ូលិសមោកអស់នោះ គ្មានថ្ងៃរកឃើញការពិតទេ! គ្មានថ្ងៃ....»

ប៉ុន្តែការពិតនៅតែជាការពិត ប៉ូលិស៤ប្រាំនាក់បានចូលមកដល់ចម្ងាយអាចលូកដៃមកប៉ះនាងបាន។ វាជាអ្វីដែលស្រីម្នាក់នេះមិនធ្លាប់បាន រំពឹងទុកថានឹងអាចកើតមានឡើងបាន។

ទោះបីនាងមិនដែលខ្លបខ្លាចចំពោះសេចក្ដីស្លាប់ ប៉ុន្តែនាងពិតជាឈឺចិត្តជាទំងន់ដែលប៉ុន្មាននាទីមុននេះបាន គិតថា ខ្លួនកំពុងទទួលជោគជ័យលើបេសកកម្មដ៏អស្ចារ្យមួយ ពេលនេះវិញគ្រប់យ៉ាងត្រូវរលាយដូចជាក្រមួនហាលចោលក្រោមកម្ដៅថ្ងៃ។

«នាងបង្អាក់រលកសញ្ញាតាមដានរបស់របស់ខ្ញុំ បើនាងបិទវាជារឿងរហូតប្រហែលល្អជាង! ប៉ុន្តែពេលនាងត្រូវការប្រើប្រាស់ខ្ញុំឱ្យទៅរំដោះពួកស្រីៗនាងបើកវាមកវិញ! ពេលនោះហើយខ្ញុំត្រូវការដឹងថា នាងជាអ្នកណា ហើយនាងកំពុងធ្វើអ្វី? នាងចង់បានអ្វី?»

ឥឡូវនេះ ស្រីស្អាតហាក់បង្ហាញការខកបំណងនិងមានអារម្មណ៍ថាខ្លួនពិតជាមានកំហុសព្រោះមើលងាយស្នងការម្នាក់នេះ។

Roy និយាយបន្ថែមមួយៗ នៅក្រោមភាពឆ្លេឆ្លារបស់នាង៖

«នៅផ្ទះខ្ញុំ នាងបានឆ្លៀតពេលលបស្តាប់សម្តីខ្ញុំនិងឱត សាម៉ុន! នាងខលទៅ Lorenzo បង្ខំឱ្យគេគេចខ្លួនទាំងដែលគេមិនចង់! នៅក្នុងសេណារីយោនេះ! មានតែជនបង្កហេតុប៉ុណ្ណោះដែលចង់ឱ្យ Lorenzo ទៅនឹងអាល ទម្លាក់កំហុសទាំងអស់ឱ្យគេ! ខ្ញុំធ្លាប់ចង់ឱ្យនាងឈប់ ខ្ញុំប្រាប់នាងរួចហើយថាភ្លើងនេះនឹងរលាកដល់អ្នកដែលបង្កាត់វាឡើង! តែខ្ញុំក៏ដឹងដែរថា គ្មានអំពើល្អណាមួយក្រៅពីច្បាប់ទេដែលអាចបញ្ឈប់នាងបាន! នៅតាមផ្លូវនាងចង់ឱ្យ Lorenzo ចប់ ដើម្បីរុញរឿងរ៉ាវឱ្យចាល់ដល់បាតហើយទាញប៉ូលិសសេតវិទូឱ្យមកទទួលខុសត្រូវ តែនាងភ្លេចគិតរឿងមួយ! »

Rose ងើបមុខសម្លឹងគេ។ នាងជាអ្នករចនារឿងល្ខោនបញ្ច្រាសទិសនេះឡើង នាងពិតណាស់ចង់ដឹងថាអ្នកណាដែលបំបែកវាបាននាកណ្តាលផ្លូវ តើគេធ្វើដោយរបៀបណា?

ពេលនាងស្ងាត់ដូចគេចុករង់ចាំអន្ទះសា Roy បំពេញបំណងនាង៖

«នាងភ្លេចគិតថា Lorenzo ពុំមែនជាមនុស្សជំឡងមូលឡើយ! គេអាចថាមានពេក ខ្ពស់ពេកដល់ថ្នាក់មិនដឹងពីល្បិចទុច្ចរិតរបស់ពួកអ្នកបើកឡាន! ប៉ុន្តែមនុស្សដូចគេឱ្យតែមានទូរសព្ទស្មាតហ្វូនក្នុងដៃ ស្អីក៏គេធ្វើបានដែរ! គេបានរៀបចំលុយវេរជាបន្ទាន់ដោះជីវិតតែលុយដដែលនោះក៏បាននាំប៉ូលិសឱ្យរកឃើញពួកអ្នកបង្កហេតុដូចគ្នា! នាងគិតថានាងមានឌុកសេណាកាដែលត្រូវការទារគំនុំជាមួយឱតសាម៉ុនជាដៃគូ នាងស្មានថាគម្រោងប្រឌិត ២០៣៥ នឹងអាចទៅរួច? នាងស្មានថាប៉ូលិសសេតវិទូទទួលខលរបស់ឈ្មោះសុខាហើយមិនព្រមផ្តល់ព័ត៌មាននេះឱ្យទៅប៉ូលិស? នាងចង់សងសឹក គេដែលធ្វើឱ្យម្តាយនាងជាប់គុកកាលពីជាង១០ឆ្នាំមុនម៉េចក៏មិនគិតលាក់ឯកសារផ្ទាល់ខ្លួនឱ្យស្អាត ឬមួយនាងភ្លេចគិតថាខ្ញុំក៏មកពីសាលាប៉ូលិសឡុងដុង?»

«តែឯងនៅទីនេះរហូតឯងមិនបានទៅMenchsterក៏មិនបានទៅLondon ហេតុអ្វីឯងរកប្រវត្តិយើងបាន?»

Roy ដើរមកក្បែរនាងគេសម្លឹងនាងពីលើដល់ក្រោម។

គេពិនិត្យពិច័យសូម្បីតែខោអាវកីឡាតម្លៃរាប់រយដោនរបស់នាង។ នាងប្រហែលទើបនឹងភ្ញាក់ពេលដែលគេលូកដៃទាញយកដុំឆក់ដែលថ្កក់ជាប់ពី ក្រោយស្លាកសញ្ញាប្រេនឌីងធ្វើអំពីដែករបស់ម៉ាក liberty london។

«នាងចង់លាក់ប្រវត្តិ ម៉េចក៏នាងចាយលុយជាកេររបស់អ្នកស្រីកុលាប ម្តងហើយម្តងទៀត? ព្រោះនាងយល់ថាលុយជាអ្វីគ្រប់យ៉ាង លុយអាចទាញព្រះអាទិត្យមិនឱ្យរះបាន? នាងប្រើកូនភ្លោះ ផលដេវីដនិងសុខដេវីដ ដោយព្រមជះលាភយ៉ាងច្រើនទៅលើគេ កែប្រែជីវិតជាក្មេងលេងល្បែងឱ្យទៅជាមនុស្សរបស់នាង ហើយដាក់គេឱ្យនៅជាមួយមហាវីនធ្វើជាឈ្លោះមិនត្រូវជាមួយនាង សង្ឃឹមថាល្ខោននាង នឹងធ្វើឱ្យប៉ូលិសវិលក្បុងបាន? ប៉ុន្តែពេលនាងឱ្យដេវីដដែលនៅក្រៅឃុំចេញទៅចាត់ការតាពាង គេនោះបានភ្លាត់រឿងសំខាន់មួយ។ នៅលើសាកសពរបស់គ្រួសារគ្រូទាយក្លែងក្លាយបានពន្យល់ប្រាប់ខ្ញុំអំពី ភាពក្លែងបន្លំនៃចរន្តលុយដែលដេវីដទាំងពីរបន្លំចុះឡើងលៀនកន្ទុយប្រភពពិតនៃថវិកាដែលគេបម្រុងចោទថាវាមានប្រភពមកពីឱត សាម៉ុន! មិនតែប៉ុណ្ណោះ តាពាងបាន បន្សល់ទុកនូវតម្រុយមួយចំនួនដែលអំណោយផល! តម្រុយទាំងនោះ ធ្វើឱ្យខ្ញុំអាចរកឃើញថា ហេតុអ្វីបានជាឆ្នាំរោង ហើយហេតុអ្វី៣៥នាក់? »

គម្រោងការរៀបមកយូរណាស់ ហេតុអ្វីចុងបញ្ចប់វាខ្លីម្ល៉េះ?

នាងនៅទ្រឹង ទុកឱ្យអ្នកណាម្នាក់ឈានមកដាក់ខ្នោះដៃពីក្រោយទាំងមិនបានតតាំងមិនបានប្រកែកប្រណាំងអ្វីទាំងអស់។

Roy សម្លឹងនាងជាមួយអារម្មណ៍សម្ងាត់ថា ហេតុអ្វីបានជា Rose ទៅជាស្ងប់ស្ងាត់? នាងកំពុងស្រមៃថា នាងនឹងអាចចាកចេញពីច្បាប់បាន ជាមួយកំហុសដ៏ច្រើននេះ? ឬមួយនាងនៅមានក្បាច់អ្វីមួយចុងក្រោយទៀត?

«Rose»

គេហៅតិចៗ នាងក៏បង្អង់ឈប់។ ស្នងការប៉ូលិសរូបនេះចាប់ផ្តើមនិយាយមួយៗបន្ថែម៖

«ម្តាយនាង អ្នកស្រីកុលាបបានលើកទោសឱ្យភីណានិងវិទូរួចហើយ! នៅចុងបញ្ចប់នៃសំណុំរឿងZ22 នាងគួរតែដឹងហើយថា គាត់ជួយប៉ូលិសភណ្ឌនិងសេតវិទូ ឱ្យរស់បន្តបានពេលគេ

ត្រូវសារធាតុគីមីពុលរបស់មករាកូនពូសួស! ហេតុអី? ហេតុអីចាស់ៗអហោសកម្មឱ្យគ្នាអស់ហើយ តែនាងជាមនុស្សជំនាន់ក្រោយ នាងនៅតែមិនព្រមចប់? សេតវិទូបានចាកចេញពីការងារកាន់កាំភ្លើងហេតុអីនាងនៅមិនទាន់អស់ចិត្ត? ភីណានិងវិទូបានបែកគ្នាដោយសារអ្នកណាបង្កឡើង? កូនស្រីតែមួយគត់របស់ភីណា ក៏មាន Side Effect នៃជាតិ 3M របស់ម្តាយនាង រហូតដល់មិនអាចធំធាត់ដឹងក្តីបាន ចុងក្រោយ ភីណានិងជំនិតមាន Lorenzo មកជាកូនធម៌ នាងនៅចង់បំផ្លាញ គេទៀត? ហេតុអីRose?»

នាងងក់ក្បាល ស្រក់ទឹកភ្នែក។ Rose ដើរឆ្ពោះទៅមុខហើយមិនព្រមនិយាយ។ Roy  ក៏មិនដឹងដែរថា ហេតុអ្វី?

វគ្គ ប៉ូលិសក្តិបួន

«នែ៎! គ្នាគ្មានយល់អីច្រើនលើសពី៣០ភាគរយទេនៃការបំបែកសំណុំរឿងនេះ!»

ឯកមាននិយាយផងរត់ផង តាមពីក្រោយជាតិចិត្រាដែលស្ពាយសាក់កាដូរើអីវ៉ាន់ចាកចេញពីផ្ទះលោកឱិត សាម៉ុន។

«និយាយរឿងដែលឯងយល់មកអ៊ីចឹង!»

ចិត្រានិយាយទាំងមុខស្រងូតហើយដើរសំដៅម៉ូតូ។

«យើងដឹងហើយថាឧកសេណាកានិងrose មានសត្រូវខុសគ្នា តែគេត្រូវការប្រើគ្នាទៅវិញទៅមក!ម្នាក់ចង់ឱ្យឱិត សាម៉ុនស្លាប់ម្នាក់ចង់ឱ្យពូសេតវិទូរបស់ឯងជាប់គុក! ប៉ុន្តែទំនុកមនុស្សស្រីឆ្នាំរោង២៥នាក់ ហេតុអ្វីបានជាចេះនឹករកឃើញហើយទៅឱ្យតាពាងបញ្ឆោត Lorenzo បានមកស្រុកខ្មែរចូលអន្ទាក់គេ?»

ចិត្រាឈានឡើងម៉ូតូទាំងមុខស្រពោន។

គេងើបមុខសម្លឹងគេហដ្ឋាននេះ បន្តិចពិសេសបន្ទប់របស់ស្រីស្អាត មុនពេលគេនិយាយទៅកាន់មិត្តទាំងខ្សោះគ្មានកម្លាំង៖

«យើងល្ងង់ណាស់! ឯងមកសួរយើងយើងសួរទៅពីណានាំឱ្យគេសើចឌឺ! ជាតិនេះខ្មាសគេឆ្អែតហើយអាណិតតែពូយើងទេ មានក្មួយល្ងង់ប្រហែលយើង! ឯងជិះអត់ បើមិនឡើងយើងចេញទៅហើយ!»

«តើលោកទៅណាបើហៀនលែងនៅហើយមានអ្នកណាជួយការពារអ្នកនាង!»

លោកឱត សាម៉ុននិយាយផងដើរត្រឹកៗមកពីហាត់ប្រាណផង។

ប៉ូលិសទាំងពីរអោនគោរព ចំណែកសក្តិបួនចិត្រាឈ្ងោកមុខសឹងគេចដី ដែលធ្លាប់ថាប្រមាថបុរសនេះទាំងល្ងង់ខ្លៅទន្ទឹងទិស។

«ខ្ញុំសួរលោក សក្តិបួនទាំងពីរ!»

ឯកមានប្រញាប់ឆ្លើយតបភ្លាមៈ

«ខ្ញុំគ្មានគម្រោងទៅណាទាំងអស់ទាន!»

គេយកកែងដៃ គោះស៊ីញ៉ូចិត្រា ធ្វើឱ្យសក្តិបួនម្នាក់ទៀតនេះឆ្លើយរដាក់រដុបៈ

«ខ្ញុំល្ងង់យ៉ាងនេះការពារអ្នកនាងនាំតែបង្កបញ្ហាថែម! ណាមួយជនពាលចូលគុកអស់ហើយទាន!រឿងមនុស្សស្រីឆ្នាំរោងលែងជាកង្វល់ទៀតហើយ!»

ឱត សាម៉ុនញញឹមសម្លឹងសាក់កាដូនៅកែបម៉ូតូគេ។ កែងដៃគេនៅមានស្នាមជាំថ្មីដែលបន្សល់ដោយស្វ័យកាំភ្លើងរបស់ឱុកសេណាកា។ គាត់និយាយតិចៗៈ

«អ៊ីចឹងមុនទៅ លោកចង់ដឹងការពិតថា ហេតុអ្វីបានជាពួកមនុស្សអាក្រក់ពីរនាក់នោះ រើសយកឆ្នាំ២០០០និងតួលេខ៣៥នាក់?»

«ចង់ដឹងណាស់ទាន!» ឯកមានថាផង គោរពគំនាប់ផង។

«នាំគ្នាចូលក្នុង! មកតាមខ្ញុំ!»

ភាគបញ្ចប់

វគ្គ គម្រោងការសម្ងាត់២០៣៥

«គាត់ហៅអ្នែងចូលក្នុងអាចិត្រ!»

ចិត្រាដើរមួយៗចូលក្នុងផ្ទះឱត សាម៉ុនតាមពីក្រោយឯកមាន ដើរផងគេរអ៊ូទាំងក្តៅចិត្ត៖

«អាមិត្តទ្រុស្តមិត្តឯងនេះ! ឯងដឹងរឿងឌុកសេណាកា ក៏មិននិយាយប្រាប់ឱ្យអញដឹង! អ្វែងទុកឱ្យអញល្ងីល្ងើ ត្រូវគេសើចពេញប្រទេស ឥឡូវនេះល្អមុខណាស់ហើយអាមាន!»

ឱត សាម៉ុនងាកមកទះស្មាគេតិចៗ៖

«ចិត្រា! ខ្ញុំមិនឱ្យឯកមាននិយាយព្រោះមានហេតុផល!»

គាត់កៀកនាយទៅក្នុងផ្ទះហើយប្រាប់បន្ត៖

«Roseនិងឌុកសេណាកាបានរៀបចំគម្រោងការមកយ៉ាងល្អិតល្អន់! សេណារីយោត្រង់នោះគឺចង់ឱ្យឯងមករករឿងខ្ញុំនឹងអាលគេមកដល់បាញ់ខ្ញុំសម្លាប់ទម្លាក់លើឯង! ហើយធ្វើឱ្យពូរបស់ឯងរើខ្លួនលែងរួច! ចុះបើឯកមានប្រាប់ឯងពីការពិតសាច់រឿងនឹងត្រូវប្តូរហើយជនល្មើសនឹងដឹងខ្លួនបាន!»

ពួកគេអង្គុយចុះលើសាឡុង។ឯកមានចាប់ផ្តើមសួរ៖

«ខ្ញុំមានរឿងច្រើនណាស់ដែលមិនយល់! ហេតុអ្វីបានជា Rose ដឹងថា ការប្រើអន្ទាក់មនុស្សស្រីកើតឆ្នាំ២០០០ចំនួន៣៥នាក់អាចនាំ lorenzo ឱ្យព្រមមកកាន់ស្រុកខ្មែរ?»

ឱត សាម៉ុន និយាយទាំងក្រោកទៅចាក់កាហ្វេច្រូចៗ៖

«ដំណាក់កាលដែលកូនខ្ញុំត្រូវគេមកចាប់ដល់មុខផ្ទះ ខ្ញុំចាប់ផ្តើមឃើញតម្រុយពីភាពក្បត់របស់ហឿន! ខ្ញុំដឹងថា ហឿនមានអ្វីម្យ៉ាងទាក់ទងនិងសេតវិទូ! ការសើបដំបូងប្រាប់ថាហឿនមិនមែនធ្វើដើម្បីលុយ តែគាត់មានទំនាក់ទំនងនិងពូសួស ជាអ្នកដែលធ្លាប់រងគ្រោះព្រោះការវែកមុខរបស់សេតវិទូ! ខ្ញុំទៅជួបគេស្ងាត់ៗពូរបស់ឯងសេតវិទូ!»

«អ៊ីចឹងបានខ្ញុំឃើញគំនូសក្រវេមក្រវ៉ាមបិទនៅលើបង្អួចរបស់គាត់? លោកទៅមិនឱ្យភរិយាគាត់ដឹងទេ?» ចិត្រាភ្លាត់មាត់និយាយព្រោះស្លុងចិត្ត។

ឱត សាម៉ុនងក់ក្បាល៖

«គ្មានអ្នកណានៅផ្ទះទេ! ព្រោះគាត់បានពង្វាងអ្នកស្រីឱ្យចេញទៅក្រៅឆ្ងាយ! ខ្ញុំបានប្រាប់រឿងហេតុតាពាង Lorenzo និងសមោសរពណ៌ព្រះចន្ទ! យើងរកឃើញថា អ្នកណាម្នាក់នៅ

ចន្លោះរបស់ទាំងនេះ ប្រាកដជាពាក់ព័ន្ធ គ្រាន់តែថា Lorenzo ជាអ្នករងផលប៉ះពាល់ជាប់សង្ស័យ គេប្រាកដជាមិនមែនអ្នកដើមហេតុ រីឯមហាវីនគេអាចជាប់សង្ស័យ ប៉ុន្តែហេតុអ្វីគេត្រូវលបធ្វើឃាត? Rose ក្លាយជាគោលដៅធំ ប៉ុន្តែនាងស្រាប់តែបាត់ខ្លួនភ្លាមៗដែរ នាងមិនមែនកើតឆ្នាំ ២០០០ ដូច្នេះនាងកាន់តែលេចធ្លោខុសគេក្នុងគំនូសរបស់ពួកយើង! ស្នងការ Royដែលខ្ញុំបានឃើញនៅស្និទ្ធជាមួយនាងបានត្រូវហៅមកពិភាក្សាស្ងាត់ៗហើយគេទទួលស្គាល់ថា នាងមានចំណុចគួរឱ្យសង្ស័យ ព្រោះដែកតាមដានទីតាំងរបស់គេត្រូវបិទរលកសញ្ញាចោលរហូតដល់ឃុនរាជរកឃើញកន្លែងលាក់ក្មេងស្រីអស់នោះ! ឯកមានបានទាក់ទងឃុនរាជ ហើយពួកគេបានមកជួបខ្ញុំជាមួយតម្រុយជុំវិញសំណួរដែលថាហេតុអ្វីប្រតិបត្តិការនីមួយៗមានទម្រង់ដូចជាត្រូវបានរៀបចំឡើងដោយប៉ូលិសជំនាញ? ជាប៉ូលិសជាន់ខ្ពស់ហើយមានជំនាញ internet សាហាវ មុនពេលយើងប្រាកដ ថាម្នាក់នោះជាឧកសេណាកា យើងត្រូវការដឹងពីហេតុផល! គំនុំកូនប្រុសរបស់គេ ត្រូវបានយើងរកឃើញ! រឿងដែលយើងធ្វើយឺតគឺការដែលអតីតប៉ូលិសឈ្មោះសុខាត្រូវគេសម្លាប់! ដេវីដមិនព្រមប្រាប់ទីតាំងពិត ដល់សេតវិទូឡើយគេកុហកមួយហើយមួយទៀត ទម្រាំគាត់អាចទៅដល់គីឃីតបន្តិចទៅហើយ!»

«លោកមិនទាន់និយាយអំពីហេតុផលមនុស្ស៣៥នាក់កើតឆ្នាំរោងនៅឡើយ!»

ឯកមានសួរចំចំណុចធ្វើឱ្យចិត្រាដាក់សាកដូចុះចំហរមាត់រង់ចាំស្ដាប់។ ឱត សាម៉ុនចាប់ផ្ដើមបង្វិលលេបថប់មកបង្ហាញញញរូបក្មេងជំទង់ម្នាក់ ដែលអ្នកសក្តិបួនទាំងពីរឃើញហើយអោនទៅពិនិត្យឱ្យ កាន់ តែច្បាស់ព្រោះគិតថា ដូចជាប្រហែលមុខ។

«Lorenzo?»

ឱត សាម៉ុនរៀបរាប់បណ្ដើរក្រេបកាហ្វេបណ្ដើរ៖

«Lorenzo ត្រូវបានគ្រួសារបោះបង់ចោល ក្រោយពេលឪពុកនឹងម្ដាយស្លាប់បន្តគ្នា ហើយហោរាចិនមួយនិយាយនឹងជីដូនជីតាគេថា គេជាផ្កាយកាច ជាដួងជតាអាក្រក់នៅក្បែរអ្នកណាអ្នកនោះនឹងវិនាស! ក្នុងវ័យ១៣ឆ្នាំគេត្រូវបានបញ្ជូនមកសហរដ្ឋអាមេរិកធ្វើប្រាណជាមួយម្ដាយមីងខាងឪពុកដែលប្រឆាំងនិងអបិយជំនឿ! គាត់បានខំចិញ្ចឹមក្មួយប្រុសឱ្យសិក្សាហើយបានរងគ្រោះថ្នាក់ចរាចរណ៍ស្លាប់នៅ៦ខែក្រោយមក! មរណភាពនេះ ធ្វើឱ្យLorenzo ខ្លួនឯងទទួលស្គាល់ថា សម្ដីហោរាចិន គឺជាការពិតដ៏ឈឺចាប់ដែលញាំញីជីវិតនាយ! ម្ដាយឱ

ពុកធម៌របស់គេគឺភីណានិងជំនិតបានទទួលយកគេមក ហើយទុកគេដូចជាកូនប្រុសច្បង! មិនបានប៉ុន្មានប្អូនស្រីនិងនីងរបស់គេត្រូវរកឃើញថាមានជំងឺឈាមដែលមិនអាចព្យាបាលបាន! ការស្លាប់របស់នាងតូចបានធ្វើឱ្យ Lorenzoសម្រេចចិត្តធ្វើអត្តឃាត ប៉ុន្តែគេត្រូវបានជួយសង្គ្រោះ! គ្មានអ្នកណាជាអ្នកស្លាប់បន្តទៀតនោះទេ ប៉ុន្តែ Rose បានដឹងទាំងអស់គ្រប់យ៉ាងកើតឡើងចំពោះគ្រួសារមួយនេះ! នៅក្នុងការពិព័រណ៍វត្ថុបុរាណមួយ Lorenzo បានបង្ហាញខ្លួន វាជាឱកាសសម្រាប់ឱ្យនាង បញ្ចេញគ្រូភូតព្រៃក្លែងក្លាយម្នាក់ដែលមកបង្ហាញតម្រុយដល់ Lorenzo ពីរឿងប្រើមនុស្សឆ្នាំនាគ ៣៥ នាក់ រួមភិសម័យ ផ្លាស់ប្តូរថាមពលមេឃដីហើយលុបចោលមហន្តរាយនៃមមហិទ្ធិឫទ្ធិផ្កាយកាច! ក្នុងស្ថានភាពរបស់ខ្លួនដែលបាត់បង់មនុស្សជាទីស្រលាញ់បន្តបន្ទាប់គ្នា ក្នុងស្ថានភាពដែលមានមរតកមហាសាលពេញក្នុងដៃ Lorenzo ត្រូវតែជ្រើសរវាងសម្លាប់ខ្លួន ឬមួយក៏កែប្រែវាសនា! ឆាកល្ខោនដ៏ធំបានកើតឡើងហើយគេបានវេចសំពាយមកកម្ពុជាស្វែងរកអ្នកចេះរៀបចំក្បួនថាមពលមេឃដី! គេមិនដឹងឡើយថាក្នុងពេលជាមួយគ្នា Rose បានមកនៅក្បែរមហាវីនហើយលើកទឹកចិត្តថៅកែមួយនេះឱ្យបង្កើតសមោសរពណ៌ព្រះចន្ទ!»

ឯកមាននិងចិត្រានៅស្ងាត់មាត់ដូចគេចុក។

នារីនោះបង្កើតរឿងច្រើនយ៉ាងនេះ ព្រោះតែហេតុផលអ្វីទៅ? ពួកគេគិតស្ងាត់ៗក្នុងចិត្តស្របពេលគាត់ហុចកាហ្វេពីរកែវមក។ ឯកមានទទួលយកមុន ចំណែកចិត្រាដែលនៅពោរពេញដោយការអៀនខ្មាសទីរទើរមុនពេលទទួលយក។

លោកឱត សាម៉ុនធ្វើជាមើលរំលង មិនឃើញអាការៈខ្មាសខ្លួនឯងរបស់យុវវ័យនេះ គាត់និយាយបន្ត៖

«សម្រាប់ប្រទេសនីមួយៗ ដរាបណា ការភ័យខ្លាចអំពីគ្រឿងញៀននិងឧក្រិដ្ឋកម្មផ្សេងៗកាន់តែត្រូវបានគំរាមកំហែង នោះសុខុមាលភាពពលរដ្ឋ កាន់តែងាយនឹងគ្រប់គ្រងដោយពួកបរទេស និងពួកប្រទេសអ្នកមានអំណាច!»

«ខ្ញុំមិនយល់!»ឯកមាននិយាយ។

«ខ្ញុំចង់និយាយប្រាប់ពួកលោកដែលជាយុវវ័យថា អធិបតេយ្យភាពនិងសុខដុមរមនារបស់ប្រជាជាតិមួយគឺ រំពឹងលើសមត្ថកិច្ចវ័យក្មេងមានជំនាញនិងសីលធម៌ខ្ពស់!»

«ខ្ញុំគ្មានសមត្ថភាព ប្រើឈ្មោះថាជាសមត្ថកិច្ចទេទាន!»

ចិត្រាសារភាពបន្ទាប់ពីបានស្ងាត់អស់ពេលមួយសន្ទុះធំ។

លោកឱត សាម៉ុនយល់ចិត្តយុវជននេះ គាត់និយាយបន្ថែម៖

«អ្នកណាក៏ត្រូវរៀនដែរ! លោកចង់ធ្វើកូនប្រសាខ្ញុំ លោកត្រូវចាប់ផ្តើមពីពេលនេះទៅ!»

គេងើបមុខយ៉ាងរហ័ស ចំណែកឯកមាន អេះក្បាលធ្វើស្ងួញស្ងាញ។

ឱត សាម៉ុនញញឹមចាប់ដៃឯកមានធ្វើឱ្យHackerបោះដៃមករលាក់វិញ៖

«អបអរសាទរដែលគ្រួសារផានូហៅលោកឱ្យនាំចាស់ៗចូលទៅជួបគេ! ខ្ញុំនឹងធ្វើជាចាស់ទុំឱ្យ!»

ចិត្រាដឹងថាហេតុអ្វីមួយព្រឹកនេះឯកមានហាក់សប្បាយស្រស់ស្រាយចម្លែក តាមពិតគឺបន្ទាប់ពីបាត់ទៅជាមួយកូនស្រីគេច្រើនថ្ងៃ ម្តាយឪពុកគេសម្រេចលើកូនឱ្យតាមបេះដូងក្មេងៗតែម្តង។ ចំណែកមើលមកខ្លួនឯងនេះវិញ ចំណាងនៅទាក់កសឹងថារើមិនរួច។ អមរាដាមានគូដណ្តឹងដែលជាមនុស្សមានសមត្ថភាពភាពខ្ពស់ និងជាស្នងការសមទាំងឋានៈពូជអម្បូរ ចំណែកខ្លួនឯណោះ មានអនុស្សាវរីយ៍ត្រឹមតែដៀលដេរឱត សាម៉ុន ព្រោះចិត្តឆេវឆាវនិងគិតរាក់។

«ខ្ញុំនេះ…គ្មាន….គ្មាន….»

គេមិនបាននិយាយចប់ទេ ព្រោះនិយាយអ្វីក៏មិនចេញ។ ឱត សាម៉ុនជាអ្នកនិយាយជំនួស៖

«កាលពីម្សិលសេតវិទូបាននិយាយរឿងផ្សារសាច់ឈាមនេះ! ខ្ញុំបានប្រាប់គេវិញថា កូនអមរាដានៅក្មេងណាស់ គេរៀនមិនទាន់ចប់ផង! ដូច្នេះលោកក៏មានពេលច្រើនដើម្បីដំឡើងសាក់នៅលើស្មារបស់ខ្លួនដែរជាតិចិត្រា!»

អូយ! បានន័យថាពូខ្លួនបានចេញមុខដណ្តឹងកូនស្រីឧត្តមសេនីយ៍ឱ្យ?

«តែអ្នកនាងមានលោកស្នងការរួចហើយទាន!»

ឯកមាននិយាយជំនួស។ ឱត សាម៉ុនញញឹម៖

«ស្នេងការRoyលែងមានហើយ! គេចេញទៅអាល្លឺម៉ង់៥ឆ្នាំ! គេចង់បានជំនាញ ជាងចង់បានប្រពន្ធ! គេមកផ្ដាច់ពាក្យតាំងពីរឿងក្ដីមិនទាន់ចប់ម្ល៉េះ គេដឹងថា កូនខ្ញុំមិនចង់បានប្ដីសក្ដិធំទេ! ឬមួយក៏មានគេប្រកាន់ថា អមរាជាមេម៉ាយខាន់ស្លា?»

គាត់សួរលេងៗតែចិត្រាប្រញាប់ប្រកែកទាំងសោមនស្ស៖

«ទេគ្មានទេទាន!!»

ឯកមានសើចគិល។ នៅក្រៅទ្វារកញ្ចក់ ចិត្រាឃើញស្រីៗពីរនាក់ប្រញាយ គ្នារត់ឡើងទៅជាន់ខាងលើលើវិញ។

កំលោះសក្ដិបួនចាប់ផ្ដើមបញ្ចេញស្នាមញញឹម ព្រោះដឹងថាផានូនិងអមរាជាបានលបមកតាមដានពួកិច្ចសន្ទនាមុននេះ.....

វគ្គ សំបុត្រចុងក្រោយរបស់ Rose

Roy ដាក់សំបុត្រជាប់ស្រោមទៅក្នុងសាក់កាដូហើយបិទទ្វារឡានគ្រាំង ដើរទៅមុខមិនបកក្រោយ ចូលទៅក្នុងអាកាសយានដ្ឋាន។

វាជារបស់ Rose ដែលផ្ញើចេញពីក្នុងគុកមក។ គេមិនអាចអានវានៅមុខអ្នកដទៃ រឹតតែមិនមានពេលវេលាសម្រាប់អានវាតាមលំដាប់លំដោយនៅកន្លែង Check-In នេះ។

វាគួរឱ្យភ្ញាក់ផ្អើលនៅពេលយើងព្យាយាមចូលសួរសុខទុក្ខគេច្រើនដង បែរជាគេមិនព្រមជួបហើយទីបំផុតគេរកវិធីសរសេរសំបុត្រនេះផ្ញើមក។

តម្រង់ជួរនៅទីកន្លែងត្រួតពិនិត្យសុវត្ថិភាពមុនឡើងយន្តហោះ Roy មានពេលស្រមៃនឹកឃើញដល់រឿងជាច្រើន។

ធាតុនៃស្ទើរតែទាំងអស់សម្រាប់ការគំរាមកំហែងដល់សន្តិសុខជាតិ នាពេលបច្ចុប្បន្ន ត្រូវបានគាំទ្រនិងជួយសម្របសម្រួលក្នុងបណ្ដាញ Internet ។ internet ជាកម្លាំងថ្មី តែក៏ជាហានិភ័យខ្ពស់។ ប៉ូលិសនិងជនស្លូតត្រង់ កំពុងរស់នៅក្នុងលក្ខខណ្ឌប្រឈមការគំរាមកំហែងតាមអ៊ីនធឺណិតដ៏ស្មុគស្មាញពីពួក Hacker ដែលភាគច្រើនពួកគេជាអ្នកជួយសម្រួលប្រសិនបើ

មានការឧបត្ថម្ភដោយអ្នកនយោបាយឬពួកអ្នកធ្វើរដ្ឋប្រហារនានា។ ភេរវកម្មតាមបណ្ដាញលំហ internet នៅតែរឿងដ៏ក្រពុលមុខមួយ។

«Rose ខ្ញុំមិនអាចនិយាយប្រាប់នាងបានពីចំនួនជាក់លាក់ក្នុងការខាតបង់សម្រាប់វិស័យធនាគារ វិស័យសេដ្ឋកិច្ចនិងចរន្តសន្តិសុខជាតិដែលនាំទៅដល់ការប៉ះទង្គិចដល់ជីវភាពរស់នៅរបស់ពលរដ្ឋខ្មែរស្លូតត្រង់ប៉ុន្មាននាក់នោះទេ ប្រសិនបើអ្នកដែលមានសមត្ថភាពខ្ពស់ មានលុយកាក់ហូរហៀរដូចនាង នាំគ្នាធ្វើអំពើក្រៅច្បាប់ ព្រោះតែគំនុំនិងភាពមានះផ្ទាល់ខ្លួន! ប៉ុន្តែក្នុងនាមជាមិត្ត ខ្ញុំនៅតែបញ្ចេញមតិរបស់ខ្លួនឯង ប្រាប់នាងថា ប្រទេសជាតិមួយដ៏អស្ចារ្យដែលមានគុណសម្បត្តិអាចគាំទ្រសេរីភាព នៅក្នុងប្រព័ន្ធយុត្តិធម៌បានសម្រេចគឺការលើកទឹកចិត្តឱ្យអ្នកធ្វើខុសកែខ្លួន! នាងភ្ញាក់ខ្លួនឡើង!»

នេះជាអ្វីដែលគេទើបនឹងបានសរសេរកាលពីម្សិលម៉ិញ ជាការសរសេរចុងក្រោយផ្ញើទៅឱ្យនាងបន្ទាប់ពីសំបុត្រជាច្រើនរបស់គេមិនមានការឆ្លើយតប។

Roy កុំព្យូទ័រយួរដៃ ចេញពីកាបូបដាក់ទៅលើកព្រៀងឆ្លងកាត់ប្រព័ន្ធត្រួតពិនិត្យ។ ពេលគេអោនដោះដាក់ស្បែកជើងដាក់មក លើធុងគេនឹកឃើញដល់ស្បែកជើងថ្លៃៗខ្ពស់ៗដែលនាងដើរហើរស្ទាត់ជំនាញ។

មន្ត្រីប៉ូលិស មួយរូបប្រហែលជាមើលឃើញគេពីចម្ងាយ ក៏ស្ទុះមកក្បែរទាំងលើកដៃគំនាប់គោរព៖

«ស្នងការRoy! សូមគោរពទាន!»

«ខ្ញុំលែងជាស្នងការទៀតហើយបង!»

គេនិយាយទាំងមុខឌី ហើយដើរបន្តទៅមុខក្នុងជួររង់ចាំ ហាក់មិនអើពើហាក់ឆ្មើងកន្ទ្រើងផុតលេខ។ទោះអ៊ីចឹងហើយក្ដី ប៉ូលិសដដែលនៅតែរត់មកតាមនិយាយ៖

«ខ្ញុំដឹងហើយ! មេទៅរៀននៅអាល្លឺម៉ង់៥ឆ្នាំ តែចិត្តខ្ញុំ នៅតែទុកមេ ជាស្នងការកំពូលសមត្ថភាពដដែល!»

Roy រំភើបណាស់ តែគេធ្វើមុខបែបមួហ្មង។

«ហេតុអី?»

ប៉ូលិសដែលស្ពាយសក្តិបីនៅលើស្មា អោនគោរពទៀតមុននឹងនិយាយ៖

«មេបំបែកសំណុំរឿង២០៣៥បាន! មេជាប៉ូលិសខ្មែរដ៏អស្ចារ្យ!»

Royធ្វើមុខមាំ ហើយសម្លុត៖

«ឯងជាប៉ូលិស! ឯងស្គាល់ច្បាប់ស្គាល់វិន័យអត់! កន្លែងនេះគេឱ្យដើរត្រួសងនិយាយគ្នាអ៊ីចឹងដែរ?»

កូនប៉ូលិសអោនកាយហើយថយក្រោយ។ Royធ្វើហីក្រោមការតាមមើលរបស់អ្នកដំណើរ។ មិនបានពីរជង្ហើមផង កូនប៉ូលិសនោះរត់ចូលមកទៀតហើយនិយាយដោយរំភើប៖

«មេមានសម្តីអាក្រក់ តែមេជាប៉ូលិសឡូយម្នាក់! ប៉ូលិសស្រុកខ្មែរឋានៈធ្លាយឡើងគ្មានអ្នកណាមិនប្រើVIPទេ មានតែមេដែលមកតម្រង់ជួរ! ខ្ញុំគោរពមេជានិច្ចក្នុងចិត្តអាសក្តិបីម្នាក់នេះ!»

គេលើកដៃគោរពជាចុងក្រោយ ធ្វើឱ្យ Roy ទប់ចិត្តរំភើបយ៉ាងពិបាក។ មុនពេលឈានដល់ម៉ាស៊ីនBody-Scanners គេឆ្លៀតងាកមកចង្អុលមុខនិយាយ៖

«ខ្ញុំមិនមែនមេរបស់ឯងទេ! ឈប់ហៅអ៊ីចឹងទៀត?»

គេមកដល់ច្រកទ្វារឡើងយន្តហោះដែលពេញដោយមនុស្សម្នា។ ស្ត្រីម្នាក់ក្រោកពីកៅអីមកសុំរលាក់ដៃនាងទាំងនាយកំពុងភាំងព្រោះគ្រប់គ្នាសម្លឹងមក។

«ស្នងការRoyខ្ញុំឈ្មោះ ចន្ថា មកពី UNWoman ផ្នែកបង្ក្រាបការជួញដូរឆ្លងកាត់ព្រំដែន! ខ្ញុំសរសើរស្នាដៃលោក! ពីរឆ្នាំមុនលោកនឹកឃើញទេការបញ្ជូននារីខ្មែរ៤៥នាក់វិលមកកម្ពុជាវិញបន្ទាប់ពីចាញ់បោកគេ! លោកពិតជាប៉ូលិសគំរូម្នាក់!»

គេនឹកឃើញភ្លាមដល់រូបភាពនារីខ្មែរដែលប្រព្រឹត្តិអនាចារដោយការបង្ខំចិត្តនៅបរទេស ព្រោះពួកនាងចាញ់បោកគេហើយចុងក្រោយនៅពេលគេបញ្ចប់ក្តីនោះដោយភ្លេចបករូបទាំងនោះយកទៅទុកជានូបាននាំ ដំណឹងទៅប្រាប់ឪត សាម៉ុន។

«ស្នងការឯងពិនិត្យសីលធម៌ខ្លួនឯងឡើងវិញផង! ហេតុអីមានរូបស្រីអាសអាភាសពេញបន្ទប់?»

គេអស់សំណើចពេលនឹកឃើញពាក្យសម្តុតរបស់អតីតឪពុកគូដណ្តឹង។ មាត់ពោលគួរសមទៅស្ត្រីនោះវិញ៖

«ស្នងការថ្មីចូលកាន់តំណែងកាលពីថ្ងៃចន្ទ! អ្នកបងជួបគាត់ហើយ?»

«ចាំខ្ញុំកំពុងរៀបចំបែបបទចូលសំណេះសំណាលជម្រាបការងារ UNWoman ដល់គាត់!»

«បាទ!»

«លោកទៅអាល្លឺម៉ង់រៀនមុខវិជ្ជាអ្វី?»

«ជំនាញបង្រ្កាបឧក្រិដ្ឋកម្មបច្ចេកវិទ្យាបាទ!»

នៅលើយន្តហោះគេចាប់ផ្តើមបើករកសំបុត្ររបស់នាង។ ចិត្តគេញាប់ញ័រពេលឃើញអក្សរខ្មែរដែលនាងសរសេរដោយដៃ។

ជាមួយពន្លឺចាំងចូលមកតាមបង្អួចបក្សីយន្ត គេចាប់ផ្តើមបំភ្លេចចោលគ្រប់យ៉ាងហើយអានវា....

«អរគុណចំពោះសំបុត្រជាច្រើនរបស់លោក Roy! លោកពិតជាមានការព្យាយាមខ្ពស់ខ្ពស់ចង់ឱ្យខ្ញុំកែខ្លួន! តែលោកកុំព្យាយាមដាស់មនុស្សដែលមិនបានដេក ហើយធ្វើជាដេក! ខ្ញុំដឹងច្បាស់ណាស់ថា អ្វីទៅដែលខ្ញុំ បានចាប់យកសម្រាប់ជីវិតខ្លួនឯង? គ្មានអ្នកណាដឹងថា ចុងក្រោយម្តាយខ្ញុំស្លាប់ដោយរបៀបណានោះទេ! លោកមិនដែលឃើញមនុស្សដែលលោកស្រលាញ់ជាងគេ ស្ថិតក្នុងសភាពរលេះរលួយហើយនៅមានដង្ហើមនោះឡើយ Roy! ម្តាយខ្ញុំរងទារុណកម្មផ្លូវចិត្តពេញមួយជីវិតរបស់គាត់ ហើយចុងក្រោយក៏ត្រូវទទួលបន្ថែមភាពខ្លោចផ្សាផ្លូវកាយពីស្នាដៃមនុស្សប្រុសដែលគាត់ស្រលាញ់ជាងគេ! ប៉ូលិសសេតវិទូត្រូវទទួលខុសត្រូវ ព្រោះគេជាអ្នកដែលវែកញែកក្តីម៉ោង១២អធ្រាតនៅសង្កាត់លេខមួយ! ទោះគេចាប់លោកកុសលបានតែម្តាយខ្ញុំបានជ្រុលរងគ្រោះទៅហើយ! ម្តាយខ្ញុំលើកទោសឱ្យគេតែខ្ញុំគ្មានថ្ងៃព្រម! ខ្ញុំជាក្មេងកំព្រាដែលគ្មានអ្នកអើពើ! ជាក្មេងស៊ីកាកសំណល់តាមចិញ្ចើមផ្លូវ ហើយត្រូវរងការវាយដំបង្ខំផ្លូវភេទតាំងពីអាយុ៩ឆ្នាំ! អ្នកស្រីកុលាបបានលះបង់ភាពជាមនុស្សខ្ពង់ខ្ពស់

របស់គាត់ ហើយទុកខ្ញុំជាកូនម្នាក់ ជាកូនស្រីតែមួយគត់! ខ្ញុំទៅរៀននៅសិង្ហបុរី ចុងក្រោយ Manchester! ខ្ញុំតែងនឹកឆ្ងល់ថា ហេតុអីប៉ាធម៌មិនដែលមកជាមួយម៉ែធម៌! ហេតុអីម៉ែខ្ញុំតែងតែអង្គុយយំនៅពេលយប់ជ្រៅម្នាក់ឯងៗ ញ៉ាំស្រាទាំងដបៗ! ពេលខ្ញុំអាយុ១៨ឆ្នាំ គាត់បានផេរលុយជាច្រើនមកឱ្យហើយបង្គាប់ឱ្យខ្ញុំទិញអចលនទ្រព្យនានាទុកជាកម្មសិទ្ធិផ្ទាល់ខ្លួន!គាត់ដឹងខ្លួនជាមុនថារស់បែបនេះមិនបានវែងឆ្ងាយ បានជាគាត់រៀបចំគ្រប់យ៉ាងជាមុនដើម្បីធានាអនាគតកូនចិញ្ចឹមម្នាក់នេះ! ខ្ញុំជួបម៉ែធម៌ចុងក្រោយនៅពេលដែលគាត់មើលខ្ញុំលែងស្គាល់! គាត់តែងសរសេរសំបុត្រមកកុហកហើយមិនព្រម Skype! ខ្ញុំឡើងមកភ្នំពេញយ៉ាងស្ងាត់កំបាំងដើម្បីស្វែងរកការពិត! ហើយការពិតចុងក្រោយដែលខ្ញុំរកឃើញគឺម្ដាយខ្ញុំជិតស្លាប់ក្នុងពេទ្យមួយយ៉ាងឯកោនៅឯប្រទេសថៃ! មនុស្សប្រុសម្នាក់នោះមិនដែលស្ដាយក្រោយក្នុងការបំផ្លាញជីវិតម្ដាយធម៌ខ្ញុំឡើយ!ស្ដាយណាស់ដែលវានោះឆាប់ស្លាប់ មិនអ៊ីចឹងខ្ញុំមិនផ្ទេរគំនុំនេះទៅភីណា និងគ្រួសារគេព្រមទាំងប៉ូលិសគ្មានបានការម្នាក់នោះទេ! ក្នុងសំបុត្រទីមួយរបស់លោក លោកសួរខ្ញុំថា តើរាល់ពេល ក្រោក ព្រលឹមឡើងខ្ញុំចង់ជ្រើសរើសភាពសប្បាយឬជ្រើសរើសការគិតដ៏សោកខ្ញុំគ្មានជម្រើសទេ roy ខ្លួនប្រាណខ្ញុំ សាច់ឈាមខ្ញុំ បង្កប់នូវស្រមោលម្ដាយខ្ញុំជានិច្ច រូបភាពដ៏គួរឱ្យព្រឺខ្លាចដែលកើតឡើងលើគាត់ មុនពេលស្លាប់វាថតជាប់ក្នុងភ្នែកខ្ញុំ ដិតដាមក្នុងជីវិតខ្ញុំ បើខ្ញុំសើចសប្បាយបានទាល់តែខ្ញុំឆ្កួតសិន! សំបុត្រទី៥ លោកសួរខ្ញុំថា តើពិបាកអ្វីខ្លះក្នុងនេះ ចង់បានអ្វី? ចង់ឱ្យលោកជួយអ្វី? ខ្ញុំនៅទីណាក៏ដូចគ្នា Roy គុកហើយនឹងពិភពលោកខាងក្រៅសុទ្ធតែមិនស្វាគមន៍ខ្ញុំ តាំងពីថ្ងៃដែលខ្ញុំឃើញពន្លឺថ្ងៃលោកធំឡើងក្នុងសុភមង្គលលោកគ្មានថ្ងៃយល់ទេ! ហេតុអ្វី Lorenzo មានសែនមាន មកពីពិភពសែនស៊ីវិល័យ តែគេនៅជឿងប់លើអបិយជំនឿលោកមិនយល់ទេ វាព្រោះតែមនុស្សមានតែការឈឺចាប់ខ្លាំងអស់សង្ឃឹមខ្លាំងនឹងការពិតដូចគ្នា ទើបយល់ចំណុចនេះ ហើយខ្ញុំអាប្រើចំណុចខ្សោយនេះទៅធ្វើបាបគេបាន! លោកនៅអង់គ្លេសលោកចេះពាក្យថា Stereotypes លោកយល់ហើយថា វាជាអារម្មណ៍ផ្លូវចិត្ត ក៏អាចក្លាយមកជាអាវុធធម្មជាតិដ៏សាហាវមួយ យើងអាចវាយប្រហារមនុស្សណាម្នាក់ ដោយការយល់ដឹងពី Stereotypes នេះមិនឱ្យគេរើខ្លួនរួច! Loren ច្រឡំថាខ្លួនឯងអស្ចារ្យ អ្នកណាក៏ស្រលាញ់គេ នេះហើយដែលគេមិនអាចរកឃើញល្បិចរបស់ខ្ញុំ! ជួនកាលក្នុងជីវិត រឿងជាច្រើនយើងអាចបំភ្លេចបាន តែរឿងខ្លះ គ្មានថ្នាំព្យាបាលជារៀងរហូត! តួយ៉ាងឪុកសេណាកាក៏ដូចគ្នា! ការឈឺចាប់ដ៏ជ្រៅរបស់ឪពុកម្នាក់ គ្មានអ្នកណាអាចយល់ដល់ទេ ប្រសិនគេមិនបានឆ្លងកាត់វាជាមួយបទ

ពិសោធន៍ផ្ទាល់ខ្លួន! តែខ្ញុំអាចយកឈ្នះចិត្តគាត់បានឱ្យគាត់ព្រមចូលរួមជាមួយ ព្រោះខ្ញុំយល់អ្វីទាំងនេះលើសពីដែលពួកប៉ូលិសអាចយល់! លោកបានព្រោះលោកមានការបែងចែកច្បាស់រវាងការងារនិងមនោសញ្ចេតនា! ក្នុងសំបុត្រទី៩លោកសួរខ្ញុំថា ខ្ញុំមានមនោសញ្ចេតនាដែរទេ? ខ្ញុំនៅសល់ចិត្តថ្លើមជាមនុស្សស្រីម្នាក់ដែរទេ? លោកឆ្លើយខ្លួនឯងទៅ Roy! ខ្ញុំមិនបានសម្លាប់អ្នកណាម្នាក់ឡើយនៅក្នុងគម្រោងការលើកលែងតែជនបោកប្រាស់មហាវីន! គេនោះសមណាស់នឹងស្លាប់!មនុស្សហ៊ឹហា ឡូយឆាយមានគេអោនលំទោននៅក្នុងសង្គមមួយទាំងដែលរស់នៅគ្មានភាពអាណិតអាសូរគ្មានភាពយោគយល់ ស្គាល់តែប្រយោជន៍ បម្រុងតែនឹងទ្រុស្ត ប៉ុន្តែច្បាប់បែរជាការពារគេ! តើលោកទៅអាល្លឺម៉ង់រៀនសូត្រមកការពារពួកនេះ? »

«នាងបានសម្លាប់អតីតប៉ូលិសសុខា ហើយបានបំផ្លាញអនាគតកូនភ្លោះពីរនាក់ដែលនាងប្រើប្រាស់!»

គេនិយាយម្នាក់ឯងទាំងបត់សំបុត្រនោះទុកហើយគ្រវែងវាចោលទៅក្នុងធុងសំរាម។ គេនិយាយបន្ថែមតិចៗក្នុងចិត្តះ

«គ្រប់គ្នាតែងមានហេតុផលក្នុងការកាន់ជើងខ្លួនឯង សម្រាប់អំពើអាក្រក់ដែលបានបង្កឡើង! តែចិត្តសាស្ត្រនេះមិនអាចបំភ័ន្តអ្នកអនុវត្តិច្បាប់បានទេ Rose! ខ្ញុំបានធ្វើរឿងជាច្រើនរួចហើយសម្រាប់នាង ក្នុងនាមជាមិត្ត! លាហើយ Rose»

វគ្គ កូននាគសំណព្វចិត្ត

Lorenzo ត្រឡប់មកដល់ផ្ទះអនាគត ក្នុងសម្លៀកបំពាក់សាមញ្ញ តែបេះដូងពេញទៅដោយកម្តៅស្នេហ៍ គេនឹកដល់កូននាគជានិច្ចជាកាល បានជាចុងក្រោយនេះគេ សម្រេចចិត្តថា នឹងមិនអាចបកទៅអាមេរិកដោយមិនមាននាងទៅជាមួយឡើយ។

ផ្ទះនេះនៅតែស្ងប់ស្ងាត់ដូចកាលពីគេទើបនឹងរត់លូនមកដល់ដំបូង។ ក្លិនឆៃថាវនឹងគ្រៃប្ញស្សី ប៉ុន្តែគ្មាននាង???

គេចាប់ផ្តើមចេះភ័យ!

ចរិតគួរឱ្យស្រលាញ់របស់ស្រីតូចនេះមិនមែនជាការសម្ដែងទេ ដូច្នេះអនុស្សាវរីយ៍ពិតវាពិបាកភ្លេចណាស់។ គេដឹងថាខ្លួនឯងស្រលាញ់នាងខ្លាំង ជាពិសេសពេលដែលចុះពីម៉ូតូឌុបមក ហើយមិនបានឃើញនាងឈរហាលថ្ងៃថាវក្បៀរមាត់បង្អួចដូចការរំពឹងទុក។

«កូននាគៗ»

គេស្រែកហៅតែគ្មានសំឡេងតប។ ប្រុសស្អាតទម្លាក់បង្វេចទៅលើគ្រែឫស្សីដែលកាលណោះខ្លួនគ្រេចករើងាកក៏មិនចង់បាន ហើយចាំបានថាខ្លួនមិនចង់សូម្បីស្នាក់នៅទីនេះបន្ថែមមួយវេលាណា។

ហេតុអ្វីពេលនេះអន្ទះសាចង់វិលមកវិញ។

«អ្ហូយទីបំផុតបងឯងមកចំពេលល្មមហ្មង!»

សំឡេងនាងនៅមាត់ទ្វារធ្វើឱ្យនរៈបែរខ្លួនទៅដោយស្វ័យប្រវត្តិ។

នារីនេះរត់មកទាំងញើសកក្លាក់ហើយអោបផ្កាព្រៃមួយសំណុំត្រកងក្នុងដៃ។

«មកពីណា?»

គេនិយាយខ្លីៗ ព្រោះមាត់រវល់ញញឹមស្វាគមន៍ការមកដល់របស់នាង។ សរសៃសក់វែងអន្លាយរបស់សន្សារសាត់តិចប៉ើងៗតិចៗ តាមកម្លាំងខ្យល់ជាយព្រៃ បន្ថែមសម្រស់នាងជាមួយផ្កាពណ៌ស្វាយមួយបាច់ធំក្នុងហត្ថា ញ៉ាំងឱ្យបុរសនេះចង់គូរគំនូររូបនាងរក្សាទុកក្នុងបេះដូងជារៀងរហូត។

«ឮបងសួរអត់ មកពីណា?»

នាងដាក់ផ្កាទៅម្ខាងហើយស្ទុះមកទាញបង្វិលរាងកាយនាយពិនិត្យមុនក្រោយ។

«ធ្វើអីនៀក?»

នេះជាលើកដំបូងក្នុងជីវិតអភិជន Loren ដែលមានអ្នកណាម្នាក់មកបង្វិលកាយគេពិនិត្យគ្រវាត់គ្រវែង។ តាមថាគេនឹងខឹងហើយធ្វើឫកដូចចុះមកពីលើមេឃ តែថ្ងៃនេះគេញញឹមតាមដាននាងហើយក៏មិនជំទាស់និងសកម្មភាពស្លន់ស្លោរបស់នាង។

«ខ្ញុំត្រូវការមនុស្សម្នាក់ បន្លំធ្វើជា Lorenzo»

បុរសគាំងចលនា គេនៅធ្មឹង ពេលឮពាក្យនាង។ គេខំពិនិត្យមើលតើនាងនិយាយពិតឬមួយនាងធ្វើពុត។ នាងនៅតែបង្វិលកាយគេហើយពោលបង្អាប់៖

«បងឯងមើលយ៉ាងណាក៏នៅតែក្រៗ ធ្វើ Lorenzo គ្មានអ្នកណាគេជឿដឹង?»

នាងនិយាយសរសើរឬបង្អាប់? គេគិតហើយជ្រួញចិញ្ចើមមួម៉ៅ។ គេសម្លឹងថ្វាសនាងដែលឈ្ងោកទាបកញ្ច្រិចនៅក្រោមទ្រូង ហើយឆ្លេឆ្លាពិនិត្យខ្លួននាយចុះឡើងមិនដាច់ស្រេច។

Loren គំហកតិចៗ៖

«និយាយរឿងស្អីនៀក?»

ស្រីតូចងើបមុខមកវិញ ហាក់មិនអើពើនឹងកំហឹងក្នុងភ្នែកនាយ នាងនិយាយពន្យល់ប្រញិបប្រញាប់៖

«នៅភូមិមានពិធីអង្គាសលុយសង់សាលានិងបុកអណ្ដូង! ពួកថៅកែៗចុះមកពីខេត្តច្រើនណាស់! មេភូមិប្រាប់ថា ពួកនោះភាគច្រើនធ្វើបុណ្យតាមគ្នា និយាយឱ្យស្រួលស្ដាប់គឺធ្វើបុណ្យយកមុខ! កាលណាមានអ្នកមានមកពីភ្នំពេញចូលរួម ពួកគេកាន់តែខំបរិច្ចាគ ឥឡូវនេះវ័ណ្ឌកហើយ ខ្ញុំកុហកគេថា បងធម៌ខ្ញុំស្គាល់ Lorenzo សន្យាថា Lorenzo នឹងមកចូលរួមនៅទីនោះ! មានថៅកែសិប្បកម្មថៅកែមាសថៅកែដី ថៅកែស្វាយ ថៅកែស្រាមកចុះឈ្មោះរាប់រយនាក់! ពួកគេចង់ថតជាមួយ Lorenzo ពេលនេះបងឈុនរាជខលមកថារក Lorenzo មិនឃើញ! ចប់ហើយខ្ញុំ!»

«ស្រលះទៅ ក្មេងប៉ិនកុហក!»

គេថាឱ្យទាំងមុខស្មើ។ loren តាំងពីដើមមកស្អប់បំផុត អ្នកណាដែលប្រើឈ្មោះនាយយកលាភយកមុខ។ ពេលនេះស្អប់ណាស់ជួបណាស់។

សន្យាឃើញនាយថាឱ្យហើយធ្វើមុខស្មើថែសទៀត នាងក៏ធ្វើមុខចង់យំសម្លឹងនាយបកវិញភ្លឹះៗ។ចិត្តស្នេហាបានគ្របដណ្ដប់ត្រជាក់ល្ហឹមមកលើបេះដូងបុរស។ គេផ្ដើមស្រាយទឹកមុខសន្សឹមៗហើយញញឹមសួរតិចៗ៖

«ចុះបើគេដឹងការពិត មានរឿងអីកើតឡើង?»

«អ្នកភូមិនឹងបណ្ដេញលែងឱ្យធ្វើពិធី! ខូចឈ្មោះ ហើយថ្ងៃក្រោយកុំសង្ឃឹមបានប្រមូលលុយបរិច្ចាគអីទៀត!»

«សមមុខ!»

គេរអ៊ូតិចៗ តែនាងលបស្ដាប់ឮហើយវាយនាយផាច់ៗ។

«ខ្ញុំមិនដឹង! បងឯងត្រូវក្លែងធ្វើជាគេ ដើរតួឱ្យបានល្អបំផុត!»

គេនៅស្ងៀមដៀងភ្នែកសម្លឹងនាង ជាពន្លឺភ្នែកពេញដោយសេចក្ដីកក់ក្ដៅ និងភាពឈឺឆ្អាលដែលមានតែមនុស្សស្រលាញ់គ្នាទេ គេប្រើវាចេញមកបាន។

ពីដំបូងឡើង ចិត្តអាណិកជនគឺចង់ចេញពីទីនេះឱ្យកាន់តែឆាប់ តាមដែលអាចធ្វើទៅបាន ហើយនាំនារីតូចនេះទៅជាមួយ។ ពីតាមផ្លូវមកកាលណាគេប្រាថ្នានិយាយការពិតប្រាប់ដល់នាង ហើយនាំនាងទៅ តែពេលនេះ នាងមើលទៅហាក់មិនចង់ឮអ្វី ក្រៅតែពីតួអង្គ lorenzo ក្លែងក្លាយនោះទេ។

«មិញពីណាថាបងមើលទៅក្ររហាម! ធ្វើអីក៏មិនសមហើយមករកបងធ្វើអី?»

«ចាំខ្ញុំបង្រៀនបងឯងធ្វើឬកឱ្យសមអ្នកមាន!»

គេចងចិញ្ចើម។ តើគួរសើច ឬយំនៀក?

គេគិតផងត្រូវនាងអូសទីណាត់ទីណែងឱ្យឈរកណ្ដាលផ្ទះ។ នាងចាប់ផ្ដើមនិយាយ៖

«តោះឧបមាថា បងឯងកំពុងពាក់អាវធំហើយ ហើយមនុស្សជាច្រើនសងខាងផ្លូវចាំស្វាគមន៍បងឯង! បងឯងជាអ្នកមានលុយបរិច្ចាគច្រើនជាងគេក្នុងកម្មវិធី ហើយបងឯងជាអ្នកមានដែលគ្រប់គ្នាដណ្ដើមចង់ Selfie ដាក់ Facebook! តោះឥឡូវនេះទ្វារនៅខាងណោះ គ្រប់គ្នានៅចំហៀងនេះ មើលមកបងឯង! ពេលមេក្រូប្រកាសថាលោក Lorenzo មកដល់ហើយ បងឯងដើរចូលមកឱ្យសង្ហា! តោះ! ដើរមកៗ»

នាងបកដៃហៅភ្លាមៗធ្វើឱ្យបុរសរង៉ើរង៉េ។

គេដើរមួយៗ ចូលមកតែនាងធ្វើមុខមិនពេញចិត្តសោះឡើយ។ នាងរអ៊ូ៖

«បងឯងមិនដែលពាក់អាវធំមិនដែល ចូលពិធីធំ ដើរឆ្គងអ៊ីចឹងហ្មង! នៀកៗចាំខ្ញុំធ្វើឱ្យមើល! Lorenzoគេដើរអ៊ីចេះ!»

បុរសឈប់ស្ងៀមហើយដៀងភ្នែកមកសម្លឹងនាងច្រមក់។

នាងបន្ទោសចច្រែត៖

«បងឯងឈប់ធ្វើអី? ប្រឹងរៀនឡើងត្រូវមានការងារច្រើនណាស់ត្រូវទៅ រកជួលអាវធំមកពាក់ទៀតណ៎ា! ហើយសក់នៀក សក់មើលទៅមិនសមអ្នកមានសោះត្រូវកាត់ចេញ!»

«អ្ហះ? កាត់សក់?»

វគ្គ តារាសប្បុរសរបស់អូន

ព្រលឹមស្រាងៗ កូននាគនៅក្នុងភូមិជាមួយអ្នករៀបចំកម្មវិធីរបស់នាង។ នាងស្លៀកពាក់ខ្មែរអាវប៉ាក់សំពត់ហូលស្អាតដូចទេវតាតែ នាងអន្ទះអន្ទែងរង់ចាំមើលតែផ្លូវបុរស Lorenzo របស់នាង។

«សន្យា! អត់បែកការណ៍ទេអ្ហីក្មួយ?»

ពូនាងសួរទាំងភ្នែកកញ្ជឹងក ព្រោះដង្ហៅៗបើកឡានទំនើប មកបន្តបន្ទាប់គ្នា ព្រោះគេស្ងប់ស្ងែងតារាសប្បុរសនៅភ្នំពេញដែលធ្លាប់ឮតែឈ្មោះ កម្រមានអ្នកមានបានឃើញមុខ។

«ពូកុំស្លន់ប្រយ័ត្នគេដឹង! អត់អីទេ! គេនោះសង្ហាដែរតើ! ខ្ញុំបង្ហាត់គេមួយយប់ហើយ! សង្ឃឹមថាគ្រប់យ៉ាងដំណើរការដោយរលូន!»

«គេនៅឯណា ថ្មើរណាបានមក!?»

«អត់អីទេពូអាចយឺតតិចតួច ប៉ុន្តែគេចេញតាំងពីល្ងាចមិញ ទៅរកជួលអាវនិងកាត់សក់!»

រថយន្តទំនើបខ្មៅវែងដែលអ្នកស្រុកនេះមិនដែលទិញជិះបង្ហាញខ្លួនក្បែររោងបុណ្យ។ ពួកគេនាំគ្នាដកកមើល ព្រោះឡានទាំងនេះមានតែពួកមហាសេដ្ឋីខ្មែរដែលមានលទ្ធភាពទិញជិះ។

«Lorenzo មកដល់ហើយ!»

ម្នាក់ៗខ្សឹបខ្សៀវគ្នាលាន់រំពង ហើយគ្រប់គ្នាក្រោកមកក្បែរផ្លូវចូលដើម្បីបានរលាក់ដៃតួសប្បុរសដ៏ល្បីរន្ទឺ។ កាមេរ៉ាគ្រប់គ្នាក៏បានត្រៀមថត ធ្វើឱ្យពូនាងដែលយកនាងមកថៃចិញ្ចឹមតាំងពីតូចក្រូចឆ្មារពេលនេះចំហរមាត់គាំង។

ប្រុសស្អាត Lorenzo មិនបានជួលអាវធំអ្វីពាក់ដូចនាងបញ្ជាកាលពីយប់ទេ ប៉ុន្តែគេចេញពីក្នុងជួររថយន្តខ្មៅស្និទ្ធលបន្តគ្នា៦គ្រឿង ហើយដើរមកក្នុងចំណោមអ្នកហែហមមានទាំងជំនួយការវឌ្ឍនៈផងធ្វើឱ្យគេមានរូបភាពជារាជបុត្រ Lorenzo ពិតៗដូចដែលអ្នកស្រុកធ្លាប់ល្បី។

នាងងាកមកមើលបុរសនេះ ហើយធ្វើភ្នែកភាំងៗចំពោះស្នាមញញឹមស្រស់របស់នាយ។ អ្នកស្រុកដណ្តើមគ្នារលាក់ដៃ និងថតរូបជាមួយគេ។ ដង្ហៅទាំងឡាយញញឹមបិទមាត់មិនជិតពេលគេដើរមកដល់ ហើយចុងក្រោយគេក៏ងាកមកឃើញនាង.....

កូននាគដែលស្លៀកពាក់សុភាពរាបសារគួរឱ្យស្រលាញ់ កំពុងចំហមាត់ចងចិញ្ចើមសម្លឹងដំណើរដូចរាជសីនៃប្រុសស្អាត ព្រោះ Lorenzo បានបំបែរគោលដៅ ដើរមួយៗមករកនាង។

អង្គរក្សទាំងឡាយរួមទាំងជំនួយការវឌ្ឍនៈផងថយទៅក្រោយ ទុកឱកាសនេះឱ្យថៅហ្វាយចូលទៅសាងភាពឯកជនជាមួយកូននាគតូច....

នាងសម្លឹងនាយដោយកែវភ្នែកស្រទន់។ គេពិតជាសង្ហាជារាជបុត្រក្នុងរឿងបុរាណដែលនាងតែងតែស្រមៃប្រឌិតហើយនិទានបង្អួតក្មេងៗនៅផ្ទះអនាគត។

ដំណើរនាយពិតជាហ៊ីហាររហូតបេះដូងសឹងភ្លេចដកដង្ហើមបាន។

ចំហាយនៃចរន្តរត់រកគ្នារវាងភេទផ្ទុយទាំងទ្វេមានអានុភាពអាចបណ្តាលឱ្យបេះដូងស្រីតូចចេញដង្ហើមកាន់តែក្តៅឡើងៗ។

គេមកដល់ហើយ គឺមកកៀកប្រមាណជាពីរចំអាមពីនាង ហើយភ្នែកនាងត្រូវទើរត្រឹមតែដើមទ្រូងគេព្រោះចាញ់កម្ពស់។

នាងងើបមុខឡើងមើលគេមិនរួច ព្រោះអៀនមហាអៀន។ ឃើញនាងចាញ់ប្រាបភាពជាបុរសនិងមន្តស្នេហ៍របស់គេ Loren នៅស្ងៀមសម្លឹងនាងទុកឱ្យកាមេរ៉ាទាំងឡាយបាញ់តាមត្រូវការ។

ស្រីស្អាតស្រវារកវិធីបំបែកអារម្មណ៍អៀនហើយបន្ទោសតិចៗ៖

«មនុស្សបងឯង ប្រាប់ឱ្យធ្វើអ៊ីចេះទៅធ្វើអ៊ីចុះ! ឱ្យជួលអាវធំពាក់ បងឯងជួលឡានមកម្តង៦គ្រឿង! ខ្ញុំបានស្អីទៅបង់គេ? ហើយអស់ប៉ុន្មានជួលប៉ុណ្ណឹង? ខ្ញុំបានលុយឯណាឱ្យថ្លៃឡានគេនៀក»

នាងងើបមុខមកជាមួយកង្វល់ តែនាងត្រូវទើរព្រោះគេសម្លឹងនាងយ៉ាងស្រទន់។ សន្យានៅគាំងកណ្តាលសមុទ្រស្នេហាដែលល្ងឹងល្ងើយដូចគ្មានអ្នកណានៅទីនេះក្រៅតែពីនាងហើយនឹងគេ។ សូរសព្ទមេក្រូលាន់មកកោកៗផ្តាច់សង្វាក់ដង្ហើមក្តៅឧណ្ហៗរបស់នាង៖

«សរុបប្រាក់បរិច្ចាគគឺបាន សាលាប្អូនខ្នងនិងអណ្តូង២២៣! ក្នុងនោះលោក Lorenzo តែឯងបានជួយ១០០ អណ្តូងនិងសាលាផ្ទះអនាគតចំនួនពីរខ្នង! លុយសុទ្ធទាំងអស់នៅទីនេះ»

«ហើយបងឯងបានលុយពីណាមក? បងឯងធ្វើម៉េចបានជា ធ្វើដល់ថ្នាក់ហ្នឹង! ឪខ្ញុំហ្មែន?»

អ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងសុំការខន្តីអភ័យទោសនូវរាល់កំហុសឆ្គងចំណុចខ្សោយនិងភាពយឺតយ៉ាវក្នុងការសរសេរបញ្ចប់រឿងភាគនេះ។ សូមរង់ចាំជួបគ្នានៅក្នុងប្រលោមលោកស៊ើបអង្កេតផ្សេងៗទៀតនៅពេលក្រោយ។

**សូមអរគុណ**

**ចប់**